# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 29-Sep-2014, 15:25
CMS/CFO: Sann Rada

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង: **សម្ងាត់/Confidential**

ចំណាត់ថ្នាក់ប្រភេទឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន: **សាធារណៈ**

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## បណ្ដឹងដិតចិត្តរបស់ នួន ជា ប្រឆាំងនឹងចៅក្រម និល ណុន ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc Lavergne និង ចៅក្រម យូរ ឧត្តរា

---

**<u>ដាក់ដោយ:</u>**

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ
Victor KOPPE
ព្រុំ ផល្លា
សួន វិសាល
លីវ សុវណ្ណា
Doreen CHEN
Joshua ROSENSWEIG
Xiaoyang NIE
Sophie DAWSON

**<u>ចម្លងជូន:</u>**

**សហមេធាវី ខៀវ សំផន**

គង់ សំអុន
Arthur VERCKEN
Anta GUISSÉ

**សហព្រះរាជអាជ្ញា:**

ជា លាង
Nicholas KOUMJIAN

**<u>សហមេធាវី តំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ
Marie GUIRAUD

# មាតិការឿង

I. **សេចក្ដីផ្ដើម** ..... 1

II. **សាវតារ** ..... 1

ក. ចៅក្រម ..... 1

ខ. ប្រវត្តិនីតិវិធី ..... 2

គ. ការបោះពុម្ពផ្សាយសៀវភៅរបស់ Marcel Lemonde ..... 4

ឃ. សុន្ទរកថាជាសាធារណៈរបស់ចៅក្រម Silvia Cartwright នៅឯវិទ្យាស្ថាន Aspen ..... 4

ង. សាលក្រមសំណុំរឿង ០០២/០១ និងសេចក្ដីសម្រេចស្ដាពរស្ដីពីសាក្សី ..... 5

III. **ច្បាប់ជាធរមាន** ..... 5

ក. ភាពមិនលម្អៀង និងឯករាជ្យភាពរបស់អង្គចៅក្រម ..... 5

ខ. បណ្ដឹងជំទាស់ចៅក្រម ..... 7

(i) ភាពផ្ទុយគ្នារវាងភាពលម្អៀងជាក់ស្ដែង និងការលេចចេញនូវភាពលម្អៀង ..... 7

(ii) ប្រភេទនៃការលេចចេញនូវភាពលម្អៀង ..... 8

(iii) រឿងក្ដី "ជាន់គ្នា" ..... 11

(iv) ការបង្ហាញឲ្យឃើញនូវការពុំមាន "ចិត្តគំនិតអនាគតិ និងមិនលម្អៀង" ..... 13

គ. ការដាក់ទាន់ពេលវេលានូវបណ្ដឹងជំទាស់ចិត្ត ..... 15

IV. **ឧទ្ធរណ៍** ..... 15

ក. បណ្ដឹងនេះបានដាក់ទាន់ពេល ដូច្នេះអាចទទួលយកបាន ..... 15

ខ. ការបដិសេធរបស់ចៅក្រមជាតិមិនកោះហៅ ហេង សំរិន បំផ្លាញដល់ការបង្ហាញឱ្យឃើញនូវ ឯករាជ្យភាព ឬបង្កើតឱ្យមានការលេចចេញនូវភាពលម្អៀង ....................16

(i) ការបំផ្លាញនូវការបង្ហាញឱ្យឃើញនូវឯករាជ្យភាព ....................18

(ii) ការបង្ហាញ *ឱ្យឃើញ*ភាពលម្អៀងដែលមិនអាចទទួលយកបាន ....................26

ឃ. ការប្រើប្រាស់ភាសាជាក់លាក់របស់ចៅក្រមនៅក្នុងសាលក្រមសំណុំរឿង ០០២/០១ នាំឱ្យមានការលេចចេញនូវភាពលម្អៀងដោយមិនអាចទទួលយកបាន ....................33

ង. កំហុសមួយចំនួននៅក្នុងសាលក្រមសំណុំរឿង ០០២/០១ បង្ហាញឱ្យឃើញនូវការលេចចេញនូវភាពលម្អៀងដែលមានស្រាប់ និងដែលមិនអាចទទួលយកបាន ដែលនឹងនាំឱ្យមានផលប៉ះពាល់លើសំណុំរឿង ០០២/០២....39

(i) *វចនាសម្ព័ន្ធនៃបក្សកុម្មុយនីស្តកម្ពុជា* ....................40

*(ii)* *អត្ថិភាពនៃគោលនយោបាយទាក់ទងនឹងការដាក់បទបញ្ជាទាក់ទងនឹងអាពាហ៍ពិពាហ៍*....................44

*(iii)* *ការយោងលើការវិភាគអំពីប្រជាសាស្ត្រ*....................47

*(iv)* *ការផ្អែកមូលដ្ឋានលើសាលក្រម ឌុច ដើម្បីកំណត់និយមន័យពាក្យ "កម្មេច"* ....................48

ច. ការសម្រេចរបស់ចៅក្រមនៅក្នុងសាលក្រមសំណុំរឿង ០០២/០១ អំពីអង្គហេតុទាក់ទងនឹងសំណុំរឿង ០០២/០២ នាំឱ្យលេចចេញនូវភាពលម្អៀងទាក់ទងនឹងសំណុំរឿង ០០២/០២....................50

*(ធ)* *ផលប៉ះពាល់នៃផ្នែកសំអាងហេតុនៅក្នុងសំណុំរឿង ០០២/ ០១ និងវិសាលភាពនៃសំណុំរឿង ០០២/ ០២*....................50

(*ii*) អត្ថិភាពនៃគោលនយោបាយទាំង ៥ របស់បក្សកុម្មុយនីស្តកម្ពុជាដែលរងការចោទប្រកាន់ ....................52

(iii) *គោលនយោបាយស្តីពីការកំណត់គោលដៅ "ខ្មាំង" ជាពិសេស "ប្រជាជនថ្មី" និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ* ....................53

(iv) *តួនាទីរបស់ នួន ជា នៅក្នុងការបង្កើត និងការអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា*..56

*(v)* *ទស្សនៈយល់ឃើញរបស់ជនជាប់ចោទ និងលើរឿងក្តីរបស់មេធាវីការពារក្តី* ....................58

ឆ. ការសម្រេចរបស់ចៅក្រម ណុន ចៅក្រមសុខន និងចៅក្រម *Lavergne* នៅក្នុងសាលក្រម ឌុច លើអង្គហេតុពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ នាំឲ្យលេចចេញនូវភាពលម្អៀងទាក់ទងនឹងសំណុំរឿង ០០២/០២ 59

ជ. ការសម្រេចនៅក្នុងសំណុំរឿង ០០២/០១ និងសាលក្រម ឌុច គឺជាការច្រានចោលបន្ទុកក្នុងការបង្ហាញភ័ស្តុតាង......64

ឈ. ចៅក្រមបានបង្ហាញនូវកង្វះសុចរិតភាពផ្នែកវិជ្ជាជីវៈដែលមិនអាចទទួលយកបាន ......65

V. **សេចក្តីសន្និដ្ឋាន** ......72

VI. **សំណើសុំ**......74

## I. សេចក្តីផ្តើម

1. អនុលោមតាមវិធាន ៣៤ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក សហមេធាវីការពារក្តីលោក នួន ជា ("មេធាវីការពារក្តី") សូមដាក់បណ្តឹងជំទាស់ដើម្បីដកចៅក្រម និល ណុន ចៅក្រម យ៉ា សុខន ចៅក្រម យូរ ឧត្តរា ("ចៅក្រមជាតិ") និង ចៅក្រម Jean-Marc Lavergne (ទាំងអស់គ្នានេះហៅថា "ចៅក្រម") ចេញពីការជំនុំជម្រះសំណុំរឿង ០០២/០២ និងកិច្ចដំណើរការនីតិវិធីទាំងអស់នៅក្នុងរឿងក្តី នួន ជា ("បណ្តឹងជំទាស់")។

2. ដោយយោងទៅលើហេតុផលទាំងនេះ (បរិយាយនៅខាងក្រោម) មេធាវីការពារក្តីស្នើឲ្យ (i) អង្គជំនុំជម្រះទទួលយកបណ្តឹងជំទាស់នេះ (ii) ចៅក្រមទាំងអស់គួរត្រូវបានដកចេញពីកិច្ចដំណើរការនីតិវិធីក្រោយៗប្រឆាំងនឹង នួន ជា (iii) ចៅក្រមលាលែងពីតំណែងដោយស្ម័គ្រចិត្ត ក្នុងខណៈដែលមានការសម្រេចលើបណ្តឹងជំទាស់នេះ (iv) ការចាប់ផ្តើមសវនាការលើអង្គសេចក្តីសំណុំរឿង ០០២/០២ ត្រូវតែពន្យាពេលរង់ចាំការសម្រេចលើបណ្តឹងនេះសិន និង (v) បណ្តឹងជំទាស់នេះគួរត្រូវបានចាត់ទុកជាបណ្តឹង ដែលត្រូវចាត់ការជាបន្ទាន់ ដោយសារតែលក្ខណៈពិសេសនៃបណ្តឹងនេះ។

## II. សាវតារ

### ក. ចៅក្រម

3. ក្រុមប្រឹក្សាជំនុំជម្រះនៃអង្គជំនុំជម្រះសាលាដំបូង រួមមានចៅក្រមជាតិ គឺចៅក្រម និល ណុន ចៅក្រម យ៉ា សុខន និងចៅក្រម ធូ មណី និងចៅក្រមអន្តរជាតិ គឺចៅក្រម Silvia Cartwright និងចៅក្រម Jean-Marc Lavergne ដែលបានដឹកនាំការជំនុំជម្រះក្តីសំណុំរឿង ០០១ ទាំងមូល និងបានចេញសាលក្រមសំណុំរឿង ០០១ ("សាលក្រម ឌុច") នៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០[1]។

4. អង្គជំនុំជម្រះសាលាដំបូងបានបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២ នៅក្នុងខែ កញ្ញា ឆ្នាំ

[1] សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អវតក/អជសដ ឯកសារ E188 ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ ("សាលក្រម ឌុច")។

២០១១[2]។ ក្រុមប្រឹក្សាជំនុំជម្រះដែលបានដឹកនាំការជំនុំជម្រះក្តីសំណុំរឿង ០០២/០១ ដែលត្រូវបានបំបែកនោះ គឺដូចគ្នាទៅនឹងក្រុមប្រឹក្សាជំនុំជម្រះសំណុំរឿង ០០១ ដែរ លើកលែងតែចៅក្រម យូរ ឧត្តារា ដែលបានជំនួសចៅក្រម ធូ មណី នៅក្នុងក្រុមប្រឹក្សាជំនុំជម្រះ។ ក្រុមប្រឹក្សានោះបានចេញសាលក្រមសំណុំរឿង ០០២/០១ នៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤[3]។ នៅថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៤ អ.វ.ត.ក បានប្រកាសថា ចៅក្រម Claudia Fenz នឹងជំនួសតំណែងចៅក្រម Silvia Cartwright នៅក្នុងក្រុមប្រឹក្សាជំនុំជម្រះសំណុំរឿង ០០២/០២[4]។

## ខ. ប្រវត្តិនីតិវិធី

5. នៅក្នុងខែ កុម្ភៈ ឆ្នាំ ២០១១ មេធាវីការពារក្តី និងសហមេធាវីរបស់ អៀង សារី និង អៀង ធីរិទ្ធ បានដាក់បណ្តឹងជំទាស់សុំដកក្រុមប្រឹក្សាជំនុំជម្រះនៃអង្គជំនុំជម្រះសាលាដំបូងទាំងមូល ដែលបានទទួលសំណុំរឿង ០០២ មកជំនុំជម្រះ[5]។

6. នៅថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១១ អង្គជំនុំជម្រះដែលមានសមាសភាពពិសេស ("អង្គជំនុំជម្រះពិសេស") បានបដិសេធបណ្តឹងជំទាស់ទាំងបី ដោយសំអាងថា ក្រុមមេធាវីការពារក្តីខកខានពុំបានបង្ហាញភ័ស្តុតាងអំពីការយល់ឃើញដោយសមហេតុផលថា ចៅក្រមនឹងមិនអាចធ្វើការជំនុំជម្រះ

---

[2] ឯកសារ E124 "ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ស្ទួនពីរ នៃវិធានផ្ទៃក្នុង" ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១។ ឯកសារ E163 "សេចក្តីជូនដំណឹងអំពីសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង ០០២/០១" ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២។

[3] ឯកសារ E313 "សាលក្រមសំណុំរឿង ០០២/០១" ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៤។

[4] អវតក "លោកស្រី ក្លូឌៀ ហ្វិន ត្រូវបានតែងតាំងជាចៅក្រមអន្តរជាតិថ្មីនៃអង្គជំនុំជម្រះសាលាដំបូង" ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៤ គេហទំព័រ http://www.eccc.gov.kh/en/articles/claudia-fenz-appointed-new-international-judge-trial-chamber។ ដោយសារតែចៅក្រម Cartwright នឹងមិនដឹកនាំការជំនុំជម្រះលើសំណុំរឿង ០០២/០២ នោះ បណ្តឹងជំទាស់នេះមិនមែនស្នើសុំដកលោកស្រីទេ។

[5] ឯកសារ E28 "បណ្តឹងជំទាស់របស់មេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹងចៅក្រម និល ណុន ចៅក្រម Silvia CARTWRIGHT ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE និងចៅក្រម ធូ មណី" ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១១ ("បណ្តឹងជំទាស់របស់ អៀង ធីរិទ្ធ")។ ឯកសារ E53 "សារណារបស់លោក អៀង សារី គាំទ្របណ្តឹងជំទាស់របស់ អៀង ធីរិទ្ធ និង នួន ជា ចំពោះចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង" ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១១ ("បណ្តឹងជំទាស់របស់ អៀង សារី")។ ឯកសារ E54 "បណ្តឹងជំទាស់ជាបន្ទាន់ចំពោះចៅក្រមអង្គជំនុំជម្រះសាលាដំបូង" ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ("បណ្តឹងជំទាស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូងលើកទីមួយរបស់មេធាវីការពារក្តី")។

ក្នុងសំណុំរឿង ០០២ ប្រកបដោយភាពអនាគតិនោះឡើយ[6]។ អង្គជំនុំជម្រះពិសេសនេះ ក៏បានសម្រេចផងដែរថា សេចក្តីសន្និដ្ឋានដែលបានធ្វើឡើងដោយចៅក្រមសំណុំរឿង ០០១ ដែលពាក់ព័ន្ធនឹង នួន ជា មិនមែនជាបុរេវិនិច្ឆ័យអំពីពិរុទ្ធភាពរបស់គាត់ដែលគួរត្រូវបានជំទាស់ឡើយ ពីព្រោះសេចក្តីសន្និដ្ឋាននោះពាក់ព័ន្ធតែទៅនឹងធាតុផ្សំមួយចំនួននៃឧក្រិដ្ឋកម្មដែលគាត់ត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២ ប៉ុណ្ណោះ មិនមែនធាតុផ្សំទាំងអស់ឡើយ។

7. នៅថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៤ សហមេធាវី ខៀវ សំផន បានដាក់សំណើមួយ ("សំណើរបស់ ខៀវ សំផន") សុំផ្អាកកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២/០២ រហូតដល់មានការចេញសាលក្រមសំណុំរឿង ០០២/០១ ឬម្យ៉ាងទៀត សុំជំទាស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូងទាំងអស់[7]។

8. នៅថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៤ គណៈកម្មាធិការរដ្ឋបាលតុលាការនៃ អ.វ.ត.ក បានចាត់តាំងចៅក្រមអង្គបុរេជំនុំជម្រះ ចៅក្រម ឆ្វ មណី (ប្រធាន) នៅចៅក្រមនៃអង្គបុរេជំនុំជម្រះចៅក្រម Rowan Downing ចៅក្រម Chang-ho Chung ចៅក្រម ហួត វុទ្ធី និងចៅក្រម ប៉ែន ពេជ្រសាលី ដើម្បីបង្កើតអង្គជំនុំជម្រះមួយធ្វើការពិនិត្យ និងវិនិច្ឆ័យលើបណ្តឹងជំទាស់ និងសំណើរបស់ ខៀវ សំផន នេះ[8]។

9. នៅថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើរបស់ខៀវ សំផន សុំពន្យាពេលសវនាការ[9]។ នៅថ្ងៃដដែល អង្គជំនុំជម្រះសាលាដំបូងបានចេញកាលវិភាគសម្រាប់

---

[6] ឯកសារ E55/4 "សេចក្តីសម្រេចលើបណ្តឹងរបស់ អៀង ធីរិទ្ធ, នួន ជា និង អៀង សារី ដែលប្តឹងជំទាស់ចំពោះលោកចៅក្រម និល ណុន ចៅក្រម Silvia CARTWRIGHT ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE និងចៅក្រម ធូ មណី" ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១១ ("សេចក្តីសម្រេចលើបណ្តឹងជំទាស់លើកទីមួយ")។

[7] ឯកសារ E314/1 "សំណើរបស់លោក ខៀវ សំផន សុំឱ្យពិនិត្យឡើងវិញពីភាពចាំបាច់ក្នុងការរង់ចាំសាលក្រមក្នុងសំណុំរឿង ០០២/០១ ចូលជាស្ថាពរ មុននឹងចាប់ផ្តើមការជំនុំជម្រះសំណុំរឿង ០០២/០២ និងសុំឱ្យពិនិត្យឡើងវិញពីការចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះថ្មីមួយ" ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៤។

[8] ឯកសារ E314/4 "សេចក្តីសម្រេចរបស់គណៈកម្មាធិការរដ្ឋបាលតុលាការ ទាក់ទងនឹងការចាត់តាំងសមាសភាពចៅក្រមដើម្បីពិនិត្យ និងវិនិច្ឆ័យលើបណ្តឹងជំទាស់ប្រឆាំងនឹងចៅក្រមអង្គជំនុំជម្រះសាលាដំបូង" ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៤ ទំព័រ ១។

[9] ឯកសារ E314/5 "សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំពន្យារការចាប់ផ្តើមសំណុំរឿង ០០២/០២" ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៤។

សវនាការលើសំណុំរឿង ០០២/០២ ដែលនឹងចាប់ផ្តើមក្នុងរយៈពេលបីសប្តាហ៍ខាងមុខ គឺនៅថ្ងៃទី ១៧ ខែតុលា ឆ្នាំ២០១៤។

10. នៅថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ មេធាវីការពារក្តីបានដាក់ជូននូវសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខលើសាលក្រមសំណុំរឿង០០២/០១ ដែលមាន២២៣មូលដ្ឋាននៃបណ្តឹងសាទុក្ខ[10]។

## គ. ការបោះពុម្ពផ្សាយសៀវភៅរបស់ Marcel Lemonde

11. នៅក្នុងខែ មករា ឆ្នាំ ២០១៣ អតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចៅក្រម Marcel Lemonde បានចេញផ្សាយនូវសេចក្តីពន្យល់មួយអំពីអាណត្តិរបស់គាត់នៅ អ.វ.ត.ក ដែលមានចំណងជើងថា *Un Juge en Face aux Khmers Rouges* ("សៀវភៅរបស់ Lemonde") ដែលរួមមានសេចក្តីថ្លែងមួយចំនួនពាក់ព័ន្ធនឹងចៅក្រមជាតិ ដែលនឹងត្រូវលើកយកមកពិភាក្សានៅក្នុងបណ្តឹងជំទាស់នេះ។

## ឃ. សុន្ទរកថាជាសាធារណៈរបស់ចៅក្រម Silvia Cartwright នៅឯវិទ្យាស្ថាន Aspen

12. នៅថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣ មួយសប្តាហ៍បន្ទាប់ពីសវនាការសំណុំរឿង ០០២/០១ បានបញ្ចប់ ចៅក្រម Cartwright បានថ្លែងសុន្ទរកថាជាសាធារណៈមួយនៅឯវិទ្យាស្ថាន Aspen ដែលអត្ថាធិប្បាយអំពីការជំនុំជម្រះក្តីរបស់ អ.វ.ត.ក ("សុន្ទរកថានៅឯវិទ្យាស្ថាន Aspen") ហើយវីដេអូនៃសុន្ទរកថានេះត្រូវបានដាក់ក្នុងប្រព័ន្ធអ៊ីនធឺណែត[11]។ នៅក្នុងសុន្ទរកថារបស់លោកស្រី ចៅក្រម Cartwright បានពិភាក្សាអំពីបញ្ហាជាច្រើន ដែលត្រូវបានលើកឡើងនៅក្នុងបណ្តឹងជំទាស់នេះ រួមមានបទពិសោធន៍របស់ចៅក្រមជាតិ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ និងប្រតិកម្មទៅនឹងភ័ស្តុតាងក្នុងសំណុំរឿង ០០២/០១ ព្រមទាំងមតិយោបល់ពាក់ព័ន្ធនឹងជនជាប់ចោទ និងសំណុំរឿង ០០២ ជាទូទៅ។

---

[10] "សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខលើសាលក្រមសំណុំរឿង០០២/០១" ថ្ងៃទី២៩ ខែ កញ្ញា ឆ្នាំ២០១៤ (រង់ចាំការដាក់លេខ)។

[11] ឯកសារ E305/12.38R "ការជំនុំជម្រះអំពើឧក្រិដ្ឋកម្មសាហាវឃោរឃៅ ៖ សាលាក្តីខ្មែរក្រហម យុត្តិធម៌អន្តរកាល និងនីតិរដ្ឋ" ("សុន្ទរកថានៅឯវិទ្យាស្ថាន Aspen") ឆ្នាំ ២០១៣។ វីដេអូនេះ ក៏អាចរកមើលបានជាសាធារណៈផងដែរនៅគេហទំព័រ៖ http://www.aspeninstitute.org/video/trying-atrocity-crimes-khmer-rouge-trials-transitional-justice-rule-law។

## ង. សាលក្រមសំណុំរឿង ០០២/០១ និងសេចក្តីសម្រេចស្តាពរស្តីពីសាក្សី

13. នៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រមសំណុំរឿង ០០២/០១ និងសេចក្តីសម្រេចស្ថាពរដែលពាក់ព័ន្ធស្តីពីសាក្សីដែលត្រូវស្តាប់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១ ("សេចក្តីសម្រេចស្ថាពរស្តីពីសាក្សី")[12]។

14. នៅក្នុងសេចក្តីសម្រេចស្ថាពរស្តីពីសាក្សី អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើរបស់ នួន ជា ស្នើសុំកោះហៅ សមាជិកលំដាប់ថ្នាក់ទី៣នៃរដ្ឋាភិបាលកម្ពុជា ប្រធានរដ្ឋសភាជាតិ និងអតីតមេបញ្ជាការយោធានៃបក្សកុម្មុយនីស្តកម្ពុជា ហេង សំរិន (នៅពេលនោះ ហៅថា TCW-223) ដើម្បីឱ្យមកផ្តល់សក្ខីកម្ម ដោយសារតែអង្គជំនុំជម្រះមិនអាចរកបានសំឡេងលើសលប់ដែលតម្រូវឱ្យមានជាចាំបាច់នោះ។ ចៅក្រមជាតិបានបោះឆ្នោតប្រឆាំងនឹងការកោះហៅរូបគាត់ ខណៈដែលចៅក្រមអន្តរជាតិពីររូបបានបោះឆ្នោតគាំទ្រការកោះហៅនេះ។ ចៅក្រមជាតិបានបញ្ជាក់ *ក្នុងចំណោមប្រការផ្សេងទៀត* ថា ការកោះហៅសមាជិកជាន់ខ្ពស់របស់រដ្ឋាភិបាល ដូចជា ហេង សំរិន ឱ្យមកធ្វើជាសាក្សី នឹង "នាំឱ្យ [...] លំបាកលំបិន" ដែលចៅក្រមជាតិ "មិនបានត្រៀមខ្លួន" "ប្រឈមមុខ"[13]។

# III. ច្បាប់ជាធរមាន

## ក. ភាពមិនលម្អៀង និងឯករាជ្យភាពរបស់អង្គចៅក្រម

15. សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយតុលាការឯករាជ្យ និងមិនលម្អៀង គឺជាសិទ្ធិមួយដ៏សំខាន់បំផុតរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌[14]។ សិទ្ធិនេះគឺជា "*សិទ្ធិ*

---

[12] ឯកសារ E312 "សេចក្តីសម្រេចស្ថាពរស្តីពីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវស្តាប់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១" ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ ("សេចក្តីសម្រេចស្ថាពរស្តីពីសាក្សី")។

[13] ឯកសារ E312 សេចក្តីសម្រេចស្ថាពរស្តីពីសាក្សី កថាខណ្ឌ ៩៧, ១០៣។

[14] UDHR មាត្រា ១០, ICCPR មាត្រា ១៤(១), ECHR មាត្រា ៦(១), ACHR មាត្រា ៨(១), AfCHPR មាត្រា ៧(១)។ *សូមមើលផងដែរ* រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Furundžija* សាលដីកា សំណុំរឿងលេខ IT-95-17/1-A ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០០ ("សាលដីការឿងក្តី Furundžija កថាខណ្ឌ ១៧៧។ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Nahimana និងអ្នកផ្សេងទៀត "សាលដីកា" សំណុំរឿងលេខ* ICTR-99-52-A ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ("សាលដីការឿងក្តី Nahimana") កថាខណ្ឌ ២៨, ៤៧។

*ពេញលេញ*ដែលមិនអាចមានករណីលើកលែងឡើយ”[15]។ មានន័យថា សិទ្ធិនេះអនុវត្ត “នៅគ្រប់កាលៈទេសៈទាំងអស់ និងគ្រប់តុលាការទាំងអស់ មិនថាតុលាការធម្មតា ឬតុលាការពិសេសឡើយ”[16]។

16. ភាពមិនលម្អៀង គឺជាគុណសម្បត្តិមួយក្នុងចំណោមគុណសម្បត្តិនានាដ៏សំខាន់បំផុតដែលចៅក្រមត្រូវតែមាន។ ក្នុងការបញ្ជាក់ការគាំទ្រលក្ខន្តិកៈនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិនានា[17] កិច្ចព្រមព្រៀង អ.វ.ត.ក និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងថា ចៅក្រមត្រូវតែជាបុគ្គលដែលមាន “ចរិតលក្ខណៈ និងស្មារតីខ្ពស់ មិនលម្អៀង និងសុចរិត”[18]។

17. ចៅក្រម អ.វ.ត.ក ត្រូវ “ឯករាជ្យនៅក្នុងការបំពេញការងាររបស់ខ្លួន” ផងដែរ ហើយមិនត្រូវ “ទទួល ឬស្វែងរកការបង្គាប់បញ្ជាពីរដ្ឋាភិបាលណាមួយ ឬពីប្រភពណាមួយផ្សេងទៀតឡើយ”[19]។ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR បានចាត់ទុកឯករាជ្យភាពរបស់តុលាការជា “លក្ខណៈសម្បត្តិមុខងាររបស់តុលាការ ដែលមានន័យថា ស្ថាប័ន ឬបុគ្គលដែលមានឯករាជ្យភាពមិនស្ថិតនៅក្រោមអំណាចពីខាងក្រៅទេ និងមានសេរីភាពពេញលេញក្នុងការធ្វើសេចក្តីសម្រេច”[20]។ នៅពេលធ្វើការវាយតម្លៃលើឯករាជ្យភាពរបស់តុលាការ ឬសាលាក្តី តុលាការសិទ្ធិមនុស្សអឺរ៉ុប (ECtHR) បានពិចារណាយ៉ាងយូរអំពី “លក្ខណៈនៃការតែងតាំងសមាជិករបស់តុលាការ/សាលាក្តី និងអាណត្តិការងាររបស់សមាជិកទាំងនោះ អត្ថិភាពនៃការការពារប្រឆាំងនឹងសម្ពាធពីខាងក្រៅ និង

---

[15] រឿងក្តី *González del Río ទល់នឹង ប្រទេសប៉េរូ* UN HRC, Comm. No. 263/1987, UN Doc. No. CCPR/C/46/D/263/1987 ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩២ កថាខណ្ឌ ៥.២ (សេចក្តីបញ្ជាក់បន្ថែម)។

[16] ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស សហប្រតិបត្តិការជាមួយគណៈមេធាវីអន្តរជាតិ *សិទ្ធិមនុស្សនៅក្នុងរដ្ឋបាលតុលាការ* ៖ សៀវភៅណែនាំស្តីអំពីសិទ្ធិមនុស្ស សម្រាប់ចៅក្រម រដ្ឋអាជ្ញា និងមេធាវី ឯកសាររបស់ UN លេខ HR/P/PT/9, ឆ្នាំ ២០០៣ ទំព័រ ១១៨។

[17] *សូមមើល ឧទាហរណ៍* លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា ៣៦(៣)(ក), លក្ខន្តិកៈតុលាការ ICTY មាត្រា ១៣, លក្ខន្តិកៈតុលាការ ICTR មាត្រា ១២, លក្ខន្តិកៈតុលាការ STL មាត្រា ៩(១)។

[18] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៣(៣)។ *សូមមើលផងដែរ* ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ១០ថ្មី។

[19] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ១០ថ្មី។ *សូមមើល ផងដែរ* លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា ៤០, លក្ខន្តិកៈតុលាការ STL មាត្រា ៩(១)។

[20] រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Nahimana និងអ្នកផ្សេងទៀត* សាលដីកា សំណុំរឿងលេខ ICTR-99-52-A ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧ កថាខណ្ឌ ១៩។

បញ្ហាថាតើតួអង្គនោះបង្ហាញឲ្យឃើញនូវឯករាជ្យភាព ដែរឬទេ”[21]។

## ខ. បណ្តឹងជំទាស់ចៅក្រម

18. អនុលោមតាមវិធាន ៣៤(២)នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក (“វិធានផ្ទៃក្នុង”) លក្ខណៈវិនិច្ឆ័យសម្រាប់សុំជំទាស់ចៅក្រម អ.វ.ត.ក មានដូចខាងក្រោមនេះ ៖

> ភាគីអាចធ្វើបណ្តឹងជំទាស់ចំពោះសហចៅក្រមស៊ើបអង្កេត ឬចៅក្រមនៃអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូល ក្នុងករណីណាមួយដែលចៅក្រមរូបនោះមាន ឬធ្លាប់មានផលប្រយោជន៍ផ្ទាល់ខ្លួន ឬហិរញ្ញវត្ថុ ឬមានការពាក់ព័ន្ធ ដែលអាចធ្វើឲ្យប៉ះពាល់យ៉ាងពិតប្រាកដដល់ភាពអនាគតិរបស់ចៅក្រមរូបនោះ ឬអាចបង្កើតឲ្យមានភាពលម្អៀង។

### *(i) ភាពខុសគ្នារវាងភាពលម្អៀងជាក់ស្តែង និងការលេចចេញនូវភាពលម្អៀង*

19. អ.វ.ត.ក ធ្លាប់បានដោះស្រាយ (និងបានបដិសេធ) បណ្តឹងជំទាស់ចៅក្រមចំនួន ១៤ បណ្តឹង នៅក្នុងសំណុំរឿង ០០២។ យុត្តិសាស្ត្ររបស់ អ.វ.ត.ក បានសម្រេចដោយមានភាពស៊ីសង្វាក់គ្នាថា លក្ខណៈវិនិច្ឆ័យនៅក្នុងវិធាន នៃវិធានផ្ទៃក្នុងសម្រាប់សុំជំទាស់ចៅក្រម រួមបញ្ចូលទាំងភាពលម្អៀងជាក់ស្តែងរបស់ចៅក្រម និងការលេចចេញនូវភាពលម្អៀងរបស់ចៅក្រមរូបនោះ ហើយថា នៅពេលបកស្រាយវិធាន នៃវិធានផ្ទៃក្នុង ទាក់ទិននឹងបញ្ហានេះ យុត្តិសាស្ត្ររបស់តុលាការ ICTY ត្រូវយកមកអនុវត្ត ដូចដែលបានឆ្លុះបញ្ចាំងនៅក្នុងរឿងក្តី *Furundžija*[22]។ ដើម្បីកំណត់នូវភាពលម្អៀងជាក់ស្តែង ភាគីត្រូវជំទាស់ទៅនឹងការសន្មតទុកជាមុននៃភាពអនាគតិរបស់ចៅក្រម[23]។ ទោះបីជាយ៉ាងណាក៏ដោយ មេធាវីការពារក្តីអះអាងថា ការជំទាស់បែបនេះ គឺមិនចាំបាច់

---

[21] *សូមមើល ឧទាហរណ៍* រឿងក្តី *Volkov ទល់នឹង ប្រទេសអ៊ុយក្រែន* “សាលក្រម” តុលាការ ECtHR បណ្តឹងលេខ 21722/11, ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (“សាលក្រមរឿងក្តី Volkov”) កថាខណ្ឌ ១០៣, រឿងក្តី *Findlay ទល់នឹង ចក្រភពអង់គ្លេស* “សាលក្រម” តុលាការ ECtHR បណ្តឹងលេខ 22107/93 ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ កថាខណ្ឌ ៧៣ (សេចក្តីបញ្ជាក់បន្ថែម)។

[22] *សូមមើល ឧទាហរណ៍* ឯកសារ C11/29 “សេចក្តីសម្រេចជាសាធារណៈស្តីពីបណ្តឹងជំទាស់ជាបន្ទាន់របស់សហមេធាវីជនត្រូវចោទ នួន ជា ចំពោះលោកចៅក្រម ន័យ ថុល ដែលប្តឹងប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នក្នុងសំណុំរឿង នួន ជា” ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០០៨ កថាខណ្ឌ ១២, ២០។ សេចក្តីសម្រេចលើបណ្តឹងជំទាស់លើកទីមួយ កថាខណ្ឌ ១១។

[23] *សូមមើល* រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Sesay និងអ្នកផ្សេងទៀត* “សាលដីកាលើបណ្តឹងសាទុក្ខរបស់ Sesay, Kallon និង Gbao ប្រឆាំងនឹងសេចក្តីសម្រេចលើសំណើសុំឲ្យដកខ្លួនចេញដោយស្ម័គ្រចិត្ត ឬជំទាស់ចៅក្រម Hon. Justice Bankole Thompson

ឡើយ នៅពេលជំទាស់តវ៉ាអំពីការលេចចេញនូវភាពលម្អៀង ដូចដែលបានបញ្ជាក់យ៉ាងត្រឹមត្រូវដោយអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ SCSL នៅក្នុងរឿងក្តី *RUF*[24] ។

### *(ii) ប្រភេទនៃការលេចចេញនូវភាពលម្អៀង*

20. អនុលោមតាមអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY នៅក្នុងសំណុំរឿង *Furundžija* "ការលេចចេញនូវភាពលម្អៀងដែលមិនអាចទទួលយកបាន" កើតមានឡើង ប្រសិនបើ ៖

i) ចៅក្រមជាភាគីនៃរឿងក្តី ឬមានផលប្រយោជន៍ខាងហិរញ្ញវត្ថុ ឬមានកម្មសិទ្ធិដែលកើតចេញពីលទ្ធផលនៃរឿងក្តីនោះ ឬប្រសិនបើការសម្រេចសេចក្តីរបស់ចៅក្រម នឹងនាំឲ្យមានការគាំទ្រដល់រឿងក្តីមួយដែលរូបគាត់មានការជាប់ពាក់ព័ន្ធជាមួយភាគីណាមួយនៃរឿងក្តីនោះ។ ក្នុងកាលៈទេសៈបែបនេះ ចៅក្រមរូបនោះត្រូវដកខ្លួនចេញពីរឿងក្តីនោះ *ដោយស្វ័យប្រវត្តិ* ឬ

ii) ក្នុងកាលៈទេសៈដែលនាំឲ្យអ្នកអង្កេតឥតលម្អៀង ដែលទទួលបានព័ត៌មានត្រឹមត្រូវ យល់អំពីភាពលម្អៀងយ៉ាងសមហេតុផល[25]។

21. វាបង្ហាញឲ្យឃើញថា ការលេចចេញនូវភាពលម្អៀងដែលមិនអាចទទួលយកបាន មានពីរប្រភេទ ដែលស៊ីសង្វាក់គ្នាទៅនឹងសេចក្តីសង្កេតរបស់តុលាការកំពូលនៃប្រទេសអង់គ្លេស ក្នុងរឿងក្តី *Pinochet*[26]។ ប្រភេទទីមួយកើតឡើង នៅពេលដែលចៅក្រមគឺជាភាគីនៃរឿងក្តី ឬបើពុំដូច្នោះទេ ចៅក្រមរូបនោះមានផលប្រយោជន៍ខាងហិរញ្ញវត្ថុ ឬផលប្រយោជន៍ផ្ទាល់ខ្លួននៅក្នុងរឿងក្តីនោះ។

---

ចេញពីសំណុំរឿង RUF" សំណុំរឿងលេខ SCSL-04-15-T ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០៨ ("សាលដីកាលើបណ្តឹងសាទុក្ខក្នុងរឿងក្តី RUF") កថាខណ្ឌ ៩។

[24] *សូមមើល* សាលដីកាលើបណ្តឹងសាទុក្ខក្នុងរឿងក្តី RUF កថាខណ្ឌ ៩។ *សូមមើល ផងដែរ* កថាខណ្ឌ ២, ១២-១៣ ដែលអង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា "សូចនាមួយចំនួននៃភាពលម្អៀង" មិនគ្រប់គ្រាន់សម្រាប់ជិតចិត្តឡើយ ដោយសារតែសូចនាទាំងនោះមិនប្រឆាំងនឹងការសន្មតជាមុនអំពីអនាគតិ។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា "លក្ខខណ្ឌសម្រាប់ការលេចចេញនូវភាពលម្អៀង មិនតម្រូវឲ្យបង្ហាញភ័ស្តុតាងអំពីភាពលម្អៀងពិតប្រាកដទេ" ប៉ុន្តែ ការបង្ហាញភ័ស្តុតាងអំពីភាពលម្អៀងពិតប្រាកដទៅវិញទេ ដែលតម្រូវឲ្យមានការបដិសេធការសន្មតជាមុនអំពីអនាគតិ។

[25] សាលក្រមរឿងក្តី Furundžija កថាខណ្ឌ ១៨៩ (សេចក្តីបញ្ជាក់បន្ថែម)។

[26] *In Re Pinochet* "សាលក្រម" តុលាការកំពូលប្រទេសអង់គ្លេស ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៩ ("សាលក្រមរឿងក្តី Pinochet")។

នៅក្នុងកាលៈទេសៈបែបនេះ ចៅក្រមរូបនោះ ត្រូវដកខ្លួនចេញពីរឿងក្ដីនោះដោយស្វ័យប្រវត្តិ ហើយមិនចាំបាច់ពិភាក្សាបន្ថែមអំពីថាតើ អ្នកអង្កេតឥតលម្អៀង អាចយល់អំពីភាពលម្អៀង ឬយ៉ាងណានោះឡើយ។ ការយល់ឃើញរបស់អ្នកអង្កេតឥតលម្អៀង ចាំបាច់ត្រូវយកមកពិចារណា តែក្នុងកាលៈទេសៈដែលមានការសម្រេចអំពីការលេចចេញនូវភាពលម្អៀងប្រភេទទីពីរប៉ុណ្ណោះ។ មានន័យថា នៅពេលដែលពុំមានការជាប់ពាក់ព័ន្ធអំពីផលប្រយោជន៍ខាងហិរញ្ញវត្ថុ ឬផលប្រយោជន៍ផ្ទាល់ខ្លួនជាក់ស្ដែង ហើយភាគីកំពុងតែផ្អែកទៅលើកាលៈទេសៈនានាដើម្បីជជែកតវ៉ាថា អ្នកអង្កេតឥតលម្អៀងនឹងយល់អំពីការលេចចេញនូវភាពលម្អៀង។

22. ដើម្បីកំណត់ការលេចចេញនូវភាពលម្អៀងប្រភេទទីពីរ ភាគីមិនត្រឹមតែអាចផ្អែកទៅលើទស្សនៈរបស់ចៅក្រមដែលសម្ដែងចេញនៅខាងក្រៅបន្ទប់សវនាការ ដូចជា សុន្ទរកថា អត្ថបទសរសេរជាលាយលក្ខណ៍អក្សរ ឬការឆ្លើយឆ្លងគ្នាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចផ្អែកទៅលើសេចក្ដីសម្រេចនានារបស់ចៅក្រម ដែលបានធ្វើឡើងនៅក្នុងសំណុំរឿងបច្ចុប្បន្ននេះ ឬនៅក្នុងសំណុំរឿងផ្សេងៗទៀត ដើម្បីយកមកធ្វើជាភ័ស្ដុតាង[27]។

23. នៅពេលមានការផ្អែកទៅលើសេចក្ដីសម្រេចរបស់ចៅក្រមដើម្បីយកមកធ្វើជាភ័ស្ដុតាងអំពីភាពលម្អៀងនោះ ភាពខុសគ្នាត្រូវតែបង្ហាញឱ្យឃើញរវាងស្ថានភាពដែលសេចក្ដីសម្រេចរបស់ចៅក្រមនោះ ត្រូវរងការចោទប្រកាន់ថាជាលទ្ធផលនៃភាពលម្អៀងដែលមានជាធរមានរួចហើយ[28] និងស្ថានភាពដែលសេចក្ដីសម្រេចរបស់ចៅក្រម នោះត្រូវបានចោទប្រកាន់ថាជាហេតុផលដែលនាំឱ្យ

---

[27] ឯកសារ E55/4 សេចក្ដីសម្រេចលើបណ្ដឹងជំទាស់លើកទីមួយ កថាខណ្ឌ ១៣។ រឿងក្ដី រដ្ឋអាជ្ញា ទល់នឹង *Karemera និងអ្នកផ្សេងទៀត “សេចក្ដីសម្រេចលើសំណើរបស់* Karemera សុំជំទាស់ចៅក្រមជំនុំជម្រះ” សំណុំរឿងលេខ ICTR-98-44-T ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០៤ (“សេចក្ដីសម្រេចលើរឿងក្ដី Karemera”) កថាខណ្ឌ ១៣។ រឿងក្ដីរដ្ឋអាជ្ញា ទល់នឹង *Sesay និងអ្នកផ្សេងទៀត “សេចក្ដីសម្រេចលើ*សំណើសុំឱ្យដកខ្លួនចេញដោយស្ម័គ្រចិត្ត ឬជំទាស់ចៅក្រម Hon. Justice Bankole Thompson ចេញពីសំណុំរឿង RUF” សំណុំរឿងលេខ SCSL-04-15-T ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៧ (“សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្ដី RUF”) កថាខណ្ឌ ៦១-៦៣។

[28] *សូមមើល* ឧទាហរណ៍ សេចក្ដីសម្រេចលើរឿងក្ដី Karemera កថាខណ្ឌ ១៣ ដែលបញ្ហាចោទនោះគឺថាតើ “ការសម្រេចនានា [...] គឺ*កើតឡើង*ដោយសារការរៀបចំជាមុន ឬយ៉ាងណា” (សេចក្ដីបញ្ជាក់បន្ថែម)។

មានភាពលម្អៀងនៅពេលអនាគត[29]។

24. នៅពេលមានការផ្អែកទៅលើសេចក្ដីសម្រេចរបស់ចៅក្រមដើម្បីយកមកធ្វើជាភ័ស្ដុតាងអំពីភាពលម្អៀងដែលមានជាធរមានរួចហើយនោះ អ្វីដែលត្រូវបង្ហាញនោះគឺថា "សេចក្ដីសម្រេច គឺពិតជាឬត្រូវបានគេយល់ឃើញដោយសមហេតុផលថាកើតឡើងដោយសារបុរេវិនិច្ឆ័យប្រឆាំងនឹងអ្នកដាក់ពាក្យសុំ និងមិនពាក់ព័ន្ធទៅនឹងការអនុវត្តច្បាប់ដោយសុក្រឹត្យ [...] ឬជាសេចក្ដីសម្រេចដែលមិនពិចារណាវាយតម្លៃលើអង្គហេតុពាក់ព័ន្ធនានា"[30]។ ដំណើរការនេះ *មិន*ចាំបាច់បង្ហាញថាតើសំអាងហេតុ "អាចបង្កើតបានជាការភ័ន្ដច្រឡំផ្នែកច្បាប់" (ដែលជាកម្មវត្ថុនៃបណ្ដឹងសាទុក្ខ) ឬយ៉ាងណានោះឡើយ *ប៉ុន្តែ*ត្រូវបង្ហាញថាតើ សំអាងហេតុដែលមានការភ័ន្ដច្រឡំនោះ "អាចធ្វើឱ្យមានការយល់ឃើញដោយសមហេតុផលថាបង្កើតបានជាការលេចចេញនូវភាពលម្អៀង"[31] ដែរឬយ៉ាងណា។ វាត្រូវតែមានការកត់សម្គាល់ថា ការបង្ហាញភ័ស្ដុតាងអំពីការភ័ន្ដច្រឡំ ដែលមិនពាក់ព័ន្ធជាក់ស្ដែងទៅនឹងផ្នែកច្បាប់ ឬអង្គហេតុ មានការចាំបាច់*តែ* ក្នុងកាលៈទេសៈដែលសេចក្ដីសម្រេចរបស់ចៅក្រមដែលចោទជាបញ្ហានេះ ត្រូវបានចោទប្រកាន់ថាជាលទ្ធផលនៃភាពលម្អៀងដែលមានជាធរមានរួចហើយ*ប៉ុណ្ណោះ មិនមែន*ក្នុងកាលៈទេសៈដែលសំអាងហេតុត្រូវបានយកមកប្រើដើម្បីផ្ដល់យុត្តិកម្មអំពីក្ដីបារម្ភនៃភាពលម្អៀងនាពេលអនាគតនោះឡើយ។

25. ប្រសិនបើសេចក្ដីសម្រេចរបស់ចៅក្រម គឺជាសេចក្ដីសម្រេចដែលត្រូវធ្វើឡើងនៅក្នុងករណីបច្ចុប្បន្ននេះ ការចោទប្រកាន់អាចគ្រាន់តែជាការចោទប្រកាន់ដែលថា សេចក្ដីសម្រេចទាំងនោះគឺជាលទ្ធផលនៃភាពលម្អៀងដែលមានជាធរមានរួចហើយប៉ុណ្ណោះ។ ទោះបីជាយ៉ាងណាក៏ដោយ

---

[29] ឧទាហរណ៍ ការចោទប្រកាន់ ដែល*មិន*ផ្ដោតទៅលើសុពលភាពនៃសំអាងហេតុរបស់ចៅក្រម (ឧ. ថាតើសំអាងហេតុទាំងនោះកើតចេញមកពីភាពលម្អៀង ឬយ៉ាងណា) *ប៉ុន្តែ*ផ្ដោតទៅលើអង្គហេតុដែលសំអាងហេតុទាំងនេះ គឺជាការកំណត់ជាមុន ទៅលើបញ្ហានានានៅក្នុងរឿងក្ដីបន្តបន្ទាប់ទៀត។

[30] ឯកសារ E55/4 សេចក្ដីសម្រេចលើបណ្ដឹងជំទាស់ចៅក្រមលើកទីមួយ កថាខណ្ឌ ១៣។ រឿងក្ដី រដ្ឋអាជ្ញា ទល់នឹង *Karemera និងអ្នកផ្សេងទៀត "សេចក្ដីសម្រេចលើសំណើរបស់* Karemera សុំដិតចិត្តចៅក្រមជំនុំជម្រះ" សំណុំរឿងលេខ ICTR-98-44-T ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០៤ កថាខខណ្ឌ ១៣។ រឿងក្ដីរដ្ឋអាជ្ញា ទល់នឹង *Sesay និងអ្នកផ្សេងទៀត "សេចក្ដីសម្រេចលើ*សំណើសុំឱ្យដកខ្លួនចេញដោយស្ម័គ្រចិត្ត ឬដិតចិត្តចៅក្រម Hon. Justice Bankole Thompson ចេញពីសំណុំរឿង RUF" សំណុំរឿងលេខ SCSL-04-15-T ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៧ ("សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្ដី RUF") កថាខណ្ឌ ៦១-៦៣។

[31] សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្ដី RUF កថាខណ្ឌ ៦៣។

ប្រសិនបើសេចក្តីសម្រេចរបស់ចៅក្រមចេញមកពីករណីផ្សេងៗទៅវិញ ការចោទប្រកាន់អាច សំដៅទៅលើភាពលម្អៀងដែលមានជាធរមានរួចហើយ ឬក៏ភាពលម្អៀងនាពេលអនាគត។ នៅក្នុងបណ្តឹងនេះ មេធាវីការពារក្តីផ្អែកទៅលើ *ក្នុងចំណោមប្រការផ្សេងទៀត* សេចក្តីសម្រេច របស់ចៅក្រមនៅក្នុងសំណុំរឿង ០០២/០១ ដើម្បីសុំជិតចិត្តចៅក្រមពីសំណុំរឿង ០០២/០២។ ដូចដែលបានបញ្ជាក់នៅក្នុងផ្នែកពាក់ព័ន្ធខាងក្រោម មេធាវីការពារក្តីអះអាងថា សេចក្តីសម្រេច មួយចំនួនក្នុងចំណោមសេចក្តីសម្រេចនៃសំណុំរឿង ០០២/០១ ទាំងនេះ បង្កើតបានជាការលេច ចេញនូវភាពលម្អៀងដែលមានអត្ថិភាពរួចហើយនៅក្នុងសំណុំរឿង ០០២/០១ ដោយឡែកសេចក្តី សម្រេចផ្សេងៗទៀត ផ្តល់យុត្តិកម្មអំពីក្តីបារម្ភនៃភាពលម្អៀងនាពេលអនាគតនៅក្នុងសំណុំរឿង ០០២/០២។

### *(iii) រឿងក្តី "ជាន់គ្នា"*

26. នៅក្នុងសេចក្តីសម្រេចថ្មីៗនេះ អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ថា យុត្តិសាស្ត្រនៃ តុលាការអន្តរជាតិដទៃទៀតទទួលស្គាល់ "ការសន្និដ្ឋានជាមុនយ៉ាងមុតមាំអំពីភាពឥតលម្អៀងរបស់ ចៅក្រមដែលមានជំនាញច្បាស់លាស់ សូម្បីតែនៅក្នុងរឿងក្តីដែលមានភស្តុតាង ឬទម្រង់នៃ អង្គហេតុជាន់គ្នាក៏ដោយ" ហើយថា ការជំទាស់តវ៉ាទៅលើភាពឥតលម្អៀងរបស់ចៅក្រម ដោយ ផ្អែកទៅលើមូលដ្ឋានថា ចៅក្រមរូបនោះនឹងចូលរួមនៅក្នុង "ការជំនុំជម្រះ*ច្រំដែល*លើធាតុផ្សំ បរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ [និង] លើធាតុផ្សំអង្គហេតុនៃព្រឹត្តការណ៍ដទៃផ្សេងទៀត" តែងតែត្រូវបានបដិសេធ[32]។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ ថា យុត្តិសាស្ត្រទៅលើរឿងក្តីជាន់គ្នានេះ ត្រូវបានផ្អែកទៅលើស្ថានភាពដែលរឿងក្តីជាន់គ្នា ជាប់ ពាក់ព័ន្ធនឹងជនជាប់ចោទផ្សេងគ្នា ហើយរឿងក្តីនីមួយៗមានភស្តុតាងដាច់ដោយឡែក និងមិនជាប់ ពាក់ព័ន្ធគ្នា ចំណែកឯសំណុំរឿង ០០២/០១ និងសំណុំរឿង ០០២/០២ មានជនជាប់ចោទ និង សំណុំរឿងដដែល[33]។ យោងតាមអង្គជំនុំជម្រះតុលាការកំពូល នៅពេលដែលរឿងក្តីជាន់គ្នាមាន

---

[32] ឯកសារ E301/9/1/1/3 "សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គ ជំនុំជម្រះសាលាដំបូងលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២" ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ ("សេចក្តីសម្រេចរបស់ អជតក លើបណ្តឹងសាទុក្ខរបស់ ខៀវ សំផន") កថាខណ្ឌ ៨៣ (សេចក្តីបញ្ជាក់បន្ថែម)។

[33] ឯកសារ E301/9/1/1/3 សេចក្តីសម្រេចរបស់ អជតក លើបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៨៣។

ជនជាប់ចោទរួម និងភ័ស្តុតាងរួមតែមួយ លក្ខខណ្ឌនៃភាពឥតលម្អៀងតម្រូវថា ភ័ស្តុតាងដែលនាំឱ្យមានផលប៉ះពាល់ ដែលចៅក្រមបានជំនុំជម្រះរួចហើយនោះ ត្រូវតែដកចេញពីសំណុំរឿងក្រោយៗទៀត ឬក៏ចៅក្រមខ្លួនឯងត្រូវដកខ្លួនចេញ[34]។ ភាពខុសគ្នាដ៏សំខាន់នេះត្រូវតែយកមកពិចារណា នៅពេលចៅក្រមយកយុត្តិសាស្ត្រខាងលើនេះមកអនុវត្តលើរឿងក្តីជាន់គ្នា។

27. នៅក្នុងចម្លើយតបនាពេលថ្មីៗនេះទៅនឹងសំណើរបស់ ខៀវ សំផន ក.ស.ព បានអះអាងថា យុត្តិសាស្ត្រ របស់សហរដ្ឋអាមេរិកកំណត់ថា ការចូលរួមរបស់ចៅក្រមនៅក្នុងសវនាការជាប់ៗគ្នាប្រឆាំងនឹងជនជាប់ចោទដដែល មិនប្រាកដជាបង្កើតបានជាការលេចចេញនូវភាពលម្អៀងឡើយ[35]។ ទោះបីជាយ៉ាងណាក៏ដោយ យុត្តិសាស្ត្រដដែលនោះកំណត់ថា ការចូលរួមបែបនេះ *អាច* បង្កើតបានជាការលេចចេញនូវភាពលម្អៀង ប្រសិនបើចៅក្រមរូបនេះ ត្រូវបានរកឃើញថាមានទស្សនៈដែល "បង្ហាញឱ្យឃើញនូវអសមត្ថភាពយ៉ាងច្បាស់ក្នុងការចេញសាលក្រមមួយប្រកបដោយយុត្តិធម៌"[36]។ តុលាការសហរដ្ឋអាមេរិកក៏ពិចារណាផងដែរទៅលើពេលវេលាដែលកន្លងផុតទៅ ចាប់តាំងពីមានការលេចចេញនូវភាពលម្អៀងក្នុងពេលនោះ ដោយបញ្ជាក់ថា រយៈពេលកន្លងផុតទៅកាន់តែយូរ លទ្ធភាពនៃភាពលម្អៀងកាន់តែតិច[37]។

28. ស្រដៀងគ្នានេះដែរ តុលាការនេះ និងតុលាការអន្តរជាតិបានសម្រេចថា នៅក្នុងកាលៈទេសៈនៃរឿងក្តីជាន់គ្នា លក្ខណៈវិនិច្ឆ័យសម្រាប់ការលេចចេញនូវភាពលម្អៀងរបស់ចៅក្រម គឺថាតើ ចៅក្រមរូបនោះ "អាចមិនធ្វើការសម្រេច*ដោយអនាគតិ* និង *មិនលម្អៀង*ក្នុងការដោះស្រាយបញ្ហានានានៅក្នុងរឿងក្តីបច្ចុប្បន្នបានដែរ ឬយ៉ាងណា"[38] ហើយថា ទាក់ទិននឹងបញ្ហានេះ ត្រូវតែមានការពិចារណាទៅលើបញ្ហា *ក្នុងចំណោមប្រការផ្សេងទៀត* ថាតើចៅក្រមនឹងបើកចិត្តទូលាយដែរឬទេក្នុងការពិនិត្យទៅលើភ័ស្តុតាង និងអំណះអំណាងនានាដែលបានបង្ហាញជូននៅក្នុងរឿងក្តីបច្ចុប្បន្ន

---

[34] ឯកសារ E301/9/1/1/3 សេចក្តីសម្រេចរបស់ អជតក លើបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៨៣។

[35] ឯកសារ E314/3 "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ ខៀវ សំផន សុំផ្អាកកិច្ចដំណើរការនីតិវិធី ឬប្តឹងជំទាស់ចៅក្រម" ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៤ កថាខណ្ឌ ១៨-១៩។

[36] រឿងក្តី *Liteky និងអ្នកផ្សេងទៀត ទល់នឹង សហរដ្ឋអាមេរិក* 510 U.S. 540 ត្រង់ចំណុច 551 (1994)។

[37] រដ្ឋ *Connecticut ទល់នឹង Daniel Webb*, 238 Conn. 389 ត្រង់ចំណុច 461 (1996)។

[38] ឯកសារ E55/4 សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រមលើកទីមួយ កថាខណ្ឌ ១៥។ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Brđanin & Talić*, "សេចក្តីសម្រេចលើបណ្តឹងរបស់ Momir Talić សុំជំទាស់ចៅក្រម និងដកចៅក្រមចេញ" សំណុំរឿងលេខ IT-99-36-PT ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០០ ("សេចក្តីសម្រេចលើរឿងក្តី Brđanin") កថាខណ្ឌ ១៨-១៩ (សេចក្តីបញ្ជាក់បន្ថែម)។

និងសម្រេចទៅលើរឿងក្តី "*ដោយយុត្តិធម៌* [...] ដោយផ្អែក*យ៉ាងពេញលេញ* និង*ទាំងស្រុង*លើភ័ស្តុតាងដែលបានបង្ហាញនៅក្នុងរឿងក្តីជាក់លាក់នោះ"[39]។

### *(iv) ការបង្ហាញឱ្យឃើញនូវការពុំមាន "ចិត្តគំនិតអគតិ និងមិនលម្អៀង"*

29. យុត្តិសាស្ត្របង្ហាញថា ចិត្តចង្អៀត និងភាពលម្អៀង តែងតែង ប៉ុន្តែមិនទាំងស្រុងទេ បង្ហាញឱ្យឃើញនៅក្នុង*ការធ្វើបុរេវិនិច្ឆ័យ*ទៅលើកម្មវត្ថុនៃរឿងក្តី *ការកំណត់ជាមុន*ទៅលើបញ្ហាមួយ ឬច្រើន ដែលទាក់ទិននឹងកម្មវត្ថុនៃរឿងក្តី ឬ*ការសន្និដ្ឋានអវិជ្ជមានជាមុន*ទៅលើករណីរបស់ភាគី។

30. ***បុរេវិនិច្ឆ័យ*** ៖ ការធ្វើបុរេវិនិច្ឆ័យអំពី "ពិរុទ្ធភាពរបស់បុគ្គលម្នាក់" (ពោលគឺ កម្មវត្ថុនៃរឿងក្តីព្រហ្មទណ្ឌ) តម្រូវឱ្យដកចៅក្រមរូបនោះចេញពីរឿងក្តីព្រហ្មទណ្ឌ[40]។ ទោះបីជាយ៉ាងណាក៏ដោយ ផ្ទុយគ្នាទៅនឹងការបកស្រាយលើកមុនរបស់អង្គជំនុំជម្រះពិសេសអំពី "បុរេវិនិច្ឆ័យលើពិរុទ្ធភាព"[41] វាមិនចាំបាច់ឱ្យចៅក្រមធ្វើបុរេវិនិច្ឆ័យទៅលើគ្រប់ធាតុផ្សំទាំងអស់នៃឧក្រិដ្ឋកម្មដែលជនជាប់ចោទត្រូវបានចោទប្រកាន់នោះឡើយ។ ប៉ុន្តែ វាមានលក្ខណៈគ្រប់គ្រាន់ ប្រសិន បើចៅក្រមបានសន្និដ្ឋានទូទៅជាមុនអំពី "*គុណសម្បត្តិ* នៃ*ការជាប់ពាក់ព័ន្ធ* របស់អ្នកដាក់ពាក្យសុំ [...] *ឧក្រិដ្ឋជន ឬផ្សេងពីនេះ*"[42]។ តាមពិត នៅក្នុងរឿងក្តី *Ferrantelli និង Santangelo* តុលាការ ECtHR បានរកឃើញថា មានក្តីបារម្ភដ៏សមហេតុផលអំពីភាពលម្អៀង នៅពេលចៅក្រមរូបនោះ នៅក្នុងសេចក្តីសម្រេចកាលពីមុននៃរឿងក្តីដែលពាក់ព័ន្ធ បានហៅជនជាប់ចោទទាំងពីរនាក់នៅក្នុងរឿងក្តីបច្ចុប្បន្នថាជា "សហចារី" ដោយជនជាប់ចោទម្នាក់បានចូលរួមនៅក្នុងការប្រព្រឹត្តអំពើមនុស្សឃាត ហើយម្នាក់ទៀតបានជួយជ្រោមជ្រែង ទោះបីជាពុំមានការកំណត់ជាមុនអំពីធាតុផ្សំអត្តនោម័តរបស់ពួកគេ ឬធាតុផ្សំផ្សេងទៀតនៃឧក្រិដ្ឋកម្មក៏ដោយ[43]។

---

[39] រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Akayesu* សាលដីកា សំណុំរឿងលេខ ICTR-96-4-A ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០១ ("សាលដីការឿងក្តី Akayesu") កថាខណ្ឌ ២៦៩, សាលក្រមរឿងក្តី Nahimana កថាខណ្ឌ ៧៨ (សេចក្តីបញ្ជាក់បន្ថែម)។

[40] រឿងក្តី *Poppe ទល់នឹង ប្រទេសហូឡង់ "សាលក្រម" តុលាការ* ECtHR បណ្តឹងលេខ 32271/04 ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៩ ("សាលក្រមរឿងក្តី Poppe") កថាខណ្ឌ ២៦។

[41] សូមមើល ឯកសារ E55/4 សេចក្តីសម្រេចលើបណ្តឹងជំទាស់ដិតចិត្តលើកទីមួយ កថាខណ្ឌ ២១, ២៤។

[42] សាលក្រមរឿងក្តី Poppe កថាខណ្ឌ ២៨ (សេចក្តីបញ្ជាក់បន្ថែម)។

[43] រឿងក្តី *Ferrantelli និង Santangelo ទល់នឹង ប្រទេសអ៊ីតាលី* "សាលក្រម" តុលាការ ECtHR បណ្តឹងលេខ 19874/92 ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៦ កថាខណ្ឌ ៥៩-៦០។

31. ***ការកំណត់ជាមុន*** ៖ ការធ្វើបុរេវិនិច្ឆ័យអំពីកម្មវត្ថុនៃរឿងក្តី គឺមិនមែនជាសេណារីយ៉ូតែមួយគត់ ដែលអ្នកអង្កេតឥតលម្អៀងអាចយល់អំពីភាពលម្អៀងនោះឡើយ។ តាមពិត ការកំណត់ជាមុន លើបញ្ហា ដែលទាក់ទិននឹងកម្មវត្ថុនៃរឿងក្តី ក៏អាចបង្កើតបានជាការលេចចេញនូវភាពលម្អៀងផង ដែរ។ ដូចដែល Justice Buergenthal បានពន្យល់នៅក្នុងមតិភាគតិចរបស់គាត់នៅក្នុងរឿងក្តី *Palestinian Wall* ទោះបីជាចៅក្រមមិនបានបញ្ចេញមតិណាមួយទៅលើកម្មវត្ថុនៃរឿងក្តីនោះក៏ដោយ ក៏អនាគតិរបស់ចៅក្រមត្រូវបានលើកយកមកជជែកតវ៉ាដែរ ប្រសិនបើចៅក្រមរូបនោះ "អាចត្រូវបានសន្មតថាបានធ្វើបុរេវិនិច្ឆ័យលើបញ្ហាមួយ ឬច្រើនដែលទាក់ទិននឹងកម្មវត្ថុនៃរឿងក្តី"[44]។ "បញ្ហា" នៅក្នុងន័យនេះ អាចរួមបញ្ចូលទាំង *ក្នុងចំណោមប្រការផ្សេងទៀត* "បរិបទ"នៃជម្លោះ និង "ទឡ្ហីករណ៍" ដែលអាចត្រូវបានលើកឡើងដោយភាគី ជាពិសេស "*សុពលភាព* និង *ភាពអាចជឿទុកចិត្តបាន*នៃទឡ្ហីករណ៍របស់ភាគីទាំងនេះ"[45]។

32. ***ការសន្និដ្ឋានជាមុន*** ៖ ការសន្និដ្ឋានជាមុន "ដោយទស្សនៈអវិជ្ជមានទៅលើករណី [របស់ភាគី]" នឹងបង្កើតបានជាក្តីបារម្ភដ៏សមហេតុផលអំពីភាពលម្អៀង[46]។ ជាឧទាហរណ៍ ទស្សនៈអវិជ្ជមានបែបនេះអាចបង្ហាញថា ទឡ្ហីករណ៍ ឬការពន្យល់អំពីព្រឹត្តិការណ៍នានារបស់ភាគី គឺ "មិនត្រឹមត្រូវ"[47]

---

[44] *សូមមើល* *Legal Consequences of the Construction of a Wall in the Occupied Palestinian Territory* ("ជញ្ជាំងក្នុងប្រទេសប៉ាឡេស្ទីន (*Palestinian Wall)*") យោបល់ជំទាស់របស់ចៅក្រម Buergenthal ទៅលើ "ដីកាសម្រេច ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៤", 2004 ICJ Rep. 7 ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៤ ("មតិយោបល់របស់ Buergenthal") កថាខណ្ឌ ១១, ១៣។

[45] មតិយោបល់របស់ Buergenthal កថាខណ្ឌ ១៣ (សេចក្តីបញ្ជាក់បន្ថែម)។

[46] រឿងក្តី *Buscemi ទល់នឹង ប្រទេសអ៊ីតាលី "សាលក្រម" តុលាការ* ECtHR បណ្តឹងលេខ 29569/95 ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ១៩៩៩ ("សាលក្រមរឿងក្តី Buscemi") កថាខណ្ឌ ៦៨។ រឿងក្តី *Kyprianou ទល់នឹង Cyprus* តុលាការ ECtHR បណ្តឹងលេខ 73797/01 ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៥ ("សាលក្រមរឿងក្តី Kyprianou") កថាខណ្ឌ ១២០។ *សូមមើល ផងដែរ* មតិយោបល់របស់ Buergenthal កថាខណ្ឌ ១៣។ មានការកត់សម្គាល់ថា មតិភាគច្រើន ខុសពីមតិយោបល់របស់ Justice Buergenthal ពីព្រោះតែពួកគាត់ប្រកាន់នូវទស្សនៈត្រង់ៗ និងចង្អៀតមែនទែន ទៅលើការបកស្រាយមាត្រា ១៧(២) នៃលក្ខន្តិកៈរបស់តុលាការ ICJ ដែលកម្រិតការដិតចិត្តចៅក្រមត្រឹមស្ថានភាពដែលចៅក្រមរូបនោះ "ធ្លាប់បានចូលរួមពីមុន" នៅក្នុងរឿងក្តីតែមួយ នៅក្នុងតួនាទីអ្វីក៏ដោយ (*សូមមើល* កថាខណ្ឌ ៩) ចំណែកឯ Justice Buergenthal មានទស្សនៈទូលំទូលាយជាងនេះ ហើយគាត់ជឿជាក់ថា ការដិតចិត្តចៅក្រម មានវិសាលភាពរហូតទៅដល់ការបំពានលើ "ក្រមសីលធម៌តុលាការ" គ្រប់ប្រភេទទាំងអស់ (សូមមើល កថាខណ្ឌ ៩, ១៤)។ ទស្សនៈរបស់គាត់ គឺដូចគ្នាទៅនឹងវិធីសាស្ត្រដែលអនុវត្តនៅ អ.វ.ត.ក និងតុលាការអន្តរជាតិផ្សេងៗទៀត។

[47] សាលក្រមរឿងក្តី Buscemi កថាខណ្ឌ ៤០។

ជាការបំភាន់[48] ឬមានឫសគល់ចេញពីយុទ្ធសាស្ត្រ[49]។

## គ. ការដាក់ទាន់ពេលវេលានូវបណ្ដឹងជំទាស់

33. វិធាន ៣៤(៣) នៃវិធានផ្ទៃក្នុង តម្រូវឱ្យបណ្ដឹងជំទាស់ត្រូវធ្វើឡើង "ឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន នៅពេលណាដែលភាគីបានដឹងអំពីមូលហេតុនោះ"។ អនុលោមតាមវិធាន ៣៤(៤) បណ្ដឹងជំទាស់ចៅក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវតែធ្វើឡើង "ពាក់ព័ន្ធទៅនឹងបញ្ហាមុនពេលជំនុំជម្រះ យ៉ាងយូរបំផុត នៅពេលសវនាការដំបូង ឬពាក់ព័ន្ធទៅនឹងបញ្ហាកើតឡើងក្នុងអំឡុងពេលជំនុំជម្រះ ឬកាលណាភាគីមិនបានដឹងនៅមុនពេលជំនុំជម្រះ នៅមុនពេលធ្វើសេចក្ដីសម្រេចចុងក្រោយលើសំណុំរឿងនោះ"។

34. ទាក់ទិននឹងបញ្ហានេះ អង្គបុរេជំនុំជម្រះធ្លាប់បានសម្រេចថា ភាគីអាចបង្ហាញភ័ស្ដុតាងកាលពីអតីតកាលដើម្បី "ពន្យល់ ឬគាំទ្របន្ថែមទៀត" ដល់ភ័ស្ដុតាងថ្មី ប្រសិនបើភ័ស្ដុតាងកាលពីអតីតកាលនោះជាប់ពាក់ព័ន្ធផ្នែកបរិបទ ដែលជាលទ្ធផលនៃព្រឹត្តិការណ៍ថ្មីៗ[50]។

# IV. ទង្វីករណ៍

## ក. បណ្ដឹងនេះបានដាក់ទាន់ពេល ដូច្នេះអាចទទួលយកបាន

35. មេធាវីការពារក្ដីស្នើសុំជំទាស់ចៅក្រមពីសំណុំរឿង ០០២/០២ និងការជំនុំជម្រះបន្តបន្ទាប់ទៀតលើ នួន ជា ដោយផ្អែកទៅលើបញ្ហានានាដែលកើតចេញពីសាលក្រមសំណុំរឿង ០០២/០១ និងសេចក្ដីសម្រេចស្ដាពរស្ដីពីសាក្សី។ សាលក្រម និងសេចក្ដីសម្រេចទាំងពីរនេះ បានចេញនៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ រយៈពេលមួយសប្ដាហ៍ បន្ទាប់ពីសវនាការបឋមក្នុង សំណុំរឿង ០០២/០២ នៅថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៤។ នៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៤ បន្ទាប់ពីធ្វើការពិនិត្យជាបឋមទៅលើសេចក្ដីសម្រេចទាំងពីរនេះរួចមក មេធាវីការពារក្ដីបានជូនដំណឹងទៅអង្គជំនុំជម្រះ

---

[48] សាលក្រមរឿងក្ដី Buscemi កថាខណ្ឌ ៤១ ដែលនៅក្នុងនោះ ចៅក្រមរូបនោះបានហៅម្ចាស់បណ្ដឹងថាជា "មនុស្សកុហក"។

[49] *សូមមើល*មតិយោបល់របស់ Buergenthal កថាខណ្ឌ ៨ ៖ ចៅក្រម Elaraby បានបញ្ចេញទស្សនៈជាសាធារណៈថា អ៊ីស្រាអែល កំពុងប្រើយុទ្ធសាស្ត្រដើម្បី "ធ្វើឱ្យចំណុចជម្លោះអ៊ីស្រាអែល-អារ៉ាប់ ជារឿងបន្ទាប់បន្សំ"។

[50] ឯកសារ ៧ "សាលដីកាលើបណ្ដឹងជំទាស់របស់ ខៀវ សំផន ចំពោះសហចៅក្រមស៊ើបអង្កេត Marcel Lemonde" ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ ("សាលដីកាលើបណ្ដឹងជំទាស់របស់ ខៀវ សំផន ចំពោះ Lemonde") កថាខណ្ឌ ២០។

សាលាដំបូងថា មេធាវីការពារក្តីមានបំណងដាក់បណ្តឹងជំទាស់នេះ។ បន្ទាប់ពីនោះមក មេធាវីការពារក្តីខំប្រឹងរួសរាន់ដាក់បណ្តឹងជំទាស់នេះ នៅទន្ទឹមពេលគ្នាដែលមេធាវីការពារក្តីក៏ចំណាយពេលផងដែរ ក្នុងការរៀបចំសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០១ ដែលបានរកឃើញមូលដ្ឋានចំនួន ២២៣ផ្សេងគ្នាក្នុងការប្តឹងសាទុក្ខដែលបានដាក់ក្នុងពេលជាមួយគ្នានឹងបណ្តឹងជំទាស់នេះ។

36. ដោយផ្អែកលើអំណះអំណាងខាងលើ មេធាវីការពារក្តីអះអាងថា ដោយសារតែបញ្ហានានាដែលបង្កើតឱ្យមានបណ្តឹងជំទាស់នេះ បានកើតឡើង បន្ទាប់ពីសវនាការបឋមសំណុំរឿង ០០២/០២ នោះ អនុលោមតាមវិធាន ៣៤(៣) និង (៤)(គ) នៃវិធានផ្ទៃក្នុង បណ្តឹងជំទាស់នេះត្រូវចាត់ទុកថាដាក់ទាន់ពេលវេលា និងអាចទទួលយកបាន ពីព្រោះបណ្តឹងនេះត្រូវបានធ្វើឡើង នៅពេលដែលមេធាវីការការពារក្តីបានដឹងភ្លាមៗអំពីបញ្ហាទាំងនោះ និងនៅមុនពេលសេចក្តីសម្រេចចុងក្រោយនៅក្នុងសំណុំរឿង ០០២/០២។

37. លើសពីនេះទៀត មេធាវីការពារក្តីមានសិទ្ធិបង្ហាញភ័ស្តុតាងកាលពីអតីតកាល ដូចជា សៀវភៅរបស់ Lemonde និងសុន្ទរកថានៅឯ Aspen ដើម្បី "ពន្យល់ និងគាំទ្របន្ថែមទៀត" ដល់ភ័ស្តុតាងថ្មីនៅពេលដែលភ័ស្តុតាងកាលពីអតីតកាល ជាប់ពាក់ព័ន្ធតែផ្នែកបរិបទទៅនឹងបណ្តឹងនេះ ដែលជាលទ្ធផលនៃព្រឹត្តិការណ៍ថ្មីៗ[51] (ពោលគឺការចេញសាលក្រមសំណុំរឿង ០០២/០១ និងសេចក្តីសម្រេចស្តាពរស្តីពីសាក្សី)។

## ខ. ការបដិសេធរបស់ចៅក្រមជាតិមិនកោះហៅ ហេង សំរិន បង្ហាញដល់ការបង្ហាញឱ្យឃើញនូវឯកភាពរបស់ ឬបង្កើតឱ្យមានការលេចចេញនូវភាពលម្អៀង

38. នៅក្នុងសេចក្តីសម្រេចស្តាពរស្តីពីសាក្សី ចៅក្រមជាតិបានបដិសេធមិនកោះហៅ ហេង សំរិន នៅក្នុងសំណុំរឿង ០០២/០១ ដោយលើកឡើងអំពី "ភាពលំបាកលំបិន"[52] ដែលបណ្តាលមកពីការដក "អភ័យឯកសិទ្ធិ" ដែលតាមសម្មតិកម្មនាំឱ្យមានការពន្យារពេលយូរ[53] "ភាពច្រំដែល"

---

[51] ឯកសារ 7 សាលដីកាលើបណ្តឹងជំទាស់របស់ ខៀវ សំផន ចំពោះ Lemonde កថាខណ្ឌ ២០។

[52] ឯកសារ E312 សេចក្តីសម្រេចស្តាពរស្តីពីសាក្សី កថាខណ្ឌ ៩៧។

[53] ឯកសារ E312 សេចក្តីសម្រេចស្តាពរស្តីពីសាក្សី កថាខណ្ឌ ៩៧។

នៃសក្ខីកម្មរបស់គាត់អំពីអង្គហេតុ[54] និងភាពមិនស្មោះត្រង់យ៉ាងច្បាស់របស់មេធាវីការពារក្ដីក្នុងការស្នើសុំឱ្យគាត់ធ្វើជាសាក្សីអត្ថចរិតតែម្នាក់គត់របស់ នួន ជា ជាបញ្ហានៃ "យុទ្ធសាស្ត្រក្នុងការជំនុំជម្រះ [...] ដើម្បីធ្វើឱ្យមានភាពច្របូកច្របល់"[55]។

39. នៅក្នុងរឿងក្ដី ០០២/០១ ហេង សំរិន មិនត្រឹមតែជាសាក្សីអត្ថចរិតតែម្នាក់គត់ និងអង្គហេតុដ៏សំខាន់បំផុតសម្រាប់ នួន ជា ប៉ុណ្ណោះទេ ប៉ុន្តែគាត់ក៏ជាសាក្សីដ៏សំខាន់បំផុតតែម្នាក់គត់ជាទូទៅផងដែរ[56]។ គាត់អាចផ្ដល់ជូននូវភ័ស្តុតាងផ្ទាល់ពិសេស ដែលទំនងជានាយទាហានជាន់ខ្ពស់បំផុតរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលនៅរស់រានមានជីវិតចូលរួមក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ ដូច្នេះ គាត់អាចជួយឱ្យតុលាការយល់ដឹងច្បាស់អំពីបញ្ហានានា រួមមានការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងការចោទប្រកាន់អំពីការសម្លាប់រង្គាល និងគោលនយោបាយធ្វើទុក្ខបុកម្នេញរបស់បក្សកុម្មុយនីស្តកម្ពុជា សំខាន់បំផុតគឺការចោទប្រកាន់អំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការសម្លាប់អ្នករដ្ឋការ និងទាហានរបបសាធារណរដ្ឋខ្មែរជាទូទៅ និងជាពិសេសនៅទួលពោធិ៍ជ្រៃ។ ផ្ទុយទៅវិញ សម្រាប់បញ្ហាទាំងនេះ សាលក្រមសំណុំរឿង ០០២/០១ បានផ្អែកទៅលើសក្ខីកម្មរបស់ទាហានតូចតាចបំផុត[57] និងអ្នកជំនាញ ចំណែកឯចៅក្រមជាតិបានសន្និដ្ឋានថា វាមានលក្ខណៈគ្រប់គ្រាន់ហើយក្នុងការផ្អែកទៅលើកិច្ចសម្ភាសន៍របស់បណ្ឌិតសាស្ត្រាចារ្យនានាជាមួយ ហេង សំរិន ដោយមិនបានផ្ដល់ឱកាសឱ្យភាគីតទល់ជាមួយគាត់[58]។ ផលវិបាកនៃស្ថានភាពបែបនេះ ត្រូវគ្នាទៅនឹងការពិពណ៌នារបស់ចៅក្រម Christine Van den Wyngaert ដែលបានលើកឡើងនៅក្នុងមតិភាគតិចរបស់លោកស្រី ពាក់ព័ន្ធនឹងរឿងក្ដី *Katanga* របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ៖

---

[54] ឯកសារ E312 សេចក្ដីសម្រេចស្ដាពរស្ដីពីសាក្សី កថាខណ្ឌ ៩៣។

[55] ឯកសារ E312 សេចក្ដីសម្រេចស្ដាពរស្ដីពីសាក្សី កថាខណ្ឌ ១១៧។

[56] មេធាវីការពារក្ដីបានបញ្ជាក់ទៅលើជំហរនេះយ៉ាងវែង។ *សូមមើល ឧទាហរណ៍* ឯកសារ E236/5/1/1 "សំណើលើកទី៦ និងចុងក្រោយសុំកោះហៅសាក្សី TCW-223" ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៣ (សំណើលើកទី៦ កោះហៅ ហេង សំរិន) និងឯកសារ E295/6/3 "សារណាបញ្ចប់ការពិភាក្សាដេញដោលរបស់ នួន ជា ក្នុងសំណុំរឿង ០០២/០១" ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ ("សារណាបញ្ចប់ការពិភាក្សាដេញដោលរបស់ មេធាវីការពារក្ដី ក្នុងសំណុំរឿង ០០២/០១")។

[57] ឧទាហរណ៍ពីរគឺ សាក្សី ស៊ុំ ជា ដែលទំនងជាមានឋានន្តរសក្ដិទាបបំផុត (ជាទាហានធម្មតា) និងសាក្សី គង់ គីម ដែលមានឋានន្តរសក្ដិទាបបំផុតនៅលំដាប់បន្ទាប់ គឺត្រឹមតែជាប្រធានកងតូច។

[58] ឯកសារ E312 សេក្ដីសម្រេចស្ដាពរស្ដីពីសាក្សី កថាខណ្ឌ ៩៨, ១០២។

ការពុំមានភស្តុតាងសោះពី *បុគ្គលទាំងឡាយណាដែលជាតួអង្គសំខាន់នៃព្រឹត្តិការណ៍នានា* នៅពេលនោះប្រាកដជានាំឲ្យមានការយល់ឃើញថា *ព័ត៌មានសំខាន់*កំពុងតែបាត់ចេញពីកំណត់ហេតុ [...ហើយអាចនាំឲ្យគេ] ឆ្ងល់ថាតើ វាអាចឈានទៅដល់លក្ខខណ្ឌតម្រូវដែរឬទេ [...] នៅពេលដែលមានការបង្ហាញច្បាស់ថា *ភស្តុតាងបន្ថែមទៀត និងប្រសើរជាងនេះ*អាចនាំឲ្យមាន *ចម្លើយខុសគ្នាច្រើន*យ៉ាងពិតប្រាកដ[59]។

40. ហេង សំរិន គឺប្រាកដណាស់នៅតែជាសាក្សីដ៏សំខាន់បំផុតនៅក្នុងសំណុំរឿង ០០២/០២ និងសំណុំរឿង ០០២ ជាទូទៅ។ តាមពិត ក្នុងនាមជាឥស្សរជនជាន់ខ្ពស់ម្នាក់នៅក្នុងក្រុមបក្សកុម្មុយនីស្តកម្ពុជា ដែលគាំទ្រដោយវៀតណាមដែលបានធ្វើការប្រឆាំង និងចុងក្រោយបានផ្ដួលរំលំក្រុមដែលដឹកនាំដោយ ប៉ុល ពត និង នួន ជា នៅក្នុងសំណុំរឿង ០០២/០២ ហេង សំរិន នឹងអាចផ្ដល់ជូននូវភស្តុតាងផ្ទាល់ពិសេសអំពី *ក្នុងចំណោមប្រការផ្សេងទៀត* ផ្ទៃក្នុងរបស់បក្សកុម្មុយនីស្តកម្ពុជា និងការបោសសំអាតផ្ទៃក្នុងនៅក្នុងភូមិភាគបូព៌ា ជម្លោះប្រដាប់អាវុធជាមួយវៀតណាម និងជំនួយពីក្រុមបក្សកុម្មុយនីស្តកម្ពុជាដែលរត់ចេញពីប្រទេស និងការចោទប្រកាន់អំពីប្រល័យពូជសាសន៍ជនជាតិវៀតណាម និងជានជាតិចាមនៅក្នុងភូមិភាគបូព៌ា។

### *(i) ការបំផ្លាញនូវការបង្ហាញឲ្យឃើញនូវឯករាជ្យភាព*

41. ដោយសារតែ ហេង សំរិន គឺជាសាក្សីដ៏សំខាន់បំផុតនេះហើយ ទើបមេធាវីការពារក្ដីជានិច្ចកាល និងម្ដងហើយម្ដងទៀតបានស្នើសុំកោះហៅរូបគាត់ ឬស៊ើបអង្កេតទៅលើបញ្ហាដែលពាក់ព័ន្ធនានា នៅដំណាក់កាលមុនជំនុំជម្រះក្ដី[60] និង (ប្រាំមួយដង) នៅដំណាក់កាលជំនុំជម្រះ[61]។ ចៅក្រមអន្តរជាតិនីមួយៗដែលបានទទួលសំណើទាំងនេះ យល់ឃើញថា សំណើទាំងនេះមានសារៈសំខាន់[62]។

---

[59] រឿងក្ដីរដ្ឋអាជ្ញា ទល់នឹង *Katanga* សំណុំរឿងលេខ ICC-01/04-01/07 "មតិភាគតិចរបស់ចៅក្រម Christine Van den Wyngaert" ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១៤ ("មតិរបស់ Van den Wyngaert Katanga Opinion") កថាខណ្ឌ ១៤៨-១៤៩ (សេចក្ដីបញ្ជាក់បន្ថែម)។

[60] *សូមមើល ឧទាហរណ៍* ឯកសារ E314/2/7 "សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី និងលោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឲ្យកោះហៅសាក្សី" ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១០ *ដកស្រង់ នៅក្នុង*ឯកសារ E312 សេចក្ដីសម្រេចស្ដាពរស្ដីពីសាក្សី ជើងទំព័រ ១៥៨។

[61] សម្រាប់សេចក្ដីសង្ខេបនៃប្រវត្តិនីតិវិធីនៃសំណើទាំងនេះ *សូមមើល* សំណើលើកទី៦ កោះហៅ ហេង សំរិន កថាខណ្ឌ ៣-៨។

[62] ទាក់ទិននឹងសហចៅក្រមស៊ើបអង្កេត Lemonde *សូមមើល ឧទាហរណ៍* ឯកសារ E312 សេចក្ដីសម្រេចស្ដាពរស្ដីពីសាក្សី កថាខណ្ឌ ៩០ និងឯកសារ 189/3/1/7.1.3 'Un Juge Face aux Khmers Rouges' ទំព័រ 172 (ដែលនៅក្នុងនោះ ចៅក្រម

នៅក្នុងឆ្នាំ ២០០៩ ចៅក្រម Lemonde បានកោះហៅ ហេង សំរិន ក្នុងគោលបំណងដើម្បីសម្ភាសន៍គាត់ ដោយបានផ្តល់យោបល់ថា ការសម្ភាសន៍រូបគាត់ នឹង "នាំទៅរកការបង្ហាញការពិត"[63]។ នៅក្នុងឆ្នាំ ២០១០ ចៅក្រម Downing និងចៅក្រម Marchi-Uhel បានបញ្ចេញយោបល់ថា "ការរារាំងមិនឱ្យមានការផ្តល់សក្ខីកម្មពីសាក្សីដែលត្រូវបានចាត់ទុកថាអាចនាំទៅរកការបង្ហាញការពិត អាចរំលោភលើភាពត្រឹមត្រូវនៃការជំនុំជម្រះក្តី"[64]។ ក្នុងឆ្នាំ ២០១៤ នាពេលថ្មីៗនេះ ចៅក្រម Cartwright និងចៅក្រម Lavergne យល់ឃើញថា សក្ខីកម្មសក្តានុពលរបស់ ហេង សំរិន គឺ "*តាមការវិភាគបឋម*ពិតជាជាប់ពាក់ព័ន្ធ និងអាចជួយដល់អង្គជំនុំជម្រះក្នុងការបញ្ជាក់ការពិត" និងអាចមាន "ព័ត៌មានដែលសាក្សីផ្សេងទៀត ដែលបានស្នើសុំមិនអាចដឹងព័ត៌មាននេះ នៅក្នុងសំណុំរឿង ០០២/០១"[65]។

42. ផ្ទុយគ្នាទៅនឹងគោលជំហររបស់ចៅក្រមអន្តរជាតិ ចៅក្រមជាតិនីមួយៗដែលបានទទួលសំណើរបស់មេធាវីការពារក្តី បានបដិសេធសំណើទាំងនោះ ៖ ទាំងចៅក្រមស៊ើបអង្កេត ចៅក្រមអង្គបុរេជំនុំជម្រះ និងចៅក្រមអង្គជំនុំជម្រះសាលាដំបូង ដូចគ្នាទាំងអស់[66]។ ដោយពិចារណាទៅលើប្រវត្តិ

---

Lemonde បានហៅ ហេង សំរិន ថា "qu'il nous fallait absolument interroger" ដកស្រង់នៅក្នុងសំណើលើកទី៦ កោះហៅ ហេង សំរិន ជើងទំព័រ ១០)។ ទាក់ទិននឹងចៅក្រមអង្គបុរេជំនុំជម្រះ គឺចៅក្រម Downing និងចៅក្រម Marchi-Uhel *សូមមើល ឧទាហរណ៍* ឯកសារ D314/1/12 "សាលដីកាលើកទីពីរលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី និងលោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឱ្យកោះហៅសាក្សី" ("សាលដីកាលើកទី២ របស់ អបជ ស្តីអំពីសាក្សី") ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១០ (ទោះបីជាសំណៅកែសលុបជាសាធារណៈនៃសេចក្តីសម្រេចនេះ មិនយោងទៅលើអត្តសញ្ញាណរបស់សាក្សីក៏ដោយ ប៉ុន្តែជាក់ស្តែង សេចក្តីសម្រេចស្តាពរស្តីពីសាក្សី បានធ្វើការយោង ៖ *សូមមើល* ឯកសារ E312 សេចក្តីសម្រេចស្តាពរស្តីពីសាក្សី កថាខណ្ឌ ៩១ និងជើងទំព័រ ១៥៨)។ ទាក់ទិននឹង ចៅក្រមអង្គជំនុំជម្រះសាលាដំបូង គឺចៅក្រម Cartwright និងចៅក្រម Lavergne *សូមមើល* ឯកសារ E312 សេចក្តីសម្រេចស្តាពរស្តីពីសាក្សី កថាខណ្ឌ ១០៥-១១១ និង ១១៩-១២០។

[63] ឯកសារ E136/3/1 "លិខិតផ្ញើជូនសម្តេច ហេង សំរិន" ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រ ១។

[64] ឯកសារ E314/1/12 សាលដីកាលើកទី២ របស់ អបជ ស្តីអំពីសាក្សី កថាខណ្ឌ ១២ (នៃមតិភាគតិច)។

[65] ឯកសារ E312 សេចក្តីសម្រេចស្តាពរស្តីពីសាក្សី កថាខណ្ឌ ១០៨។

[66] ទាក់ទិននឹងចៅក្រមស៊ើបអង្កេត ប៊ុនឡេង *សូមមើល ឧទាហរណ៍* ឯកសារ D314/1/12 សាលដីកាលើកទី២ របស់ អបជ ស្តីអំពីសាក្សី កថាខណ្ឌ ៩០-៩១។ ទាក់ទិននឹង ចៅក្រមអង្គបុរេជំនុំជម្រះ គឺចៅក្រម គឹមសាន ចៅក្រម ជុល និងចៅក្រម វុទ្ធី *សូមមើល ឧទាហរណ៍* ឯកសារ D314/1/12 សាលដីកាលើកទី២ របស់ អបជ ស្តីអំពីសាក្សី។ ទាក់ទិននឹងចៅក្រមអង្គជំនុំជម្រះសាលាដំបូង គឺចៅក្រម ណុន ចៅក្រម សុខន និងចៅក្រម ឧត្តរា *សូមមើល* ឯកសារ E312 សេចក្តីសម្រេចស្តាពរស្តីពីសាក្សី កថាខណ្ឌ ៨៧-៩៧, ១០១-១០៣ និង ១១៦-១២០។

នីតិវិធីនេះ ភាពមិនចុះសម្រុងគ្នារបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសេចក្តីសម្រេចស្តាពរស្តីពីសាក្សីក្នុងការកោះហៅ ហេង សំរិន បញ្ជាក់អំពីអត្ថិភាពនៃភាពដាច់ចេញពីគ្នាជាងដែល និងយ៉ាងច្បាស់ក្រឡែត រវាងចៅក្រមជាតិ និងចៅក្រមអន្តរជាតិទៅលើបញ្ហានេះ។ លើសពីនេះទៀត មេធាវីការពារក្តីអះអាងថា នៅពេលធ្វើការពិចារណាជាមួយនឹងបញ្ហាខាងក្រោមនេះ សេចក្តីសម្រេចនោះបង្ហាញថា ចៅក្រមជាតិគ្មាន "បង្ហាញឱ្យឃើញនូវឯករាជ្យភាព" ដើម្បីនៅជាចៅក្រមលើសំណុំរឿង ០០២/០២[67]។

43. ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកម្ពុជា តែងតាំងចៅក្រមជាតិទាំងអស់ រួមទាំងនៅ អ.វ.ត.ក ផងដែរ និងទទួលបន្ទុកក្នុងការដាក់វិន័យ បណ្តេញចេញ និងតំឡើងឋានន្តរសក្តិ[68]។ សមាជិកនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម រួមមាន អ្នកដែលត្រូវបានតែងតាំងបួនរូបដោយអង្គនីតិប្រតិបត្តិ[69] ព្រមទាំង អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល និងប្រធានសាលាឧទ្ធរណ៍ ជា លាង និង យូ ប៊ុនឡេង ដែលត្រូវបានតែងតាំងបន្ថែមទៀតឱ្យបំពេញការងារនៅ អ.វ.ត.ក ជាសហព្រះរាជអាជ្ញាជាតិ និងសហចៅក្រមស៊ើបអង្កេតជាតិ។ ចៅក្រមជាតិក៏ត្រូវបានតែងតាំងបន្ថែមទៀតផងដែរ ដោយចៅក្រម ណុន កំពុងបន្តកាន់តួនាទីរបស់ខ្លួនជាប្រធានតុលាការខេត្តសៀមរាប និងចៅក្រម សុខន និងចៅក្រម ឧត្តរា មានតួនាទីជាចៅក្រមតុលាការកំពូល[70] រួមជាមួយនឹងតួនាទីរបស់ពួកគាត់នៅ អ.វ.ត.ក ហើយទទួលបានប្រាក់ខែពេញម៉ោងផ្សេងគ្នាសម្រាប់តួនាទីនីមួយៗ។

44. ជាទូទៅ ចៅក្រមកម្ពុជាពុំមានសុវត្ថិភាពផ្នែកមុខតំណែង ទទួលបានប្រាក់ខែតិចតួច និងបើយោងទៅលើរបាយការណ៍ទូទៅរបស់អ្នកសង្កេតការណ៍អង្គការក្រៅរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ ចៅក្រមកម្ពុជាជិតដាមទៅដោយការចោទប្រកាន់អំពីអំពើពុករលួយ[71] ឯករាជ្យភាព

---

[67] សាលក្រមរឿងក្តី Volkov កថាខណ្ឌ ១០៣។

[68] ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឆ្នាំ ១៩៩៤ មាត្រា ១, ១១។

[69] រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងចៅក្រមបីរូប ដែលគាត់តែងតាំង ៖ *សូមមើល* មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "Fact Sheet: ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម" ខែ កុម្ភៈ ឆ្នាំ ២០១២ ទំព័រ ១។

[70] អ.វ.ត.ក "នរណាខ្លះនៅក្នុងបន្ទប់សវនការ" ("តើនរណាខ្លះ") ឆ្នាំ ២០១៤, http://www.cccc.gov.kh/cn/who-is-who.

[71] *សូមមើល ឧទាហរណ៍* អង្គការតម្លាភាពអន្តរជាតិ កម្ពុជា "អំពើពុករលួយ និងប្រព័ន្ធអភិបាលកិច្ចប្រទេសកម្ពុជា ៖ តម្រូវការសម្រាប់កំណែទម្រង់" ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១៤ ("របាយការណ៍អំពីអំពើពុករលួយរបស់អង្គការតម្លាភាពអន្តរជាតិកម្ពុជា") ទំព័រ ៥២-៦៧។ តាមពិត សហមេធាវី អៀង សារី ធ្លាប់បរាជ័យក្នុងការដាក់បណ្តឹងជិតចិត្តចំពោះចៅក្រម ណុន

មានកម្រិត និងការតែងតាំងដោយអង្គនីតិប្រតិបត្តិ[72]។ ពាក់ព័ន្ធនឹងអំពើពុករលួយជាពិសេស អង្គការតម្លាភាពអន្តរជាតិ (Transparency International) បានចេញរបាយការណ៍របស់ខ្លួននៅក្នុងខែនេះ ស្តីអំពីអំពើពុករលួយនៅក្នុងប្រព័ន្ធអភិបាលកិច្ចប្រទេសកម្ពុជា ដែលបានវាយតម្លៃអំពីសុចរិតភាពនៃស្ថាប័នអភិបាលកិច្ចសំខាន់ចំនួន ១៣ (រួមមាន *ក្នុងចំណោមស្ថាប័នផ្សេងទៀត* អង្គនីតិប្រតិបត្តិ អង្គនីតិបញ្ញត្តិ ស្ថាប័នតុលាការ វិស័យសាធារណៈ និងគណបក្សនយោបាយ) និងបានរកឃើញថា ក្នុងចំណោមស្ថាប័នសំខាន់ទាំង ១៣ ស្ថាប័នតុលាការប្រទេសកម្ពុជាគឺខ្សោយជាងគេបំផុត ដោយទទួលបានពិន្ទុតែ ១៦ ប៉ុណ្ណោះលើ ១០០ពិន្ទុ[73]។ ការរកឃើញនេះត្រូវបានធ្វើឡើងនៅក្នុងបរិបទដ៏ទូលំទូលាយមួយ ដែលនៅក្នុងការស្រាវជ្រាវរបស់របស់អង្គការតម្លាភាពអន្តរជាតិស្តីពីអំពើពុករលួយ បានរកឃើញថា ប្រទេសកម្ពុជាបច្ចុប្បន្ននេះត្រូវបានចាត់ទុកថាជាប្រទេសពុករលួយបំផុតនៅក្នុងចំណោមប្រទេសអាស៊ាន និងជាប្រទេសទី១៧នៃក្នុងចំណោម

---

ដោយផ្អែកលើមូលដ្ឋាននៃការទទួលស្គាល់របស់គាត់ក្នុងការទទួលយកសំណូកនៅក្នុងរឿងក្តីមុនៗ ៖ *សូមមើល* ឯកសារ E5/3 "សេចក្តីសម្រេចលើបណ្តឹងរបស់លោក អៀង សារី ដែលប្តឹងជំទាស់ចំពោះលោកចៅក្រម និល ណុន និងសំណើពាក់ព័ន្ធផ្សេងៗ" ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១ ("សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រម និល ណុន")។

[72] *សូមមើល ឧទាហរណ៍* ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ "របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីអំពីស្ថានភាពសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា ៖ Surya P. Subedi" ("របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីអំពីឯករាជ្យភាពនៃតុលាការ") ឯកសាររបស់ UN លេខ A/HRC/15/46 ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១០ កថាខណ្ឌ ៤០, ៤១, ៤៤, ៤៨-៥០, ៥២-៥៦។ ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ "របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីអំពីស្ថានភាពសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា ៖ Surya P. Subedi" ឯកសាររបស់ UN លេខ A/HRC/24/36 ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០១៣ កថាខណ្ឌ ១៦, ១៩, ២០។ គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា "NGOs' Joint Submission to the Universal Periodic Review of the United Nations Human Rights Council", 2013 កថាខណ្ឌ 7, 10, 14-17។ អង្គការ Human Rights Watch "Cambodia Universal Periodic Review Submission 2013", 2013។ *សូមមើល ផងដែរ* ឯកសារ ១ "សំណើរបស់ អៀង ធីរិទ្ធ សុំជំទាស់ចៅក្រម សោម សិរីវឌ្ឍ ពីអង្គជំនុំជម្រះតុលាការកំពូលដោយសារកង្វះឯករាជ្យភាព" ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១១ ដែលនៅក្នុងនោះ សហមេធាវី អៀង ធីរិទ្ធ បានស្នើសុំជំទាស់ចៅក្រម សោម សិរីវឌ្ឍ ដែលជាចៅក្រមនៅតុលាការកំពូលកម្ពុជា មិនឱ្យធ្វើជាចៅក្រមជំនុំជម្រះ នៅ អ.វ.ត.ក ដោយសារតែការចូលរួមរបស់គាត់នៅក្នុងសេចក្តីសម្រេច (ដែលត្រូវបានគេចាត់ទុកថាជាហេតុផលនយោបាយ) បដិសេធបណ្តឹងសាទុក្ខរបស់អ្នកនយោបាយគណបក្សប្រឆាំង មូរ សុខហួរ ប្រឆាំងនឹងការផ្តន្ទាទោសលោកស្រី ចំពោះបទបង្ខូចកេរ្តិ៍ឈ្មោះនាយករដ្ឋមន្ត្រី ហ៊ុន សែន។

[73] របាយការណ៍អំពីអំពើពុករលួយរបស់អង្គការតម្លាភាពអន្តរជាតិ កម្ពុជា ទំព័រ ៥២។

ប្រទេសពុករលួយបំផុតក្នុងពិភពលោក[74]។

45. ពាក់ព័ន្ធនឹងការតែងតាំងចៅក្រមដោយអង្គនីតិប្រតិបត្តិ អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា បានបញ្ចេញយោបល់ថា ចៅក្រមកម្ពុជាហាក់ដូចជាបំពេញភារកិច្ច "នៅក្នុង*បរិយាកាសនៃការភ័យខ្លាច* ក្នុងកម្រិតតិច ឬច្រើន ដែលពួកគាត់មានការប្រុងប្រយ័ត្នដោយមិនចាត់វិធានការទាំងឡាយណា ដែលអាចនាំឱ្យមានការរិះគន់លើបុគ្គលដែលមានអំណាច និងតួនាទីសំខាន់ឡើយ"[75]។ ស្រដៀងគ្នានេះដែរ នៅក្នុងសៀវភៅរបស់ Lemonde ចៅក្រម Lemonde បានរៀបរាប់អំពីរបៀបដែលចៅក្រមកម្ពុជាម្នាក់នៅ អ.វ.ត.ក បាននិយាយថា ចៅក្រមជាតិ*ទាំងអស់*មានការភ័យខ្លាច ឬមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយរដ្ឋាភិបាល និងគ្រប់ករណីទាំងអស់ មិនអាចជឿជាក់បាន និងគ្មានឯករាជ្យឡើយ[76]។ លើសពីនេះទៀត របាយការណ៍ជាច្រើន រួមមានរបាយការណ៍របស់អតីតសហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ ចៅក្រម Laurent Kasper-Ansermet បានបង្ហាញថា បញ្ហាប្រឈមទូទៅចំពោះអង្គចៅក្រមកម្ពុជា នៅតែបន្តប៉ះពាល់ដល់ចៅក្រមជាតិនៅក្នុង អ.វ.ត.ក[77]។ គួរឱ្យកត់សម្គាល់បំផុតនោះ ចៅក្រម Lemonde បានបញ្ចេញឱ្យដឹងថា គាត់ជឿជាក់ថា ចៅក្រមជាតិ អ.វ.ត.ក

---

[74] អង្គការតម្លាភាពអន្តរជាតិ Corruption Perceptions Index 2013, ឆ្នាំ ២០១៣ (ប្រទេសកម្ពុជាមានចំណាត់ថ្នាក់ទី១៦០ ក្នុងចំណោមប្រទេសទាំង១៧៧)។

[75] របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីអំពីឯករាជ្យភាពនៃតុលាការ កថាខណ្ឌ ៤៤ (សេចក្តីបញ្ជាក់បន្ថែម)។

[76] ឯកសារ E189/3/1/7.1.2 "Un Juge Face aux Khmers Rouges' (សម្រង់) ឆ្នាំ ២០១៣ ទំព័រ ៥១ ("Poursuivant sa description de la société locale, ce juge ajouta que je devais me méfier de *tous* le magistrats cambodgiens ou bien ils vivaient dans la peur du pouvoir en place ou bien ils en étaient proche mais, dans tous les cas, aucun n'était fiable ni indépendant" (សេចក្តីបញ្ជាក់ដើម))។

[77] *សូមមើល ឧទាហរណ៍* សំណុំរឿងលេខ ០០៣/០៧-០៩-២០០៩-អវតក-កសចស និង ០០៤/០៧-០៩-២០០៩-អវតក-កសចស ឯកសារ D38 "កំណត់សម្គាល់របស់សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិផ្ញើជូនភាគី ស្តីអំពីភាពមិនអាចដំណើរការបានដ៏ធ្ងន់ធ្ងរ ដែលរារាំងការបំពេញកិច្ចស៊ើបសួរឱ្យបានសមស្របក្នុងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤" ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១២។ Mark S. Ellis "ការការពារឯករាជ្យភាពនៃតុលាការនៅក្នុងតុលាការចម្រុះ ៖ មេរៀនពី អ.វ.ត.ក និងការអនុវត្តដ៏ល្អបំផុតសម្រាប់ពេលអនាគត" (Safeguarding Judicial Independence in Mixed Tribunals: Lessons from the ECCC and Best Practices for the Future) គណៈមេធាវីអន្តរជាតិ ខែ កញ្ញា ឆ្នាំ ២០១១។ អង្គការយុត្តិធម៌សង្គមសេរី (Open Society Justice Initiative) "ការជ្រៀតជ្រែកផ្នែកនយោបាយនៅឯអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" ខែ កក្កដា ឆ្នាំ ២០១០។

គឺពិតជាអាយ៉ង ដែលមានបុគ្គលនៅក្នុងរដ្ឋាភិបាលជាអ្នកញ៉ាក់ខ្សែពីក្រោយ[78]។

46. ការតែងតាំងចៅក្រមជាតិ មិនបំពេញទៅតាមលក្ខណៈវិនិច្ឆ័យរបស់តុលាការ ECtHR សម្រាប់ឯករាជ្យភាពរបស់តុលាការ សាលាក្តី ឬចៅក្រមតុលាការនោះឡើយ។ ឧទាហរណ៍ តុលាការ ECtHR កត់សម្គាល់នៅក្នុងរឿងក្តី *Volkov* ថា ៖

> វត្តមានរបស់អគ្គព្រះរាជអាជ្ញានៅក្នុងស្ថាប័នមួយដែលមានការពាក់ព័ន្ធនឹងការតែងតាំង ការដាក់វិន័យ និងការដកតំណែងចៅក្រម បង្កើតបានជាហានិភ័យថា ចៅក្រមនឹងមិនបំពេញតួនាទីដោយអនាគតិឡើយនៅក្នុងករណីបែបនេះ ឬថា អគ្គព្រះរាជអាជ្ញានឹងមិនប្រព្រឹត្តដោយអនាគតិឡើយចំពោះចៅក្រមដែលសេចក្តីសម្រេចរបស់ពួកគាត់ មិនត្រូវបានគាត់យល់ស្រប[79]។

47. រឿងក្តីនេះ មានលក្ខណៈធ្ងន់ធ្ងរជាងរឿងក្តី *Volkov*។ នៅក្នុងរឿងក្តីនេះ អគ្គព្រះរាជអាជ្ញាតុលាការកំពូល ជា ឈាង មិនត្រឹមតែជាសមាជិកនៅក្នុងក្រុមប្រឹក្សាចាត់តាំង ដាក់វិន័យ និងដកតំណែងចៅក្រមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសហព្រះរាជអាជ្ញាជាតិរបស់អ.វ.ត.ក ដែលក្នុងអំណាចនេះ គាត់ធ្លាប់បានជំទាស់ប្រកបដោយប្រសិទ្ធភាពចំពោះសំណើរបស់មេធាវីការពារក្តីសុំកោះហៅ ហេង សំរិន ក្នុងនាមជាសាក្សីម្នាក់[80]។ លោកចៅក្រម យូ ប៊ុនឡេង ដែលជាសមាជិករបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងជាសហចៅក្រមស៊ើបអង្កេតជាតិ ក៏បានជំទាស់ទៅនឹងការកោះហៅ ហេង សំរិន មកផ្តល់សក្ខីកម្មផងដែរ[81]។ សមាជិកនានានៃនីតិប្រតិបត្តិ ដែលរួមមាននាយករដ្ឋមន្ត្រី ហ៊ុន សែន ផងនោះ[82] បានថ្លែងអំពីការជំទាស់ទាំងនេះផងដែរ[83]។

---

[78] ឯកសារ E189/3/1/7.1.1 "Un Juge Face aux Khmers Rouges' (សម្រង់) ឆ្នាំ ២០១៣ ទំព័រ ៣២ ("Il est évident que, derrière les juges cambodgiens, il y a des gens qui tirent les ficelles au sein du gouvernement")។

[79] សាលក្រមរឿងក្តី Volkov កថាខណ្ឌ ១១៣។

[80] ឯកសារ E9/14/1/1/1 "ការជំទាស់បន្ថែម និងការកត់សម្គាល់របស់សហព្រះរាជអាជ្ញាទៅនឹងសាក្សី និងអ្នកជំនាញដែលបានស្នើឡើងដោយភាគីដទៃ" ("ការជំទាស់លើកទីមួយរបស់សហព្រះរាជអាជ្ញាជាតិ") ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១១ (ត្រូវបានចាត់ថ្នាក់ជាឯកសារសម្ងាត់ ទោះបីជាសំណើសុំរបស់សហព្រះរាជអាជ្ញាខ្លួនឯង បានចាត់ទុកជាចំណាត់ថ្នាក់សាធារណៈ)។

[81] ឯកសារ D314/1/12 សាលដីការបស់ អ.ប.ជ លើកទីពីរស្តីពីសាក្សី កថាខណ្ឌ ៩ និងឯកសារ E312 សេចក្តីសម្រេចស្តាពរស្តីពីសាក្សី កថាខណ្ឌ ៩០-៩១។

[82] *សូមមើល* ឯកសារ D254 "សំណើសុំបំពេញកិច្ចស៊ើបសួរ" ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ កថាខណ្ឌ ៦ ដែលដកស្រង់មតិយោបល់របស់លោក ហ៊ុន សែន នៅថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៩ ដែលថ្លែងថា "ថ្ងៃមុន ដើរទៅរកឯណា ហៅនរណាឡើងធ្វើសាក្សីឯណា ចង់ហៅអ្នកនេះ អ្នកនោះធ្វើសាក្សី អត់ទេ កុំរញ៉េរញ៉ៃច្រើនពេក"។

48. នៅក្នុងការជំទាស់របស់ខ្លួននៅខែ មីនា ឆ្នាំ២០១១ ទៅនឹងការកោះហៅ ហេង សំរិន ជាសាក្សី (ដែលមិនទាន់បំបែកកិច្ចដំណើរការនីតិវិធី) ក្នុងសំណុំរឿង០០២ សហព្រះរាជអាជ្ញាជាតិ ជា លាង បានលើកសេចក្តីសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងអាច "ដាក់បញ្ចូលកំណត់ហេតុសម្ភាសជាលាយលក្ខណ៍អក្សរ [របស់ហេង សំរិន] ទៅក្នុងឯកសាររបស់តុលាការបាន" នៅមុនការផ្តល់សក្ខីកម្មផ្ទាល់របស់គាត់ ហើយថា សក្ខីកម្មរបស់គាត់ត្រូវបាន "ធ្វើឡើងដោយសាក្សីផ្សេងទៀតនៅក្នុងសំណុំរឿងរួចហើយ"[84]។ ទឡ្ហីករណ៍ដូចគ្នាទាំងអស់មាននៅក្នុងសេចក្តីសម្រេចរបស់ចៅក្រមជាតិនៅក្នុងសេចក្តីសម្រេចស្តាពរស្តីពីសាក្សី ដែលសម្រេចមិនកោះហៅ ហេង សំរិន។ ទោះបីជាមិនមានការលើកឡើងដែលថា ចៅក្រមអាចចេញសេចក្តីសម្រេច ដោយមានសំអាងហេតុស្របគ្នាជាមួយសេចក្តីសន្និដ្ឋានដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា ក៏ស្ថានភាពនេះមានលក្ខណៈខុសគ្នាដោយសារតែ ព្រះរាជអាជ្ញារូបនេះ អាចដើរតួនាទីទៅកំណត់ជោគវាសនាវិជ្ជាជីវៈរបស់ចៅក្រមទាំងបីរូបនេះ។ នៅក្នុងករណីនេះ មេធាវីការពារក្តីកត់សម្គាល់បន្ថែមថា សហព្រះរាជអាជ្ញាជាតិ បានប្រកាសជាសាធារណនាពេលថ្មីៗនេះថា គាត់នៅតែបន្តជំទាស់ទៅនឹងការកោះហៅ ហេង សំរិន មកផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០២ ដោយផ្អែកលើមូលដ្ឋានថា ការស្នើសុំឲ្យកោះហៅនេះមានលក្ខណៈដដែលៗ មិនពាក់ព័ន្ធ និងប្រើប្រាស់ពេលវេលាមិនសមស្រប[85]។

49. ការទទួលប្រាក់បៀវត្សន៍ទ្វេរបស់ចៅក្រមជាតិ និងការរក្សាតួនាទីអចិន្ត្រៃយ៍របស់ពួកគាត់នៅក្នុងប្រព័ន្ធតុលាការកម្ពុជា រួមនឹងតួនាទីបណ្តោះអាសន្ននៅអ.វ.ត.ក មិនបានបំពេញលក្ខណៈវិនិច្ឆ័យរបស់តុលាការ ECtHR បានទេ។ នៅក្នុង*រឿងក្តី Volkov* តុលាការ ECtHR បានសម្រេចថា ស្ថានភាពបែបនេះមានន័យថា តុលាការជៀសមិនរួចនឹងមាន "ការពឹងផ្អែកខាងសម្ភារៈឋានានុក្រម និងរដ្ឋបាលទៅលើចៅហ្វាយនាយផ្ទាល់ និង[ធ្វើឲ្យប៉ះពាល់ដល់]ឯករាជ្យភាព និងភាពឥតលម្អៀងរបស់ពួកគាត់"[86]។ នៅក្នុងរឿងក្តីនេះ លទ្ធភាពឯករាជ្យភាពរបស់ចៅក្រមជាតិកាន់តែត្រូវបានធ្វើឲ្យប៉ះពាល់បន្ថែមទៀតដោយភាពខ្វះនូវសន្តិសុខក្នុងការរក្សាមុខតំណែង និងឥទ្ធិពលរបស់ក្រុមប្រឹក្សានៃអង្គចៅក្រម និងនីតិប្រតិបត្តិលើជោគវាសនាវិជ្ជាជីវៈរបស់ខ្លួន។

---

[83] *សូមមើល ឧទា.* ឯកសារ D314/1/12 សាលដីការបស់ អ.ប.ជ លើកទីពីរស្តីពីសាក្សី កថាខណ្ឌ ៤០(គ) និង(ឃ)។

[84] ឯកសារ E9/14/1/1/1 ការជំទាស់លើកទីមួយរបស់សហព្រះរាជអាជ្ញាជាតិ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១១ កថាខណ្ឌ ៤។

[85] ឯកសារ E1/240.1 "ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធី" ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៤ ទំព័រ ១១៤ ជួរ ៧-១៧។

[86] សេចក្តីសម្រេច ក្នុងរឿងក្តី Volkov កថាខណ្ឌ ១១៣។

ហេតុដូច្នេះ ចៅក្រមមិនមាន "ការធានាគ្រប់គ្រាន់ពីសម្ពាធខាងក្រៅ" ដូចដែលបានតម្រូវដោយលក្ខណៈវិនិច្ឆ័យរបស់តុលាការ ECtHR។

50. ពាក្យបណ្ដឹងនេះ មិនលើកឡើងទឡ្ហីករណ៍ត្រង់ចំណុចនីត្យានុកូលភាពទាក់ទិននឹងភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីនៃសេចក្ដីសម្រេចរបស់ចៅក្រមជាតិក្នុងការមិនកោះហៅ ហេង សំរិន នៅក្នុងសំណុំរឿង ០០២/០១ នោះទេ ដោយសារតែទឡ្ហីករណ៍បែបនេះ នឹងត្រូវលើកឡើងនៅក្នុងបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដីប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០១។ ដូច្នេះ ផ្ទុយទៅវិញ មេធាវីការពារក្ដីគ្រាន់តែកត់សម្គាល់ដោយសង្ខេបថា សេចក្ដីសម្រេចស៊ីសង្វាក់គ្នានឹងជំហរដែលបានលើកឡើងដោយសមាជិកក្រុមប្រឹក្សានៃអង្គចៅក្រម និងស្ថាប័ននីតិប្រតិបត្តិ ហើយពិតជាផ្ទុយគ្នាទៅនឹងជំហររបស់ចៅក្រមអន្តរជាតិ។

51. នៅក្នុងរឿងក្ដីពាក់ព័ន្ធនឹងអ្នកនយោបាយជនជាតិហូឡង់ Geert Wilders ដ៏ចម្រូងចម្រាស់ តុលាការសាលាដំបូង Amsterdam បានសម្រេចថា សេចក្ដីសម្រេចរបស់ចៅក្រម ដែលមិនអនុញ្ញាតតាមសំណើសុំកោះសាក្សីរបស់មេធាវីការពារក្ដី មិននាំឱ្យមានភាពអព្យាក្រឹតនោះទេ លើកលែងតែសំអាងហេតុដែលមានលើកឡើង មានលក្ខណៈមិនសមហេតុផល ដែលមិនមានការសន្និដ្ឋានផ្សេងទៀតក្រៅតែមានលក្ខណៈលម្អៀងពិតប្រាកដ ឬនាំឱ្យដឹងអំពីភាពលម្អៀង[87]។ រឿងក្ដីនោះគឺខុសគ្នាពីរឿងក្ដីនៅទីនេះ។ សេចក្ដីសម្រេចរបស់ចៅក្រមជាតិគឺមិនសមហេតុផលយ៉ាងច្រើន[88] ហើយសេចក្ដីសម្រេចនេះធ្វើឡើងនៅក្នុងបរិបទមួយដែលផ្ទុះ

---

[87] Rechtbank Amsterdam ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១០, NS 2010, 329, HA RK 10.1128។ Geert Wilders គឺជាសមាជិកមួយរូបរបស់សភាហូឡង់ ដែលគាត់ត្រូវបានផ្ដន្ទាទោសពីបទញុះញង់ឱ្យស្អប់លើប្រជាជនមូស្លីមហូឡង់។

[88] ដោយសារបណ្ដឹងសាទុក្ខនេះមិនបានលើកឡើងនូវទឡ្ហីករណ៍ ក៏ប៉ុន្តែមេធាវីការពារក្ដីគ្រាន់តែកត់សម្គាល់ដោយសង្ខេបថា នៅក្នុងការដកស្រង់ការធ្វើឧបមានវិធី ដែលរួមមានការប្រើប្រាស់អភ័យឯកសិទ្ធិ និងការពន្យារពេលដែលអាចកើតមានឡើង នៅពេលកោះហៅ ហេង សំរិន មកផ្ដល់សក្ខីកម្ម ក៏ចៅក្រមជាតិ "បានឱ្យតម្លៃទៅលើការពិចារណាមិនពាក់ព័ន្ធ" ហើយបានខកខានមិនបាន "ឱ្យតម្លៃគ្រប់គ្រាន់ទៅលើការពិចារណាដែលពាក់ព័ន្ធ" (*រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Prlić និងអ្នកផ្សេងទៀត*, សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញាប្រឆាំងនឹងការដោះលែង Jadranko Prlić ជាបណ្ដោះអាសន្ន សំណុំរឿងលេខ IT-04-74-AR65.26 ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ កថាខណ្ឌ ៤។ *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Lukić & Lukić* សាលដីកា សំណុំរឿង IT-98-3211-A ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១២ កថាខណ្ឌ ១៧)។ កត្តាមិនពាក់ព័ន្ធទាំងនេះ ដែលរួមមានការធ្វើឧបមានវិធី រួមទាំងការពន្យារដែលអាចកើតមានដោយសារការកោះហៅ ហេង សំរិន មកផ្ដល់សក្ខីកម្មផងដែរ ៖ ឯកសារ E312 សេចក្ដីសម្រេច

បញ្ហាំងពីចំណុចជាច្រើនដែលប្រាសចាកពីបទដ្ឋានមានចែងអំពីឯករាជ្យភាព[89] ដែលអនុភាពត្រួតគ្នា គឺបំផ្លាញដល់ការបង្ហាញឱ្យឃើញនូវឯករាជ្យភាពខាងផ្នែករបស់ចៅក្រមជាតិ។ ករណីនេះរំលោភជាក់ស្តែងលើសិទ្ធិរបស់ នួន ជា ក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌។ ដោយសារតែចៅក្រមជាតិ មិនមានបង្ហាញឱ្យឃើញនូវឯករាជ្យភាព ដូច្នេះចៅក្រមជាតិ មិនមានលក្ខណៈសម្បត្តិពាក់ព័ន្ធដើម្បីរក្សាតួនាទីនៅក្នុងតុលាការ អ.វ.ត.ក ឡើយ ហើយអាស្រ័យហេតុនេះចៅក្រមទាំងនេះគួរតែត្រូវបានដកចេញ។

***(ii) ការបង្ហាញឱ្យឃើញនូវភាពលម្អៀងដែលមិនអាចទទួលយកបាន***

52. ម្យ៉ាងវិញទៀត និងជាពិសេសប្រសិនបើអង្គជំនុំជម្រះសម្រេចថា ខ្លួនមិនអាចប្រឈមនឹងបញ្ហានៃឯករាជ្យភាពតុលាការដោយផ្ទាល់[90] មេធាវីការពារក្តីលើទឡ្ហីករណ៍ថា សេចក្តីសម្រេចរបស់ចៅក្រមជាតិដែលសម្រេចមិនកោះហៅ ហេង សំរិន នៅក្នុងសំណុំរឿង ០០២/០១ បានបណ្តាលឱ្យមានការបង្ហាញឱ្យឃើញនូវភាពលម្អៀងដែលមិនអាចទទួលយកបាន។ សេចក្តីសម្រេចរបស់ចៅក្រមជាតិដែលសម្រេចមិនកោះហៅ ហេង សំរិន គឺផ្អែកលើបញ្ហានានាដែលមិនមែនជាការវាយតម្លៃច្បាស់លាស់លើអង្គច្បាប់ និងអង្គហេតុដែលពាក់ព័ន្ធ ដូចដែលបានលើកឡើងនៅក្នុងកថាខណ្ឌ ៥០ ខាងលើ។ ហេតុដូច្នេះ ទង្វើនេះបង្ហាញឱ្យឃើញថា ចៅក្រមជាតិមានការបង្ហាញនូវភាពលម្អៀងរួចទៅហើយ ដែលគួរតែដកចេញ។ ម្យ៉ាងវិញទៀត សេចក្តីសម្រេចរបស់ចៅក្រមជាតិដែលសម្រេចមិនកោះហៅ ហេង សំរិន បានបង្ហាញឱ្យឃើញច្បាស់ថា ចំពោះសំណុំរឿង

---

ស្តាពរស្តីពីសាក្សី កថាខណ្ឌ ៩៧។ ចៅក្រម Cartwright និងចៅក្រម Lavergne រិះគន់យ៉ាងខ្លាំងចំពោះបញ្ហានេះ ៖ *សូមមើល* ឯកសារ E312 សេចក្តីសម្រេចស្តាពរស្តីពីសាក្សី កថាខណ្ឌ ១០៧, ១០៨, ១១០។

[89] *សូមមើល* ទឡ្ហីករណ៍នៅកថាខណ្ឌ ៤៣ ដល់ ៤៨ ខាងលើ។

[90] អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានយល់ឃើញបែបនេះនៅខែមករា ឆ្នាំ២០១១ (*សូមមើល* ឯកសារ E5/3 សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្តចំពោះចៅក្រម និល ណុន កថាខណ្ឌ ១៥ ទោះបីជាអង្គជំនុំជម្រះសាលាដំបូងក៏បានសម្រេចថា "អ.វ.ត.ក អាចធានាបានថា ក្នុងដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ជនជាប់ចោទពិតជាទទួលបានអត្ថប្រយោជន៍ពីដំណើរការនីតិវិធីប្រកបដោយយុត្តិធម៌ និងបានប្រព្រឹត្តទៅស្របតាមបទដ្ឋានអន្តរជាតិ")។ ទោះបីជាយ៉ាងណាក៏ដោយ វាបង្ហាញឃើញថា អ.ជ.ត.ក មិនយល់ស្របជាមួយនឹង អ.ជ.ស.ដ។ អ.ជ.ត.ក ហាក់មានចេតនាយល់ស្របតាមខ្លឹមសារនៃពាក្យសុំជំទាស់ចិត្តចៅក្រម សោម សិរីវុឌ្ឍ អនុលោមតាមវិធាន ៣៤ នៃវិធានផ្ទៃក្នុងដោយផ្អែកលើកង្វះឯករាជ្យភាព (*សូមមើល* ឯកសារ ១/៤ "សេចក្តីសម្រេចលើសំណើរបស់ អៀងធីរិទ្ធ សុំជំទាស់ចិត្តចៅក្រម សោម សិរីវុឌ្ឍ ពីអង្គជំនុំជម្រះតុលាការកំពូលដោយសារកង្វះឯករាជ្យភាព" ថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ២០១១)។

០០២/០២ ចៅក្រម*បានសម្រេចជាមុន* (ខ្វះ) នូវភាពជឿជាក់នៃទឡ្ហីករណ៍ដែលមេធាវីការពារក្តីស្នើសុំតាមរយៈការផ្តល់សក្ខីកម្មពិសេសរបស់ ហេង សំរិន[91] ហើយ*កំណត់ជាមុន*នូវទស្សនៈថា សំណើរបស់មេធាវីការពារក្តីសុំឱ្យកោះហៅ ហេង សំរិន ក្នុងនាមជាសាក្សីអត្តចរិតតែមួយ គឺជាបញ្ហាអាក្រក់នៃ "យុទ្ធសាស្ត្រជំនុំជម្រះ" ដែលរៀបចំឡើងដើម្បី "បង្កើតឱ្យមានភាពចម្រូងចម្រាស់"[92]។ ករណីនេះឱ្យនាំដល់ការលេចចេញនូវភាពលម្អៀងរបស់ចៅក្រមនៅក្នុងសំណុំរឿង ០០២/០២ ដែលគួរតែត្រូវបានដកចេញ។

**គ. ចៅក្រមជាតិមានផលប្រយោជន៍ផ្ទាល់ខ្លួននៅក្នុងរឿងក្តីប្រឆាំងនឹង នួន ជា ដែលនាំឱ្យលេចចេញនូវភាពលម្អៀងដែលមិនអាចទទួលយកបាន**

53. នៅក្នុងសុន្ទរកថានៅវិទ្យាស្ថាន Aspen ចៅក្រម Cartwright បានលើកឡើងថា ចៅក្រមជាតិមួយរូបក្នុងចំណោមចៅក្រមជាតិទាំងអស់ត្រូវបានចោទប្រកាន់ថា ធ្លាប់ត្រូវបានចាប់ខ្លួនដោយភាន់ច្រឡំថាជាទាហាន នល់ នល់ នៅពេលទីក្រុងភ្នំពេញត្រូវបានជម្លៀស ប៉ុន្តែត្រូវបានដោះលែងមកវិញនាពេលក្រោយមក ធ្លាប់ធ្វើការងារនៅទំនប់មួយ ដែលប្រធានទំនប់នេះក្រោយមកត្រូវបានចោទប្រកាន់ និងសម្លាប់ចោលនៅ ស-២១ និងធ្លាប់រៀបអាពាហ៍ពិពាហ៍ដែលត្រូវបានចោទប្រកាន់ថាបានរៀបចំឡើងដោយបក្សកុម្មុយនីស្តកម្ពុជា។ ចៅក្រមជាតិម្នាក់ទៀតត្រូវបានបញ្ជូនឱ្យទៅធ្វើការងារនៅក្នុងកងកុមារនៅក្នុងអំឡុងពេលនៃសម័យកម្ពុជាប្រជាធិបតេយ្យ។ ម្យ៉ាងវិញទៀត ចៅក្រម Cartwright បានសង្កេតឃើញថា ចៅក្រមជាតិ - "ទាំងអស់គ្នាធ្លាប់រស់នៅក្នុងពេញមួយរបបនេះ" ជារឿយៗបាន "លើកយោបល់មិនគួរសម" អំពី ឬ "បានសំដែងទឹកមុខប្រឆាំង" ប្រឆាំងនឹងភស្តុតាងដោះបន្ទុក ឬទឡ្ហីករណ៍ដែលបានបង្ហាញនៅក្នុងតុលាការ[93]។

54. ករណីត្រឹមតែថា ចៅក្រមជាតិច្បាស់ណាស់ថាធ្លាប់បានឆ្លងកាត់បទពិសោធន៍ដោយផ្ទាល់លើបញ្ហានានាដែលមានភាពចម្រូងចម្រាស់ក្នុងសំណុំរឿង ០០២ ពុំនាំឱ្យមានការប្តឹងជំទាស់ដោយស្វ័យ

---

[91] មតិយោបល់របស់ Buergenthal កថាខណ្ឌ ១៣ (គូសបញ្ជាក់បន្ថែម)។

[92] ទាក់ទិននឹងផ្នែកដែលដកស្រង់នៃការយល់ឃើញរបស់ចៅក្រមជាតិ *សូមមើល ឯកសារ E312* សេចក្តីសម្រេចស្តាពីសាក្សី កថាខណ្ឌ ១១៧។ ទាក់ទិននឹងការយល់ឃើញត្រង់ចំណុចយុទ្ធសាស្ត្រដែលជាការបង្កើតនូវទស្សនមួយ បណ្តាលឱ្យមាននូវការបង្ហាញនៃភាពលម្អៀងដែលមិនអាចទទួលយកបាន *សូមមើល* មតិយោបល់របស់ Buergenthal កថាខណ្ឌ ៨។

[93] ឯកសារ E350/12.38R សុន្ទរកថានៅវិទ្យាស្ថាន Aspen ម៉ោង ៥៤:៤១-៥៩:០១ ។

ប្រវត្តិនោះទេ។ ចៅក្រមវិជ្ជាជីវៈមានភារកិច្ចចម្បងធ្វើការជំនុំជម្រះដោយអព្យាក្រឹត។ ដូចចៅក្រមនៅក្នុងតុលាការដំបូងរបស់ Jerusalem បានពន្យល់នៅក្នុងរឿងក្តី *Eichmann* ខណៈក្នុងពេលធ្វើការជំនុំជម្រះ ចៅក្រមតម្រូវឱ្យ "រំងាប់អារម្មណ៍ និងចិត្ត[របស់ចៅក្រម] បើមិនដូច្នោះទេ ចៅក្រមនឹងពុំមានសម្បទាពិចារណាបទចោទព្រហ្មទណ្ឌ ដែលធ្វើឱ្យមានអារម្មណ៍ស្អប់ខ្ពើម ដូចជា ការក្បត់ជាតិ ការធ្វើមនុស្សឃាត ឬឧក្រិដ្ឋកម្មធ្ងន់ធ្ងរផ្សេងទៀតនោះឡើយ"[94]។ ដូច្នេះ ទោះបីជាការធ្វើសវនាការលើខ្លឹមសារនៅវិទ្យាស្ថាន Aspen បាននាំឱ្យមេធាវីការពារក្តីមានការព្រួយបារម្ភភ្លាមៗក៏ដោយ ក៏មេធាវីការពារក្តីមិនប្រតិកម្មតបស្នើសុំប្តឹងជំទាស់ ចៅក្រមជាតិភ្លាមៗនោះទេ។ ការមិនប្រតិកម្មដូច្នេះគឺដោយសារថា មេធាវីការពារក្តីបានពិចារណាឃើញថា ខ្លួនចាំបាច់ត្រូវគោរពសច្ចធារណ៍នៃវិជ្ជាជីវៈ និងភាពអព្យាក្រឹតរបស់ចៅក្រមជាតិ ហើយមិនត្រូវសន្និដ្ឋានអំពីភាពលម្អៀងដោយពុំមានភស្តុតាងសំអាងបន្ថែមនោះឡើយ។

55. ទោះបីជាយ៉ាងនេះក្តី ក្រោយពីពិនិត្យមើលសាលក្រមសំណុំរឿង ០០២/០១ ឡើងវិញ និងក្រោយពិនិត្យមើលសេចក្តីសម្រេចស្តាពរស្តីពីសាក្សី មេធាវីការពារក្តីត្រូវធ្វើការសន្និដ្ឋានដោយបង្ខំចិត្តថា នៅក្នុងសំណុំរឿង ០០២/០១ តាមពិត ចៅក្រមជាតិអាចមិនបានបំពេញភារកិច្ចដោយភាពអព្យាក្រឹតរបស់ខ្លួនក្នុងសំណុំរឿងនេះទេ។ នៅក្នុងសាលក្រមនេះ ចៅក្រមទាំងអស់ទំនងជាខ្វះនូវភាពអព្យាក្រឹតចំពោះភស្តុតាង និងសេចក្តីសន្និដ្ឋាននានារបស់មេធាវីការពារក្តីដូចបានបង្ហាញតាមរយៈការប្រើប្រាស់ពាក្យបច្ចេកទេសផ្សេងៗគ្នា[95] បានច្រានចោលទឡ្ហីករណ៍របស់មេធាវីការពារក្តីទាក់ទងនឹងអត្ថិភាពនៃភាពរង្គោះរង្គើនៃការបាក់បែកផ្ទៃក្នុងបក្សកុម្មុយនីស្តកម្ពុជា[96] ព្រមទាំងបានសម្រេចលឿនពេកអំពីអត្ថិភាពនៃគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ស្តីពីការដាក់បទបញ្ជាទាក់ទងនឹងអាពាហ៍ពិពាហ៍[97] និងការសម្រេចមិនសមស្របទាក់ទងនឹងភស្តុតាងអំពីប្រជាសាស្ត្រ[98] និងបានលើកយោងមិនសមហេតុផលលើសាលក្រមក្នុងរឿងក្តី ឌុច ដើម្បីកំណត់

---

[94] រឿងក្តី *រដ្ឋអាជ្ញានៃរដ្ឋាភិបាលអ៊ីស្រាអែល ទល់នឹង Eichmann* តុលាការក្រុង Jerusalem, Decn. 6, Sessn.3, Vol. 1, ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៦១ ដែលបានដកស្រង់ដោយមានការឯកភាពនៅក្នុងរឿងក្តី *រដ្ឋអាជ្ញានៃរដ្ឋាភិបាលអ៊ីស្រាអែល ទល់នឹង Eichmann* (តុលាការកំពូលនៃប្រទេសអ៊ីស្រាអែល ឆ្នាំ ១៩៦២) ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៦២។

[95] *សូមមើល* សេចក្តីសន្និដ្ឋានលម្អិតរបស់មេធាវីការពារក្តីក្នុងបញ្ហានេះចាប់ពីកថាខណ្ឌ ៦១ *និងកថាខណ្ឌបន្តបន្ទាប់ទៀត*។

[96] *សូមមើល* សេចក្តីសន្និដ្ឋានលម្អិតរបស់មេធាវីការពារក្តីក្នុងបញ្ហានេះចាប់ពីកថាខណ្ឌ ៧៣ *និងកថាខណ្ឌបន្តបន្ទាប់ទៀត*។

[97] *សូមមើល* សេចក្តីសន្និដ្ឋានលម្អិតរបស់មេធាវីការពារក្តីក្នុងបញ្ហានេះចាប់ពីកថាខណ្ឌ ៨១ *និងកថាខណ្ឌបន្តបន្ទាប់ទៀត*។

[98] *សូមមើល* សេចក្តីសន្និដ្ឋានលម្អិតរបស់មេធាវីការពារក្តីក្នុងបញ្ហានេះចាប់ពីកថាខណ្ឌ ៨៦ *និងកថាខណ្ឌបន្តបន្ទាប់ទៀត*។

និយមន័យនៃពាក្យ "កម្មេច"[99]។ បញ្ហាទាំងអស់នេះបង្ហាញឲ្យឃើញថា ចៅក្រមបានបង្ហាញនូវការលេចចេញនៃភាពលម្អៀងដែលមានស្រាប់រួចទៅហើយ។

56. នៅក្នុងរឿងក្តី *Kyprianou* តុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចថា វាមានការភ័យខ្លាចមិនអាចទទួលយកបាននូវការមិនគោរពតាម "គោលការណ៍ដែលចែងថា *គ្មានជនណាមួយធ្វើជាចៅក្រមជម្រះលើរឿងក្តីរបស់ខ្លួននោះទេ*"[100] ហើយជាហេតុនាំឲ្យលេចចេញនូវភាពលម្អៀងដែលមិនអាចទទួលយកបាន នៅពេលចៅក្រមដែលបានរងនូវភាពអាម៉ាសដោយទង្វើរបស់មេធាវី បានធ្វើការជំនុំជម្រះ និងដាក់ពន្ធនាគារមេធាវីភ្លាមៗពីបទជេរប្រមាថតុលាការ។ តុលាការក៏បានរកឃើញនូវភាពលម្អៀងជាក់ស្តែង ដោយបានកត់សម្គាល់ថា បទល្មើសផ្ទាល់ខ្លួនរបស់ចៅក្រម "បានបញ្ជាក់អំពី*ការចូលរួមផ្ទាល់របស់* [ពួកគាត់]"[101] ដែលចំណាប់អារម្មណ៍នេះកាន់តែរឹងមាំថែមទៀតតាមរយៈការប្រើប្រាស់ភាសាសម្តែងនូវ "អារម្មណ៍ឈឺចិត្ត និងស្រឡាំងកាំង" ដែលផ្ទុយនឹងវិធីសាស្ត្រដោយឡែក ដែលត្រូវបានរំពឹងថាកើតមាននៅពេលប្រកាសសាលក្រម" និងតាមរយៈសេចក្តីសន្និដ្ឋានលឿនពេកអំពីពិរុទ្ធភាពរបស់មេធាវី[102]។ តុលាការបានសម្រេចបន្ថែមទៀតថា ទង្វើដូចគ្នារបស់ចៅក្រមអាចបង្កើតឲ្យឃើញមានទាំងការលេចចេញនូវភាពលម្អៀង និងភាពលម្អៀងជាក់ស្តែង[103]។ ស្រដៀងគ្នានេះដែរក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធីជំនុំជម្រះនៅចំពោះមុខតុលាការយោធា Tokyo សម្រាប់ចុងបូព៌ា ចៅក្រមភីលីពិន Delfin Jaranilla បានដកខ្លួនចេញពីសវនាការស្តាប់ភស្តុតាងទាក់ទងនឹងព្រឹត្តិការណ៍ទាំងឡាយដែលទាក់ទងនឹង 'Bataan death march' ដែលជាព្រឹត្តិការណ៍ជម្លៀសដោយបង្ខំដែលគាត់ជាជនរងគ្រោះ[104]។ ថ្វីបើមានការដកខ្លួនពីសំណាក់ចៅក្រមមែន ក៏វាមិនគ្រប់គ្រាន់សម្រាប់ក្រុមអ្នករិះគន់ដែរ ដែលគិតថា"ប្រវត្តិសាវតារផ្ទាល់ខ្លួននៃការពាក់ព័ន្ធដោយផ្ទាល់នៅក្នុងបញ្ហានេះ [...] ចាំបាច់ឲ្យដកខ្លួនចៅក្រមណា

---

99 *សូមមើល* សេចក្តីសន្និដ្ឋានលម្អិតរបស់មេធាវីការពារក្តីក្នុងបញ្ហានេះចាប់ពីកថាខណ្ឌ ៩០ *និងកថាខណ្ឌបន្តបន្ទាប់ទៀត*។

100 សាលក្រមរឿងក្តី Kyprianou កថាខណ្ឌ ១២៧។

101 សាលក្រមរឿងក្តី Kyprianou កថាខណ្ឌ ១៣០ (គូសបញ្ជាក់បន្ថែម)។

102 សាលក្រមរឿងក្តី Kyprianou កថាខណ្ឌ ១៣០។

103 សាលក្រមរឿងក្តី Kyprianou កថាខណ្ឌ ១១៩។

104 Neil Boister និង Robert Cryer, eds., "ឯកសារនៅតុលាការយោធាអន្តរជាតិទីក្រុងតូក្យូ" ឆ្នាំ២០០៨ p. lv ។

មួយនៅកម្រិតជាតិ ឬកម្រិតអន្តរជាតិ”[105]។

57. នៅក្នុងរឿងក្តីបច្ចុប្បន្ន ចៅក្រមជាតិទាំងអស់ធ្លាប់បាន “រស់នៅពេញមួយរបបនេះ” យោងតាមសុន្ទរកថារបស់ចៅក្រម Cartwright នៅវិទ្យាស្ថាន Aspen[106]។ យ៉ាងហោចណាស់ ចៅក្រមពីររូបក្នុងចំណោមចៅក្រមទាំងអស់ធ្លាប់មានបទពិសោធន៍ផ្ទាល់អំពីបញ្ហានានា ដែលមានវិវាទនៅក្នុងសំណុំរឿង ០០២/០២។ ចំណុចនេះបានបញ្ជាក់ឲ្យឃើញអំពីការពាក់ព័ន្ធផ្ទាល់ខ្លួននៅក្នុងរឿងក្តីប្រឆាំងនឹង នួន ជា។ ជាក់ស្តែង នៅក្នុងអំឡុងពេលពិភាក្សាដេញដោលនៅក្នុងរដ្ឋសភាជាតិកម្ពុជាក្នុងឆ្នាំ ២០០៤ ដើម្បីអនុម័តកិច្ចព្រមព្រៀងនៃ អ.វ.ត.ក និងដើម្បីបង្កើតសាលាក្តី សមាជិករដ្ឋសភាជាតិកម្ពុជាបានបង្ហាញនូវការព្រួយបារម្ភថា ការតែងតាំងអ្នកដែលធ្លាប់បាន “រស់នៅពេញមួយរបបនេះ” អាចបណ្តាលឲ្យតុលាការមានភាពលម្អៀងដែលមិនអាចទទួលយកបាន។ ឧបនាយករដ្ឋមន្ត្រី សុខ អាន ដែលបានដឹកនាំការចរចាជាមួយនឹង អ.ស.ប ដើម្បីបង្កើត អ.វ.ត.ក បានផ្តល់យោបល់លើបញ្ហានេះដូចខាងក្រោម ៖

> *នៅក្នុងក្របខណ្ឌច្បាប់របស់យើង ប្រសិនបើចៅក្រមណាម្នាក់ជាប់ទាក់ទងនឹងគោលដៅដែលត្រូវចោទប្រកាន់ ចៅក្រមនោះមិនអាចធ្វើការងារនោះទេ ដោយសារជនជាប់ចោទនឹងប្តឹងបកចៅក្រមនោះ។ យោងតាមច្បាប់ បុគ្គលរូបនេះមិនត្រូវតែងតាំងឲ្យធ្វើជាចៅក្រមសម្រាប់រឿងក្តីនេះទេ ពីព្រោះសាលក្រមអាចមានភាពលម្អៀង។* ទោះបីជាយ៉ាងណាក្តី រឿងក្តីនេះត្រូវបានចាត់ទុកជារឿងក្តីពិសេស។ នៅក្នុងការព្យាយាមបង្កើតច្បាប់នេះ យើងក៏បានពិចារណាលើចំណុចនេះដែរ។ បុគ្គលដែលមកចរចាជាមួយយើងអំពីច្បាប់នេះមិនមែនល្ងង់នោះទេ។ ពួកគេឆ្លាត ណាស់។ នៅក្នុងពេលពិភាក្សា យើងក៏បានកត់សម្គាល់ឃើញថា ចៅក្រមមកពីបរទេសពុំស្គាល់ ប៉ុល ពត។ ពួកគាត់មិនដែលធ្លាប់បានដឹងអំពីឧក្រិដ្ឋកម្ម [នៃរបបនោះ] ហើយពួកគាត់មិនដែល ធ្លាប់បានឆ្លងកាត់របប ៣ ឆ្នាំ ៨ ខែ ២០ ថ្ងៃនោះឡើយ។ ប៉ុន្តែ *ចៅក្រមកម្ពុជាមានបទពិសោធន៍ពីការឈឺចាប់ដោយសាររបបនេះ និងខឹងនឹងរបបនេះ។ ដូច្នេះ យោងតាមច្បាប់ ការជំនុំជម្រះអាចមិនយុត្តិធម៌ និងលម្អៀង ហើយបុគ្គលទាំងនេះមិនត្រូវចូលពាក់ព័ន្ធនឹងការងារនេះទេ។* ប៉ុន្តែ មានទស្សនៈយល់ឃើញមួយទៀតថា មេធាវីបរទេសពុំបានដឹងអំពីរបបនេះ ឬលក្ខណៈនៃរបបនេះទេ។ ដូច្នេះ ការយល់ដឹងរបស់ចៅក្រមកម្ពុជាអំពីរបបនេះគឺជាចំណុចវិជ្ជមានពីព្រោះអ្នកដែលជាជនរងគ្រោះនៅ

---

[105] Neil Boister និង Robert Cryer, eds., “ឯកសារនៅតុលាការយោធាអន្តរជាតិទីក្រុងតូក្យូ” ឆ្នាំ២០០៨ p. lv ។

[106] ឯកសារ E350/12.38R សុន្ទរកថានៅវិទ្យាស្ថាន Aspen ម៉ោង ៥៤:៤១-៥៥:៤៩ ។

ក្នុងរបបនេះអាចយល់អំពីលក្ខណៈនៃឧក្រិដ្ឋកម្ម។ ដូច្នេះ វាមានទាំងចំណុចវិជ្ជមាន និងអវិជ្ជមាន។ *អ្វីដែលខ្ញុំបាននិយាយពុំមានន័យថា យើងត្រូវតែតែងតាំងចៅក្រមទាំងនោះដែលធ្លាប់រស់នៅក្នុងរបបនោះឡើយ ប៉ុន្តែ ដូចដែលយើងបានមើលឃើញស្រាប់ វាមានទាំងចំណុចវិជ្ជមាន និងអវិជ្ជមាន* [107]។

58. យោបល់ទាំងនេះផ្សាភ្ជាប់ជាមួយនឹងការព្រួយបារម្ភធំធេងជាងនេះលើករណីថាតើសញ្ជាតិរបស់ចៅក្រមអាចនាំឱ្យលេចចេញនូវភាពលម្អៀងក្រោយពីពិនិត្យមើលបរិបទប្រវត្តិសាស្ត្រ និងភូមិសាស្ត្រនយោបាយ ពាក់ព័ន្ធនឹងរឿងក្តីទាំងនេះ ឬយ៉ាងណា។ ឧទាហរណ៍ នៅពេលជ្រើសរើសចៅក្រមលើកដំបូងសម្រាប់សាលាក្តី ICTY បេក្ខជនជ្រើសតាំងដោយប្រទេសរុស្សីសម្រាប់ក្រុមប្រឹក្សាជំនុំជម្រះរបស់សាលាក្តី ICTY ពុំត្រូវបានតែងតាំងនោះទេ "ពីព្រោះថា សមាជិកក្រុមប្រឹក្សាសន្តិសុខភាគច្រើនទំនងជាមានការភ័យខ្លាចថា ចៅក្រមរូបនេះអាចនឹងលម្អៀងទៅខាងប្រទេសស៊ែប៊ី"[108]។ ជាក់ស្តែង យោបល់របស់ឧបនាយករដ្ឋមន្ត្រី សុខ អាន បង្ហាញឱ្យឃើញថារដ្ឋាភិបាលកម្ពុជាខ្លួនឯងហាក់ដូចជាមានការភ័យខ្លាចថា សញ្ជាតិរបស់ចៅក្រមកម្ពុជា និងបទពិសោធន៍ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យអាចជ្រៀតជ្រែកជាមួយនឹងលទ្ធភាពក្នុងការរក្សានូវភាពអព្យាក្រឹត។ វាការជាក់ស្តែងនៅទីបំផុត ការភ័យខ្លាចទាំងនេះគឺមិនខុសមែន។

59. នៅក្នុងរឿងក្តីនេះ ការបង្ហាញអំពីភាពពាក់ព័ន្ធដោយផ្ទាល់របស់ចៅក្រមជាតិតាមរយៈការធ្លាប់ "រស់នៅពេញមួយរបប[នេះ]" គឺកាន់តែឃើញច្បាស់ឡើងតាមរយៈរបាយការណ៍ថា ចៅក្រមជាតិបានបង្ហាញនូវ "ការឈឺចាប់" ដូចក្នុងរឿងក្តី *Kyprianou* នៅក្នុងពេលជំនុំជម្រះលើសំណុំរឿង ០០២/០១ ដោយចៅក្រមបានផ្តល់ "យោបល់មិនគួរសម" និង "សម្តែងទឹកមុខប្រឆាំង" និងកង្វះនូវភាពអព្យាក្រឹតចំពោះភស្តុតាង និងសេចក្តីសន្និដ្ឋានមួយចំនួន[109]។ ដូច្នេះ មេធាវីការពារក្តី

---

[107] រដ្ឋសភាជាតិកម្ពុជា "សម័យប្រជុំលើកទី១ នីតិកាលទី៣នៃរដ្ឋសភាជាតិកម្ពុជា ថ្ងៃទី ៤-ថ្ងៃទី ៥ ខែ តុលា ឆ្នាំ ២០០៤ ៖ កិច្ចពិភាក្សាដេញដោល និងការអនុម័តលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា និងកិច្ចពិភាក្សាដេញដោល និងការអនុម័តលើវិសោធនកម្មលើច្បាប់ស្តីពីការកាត់សេចក្តីមេដឹកនាំខ្មែរក្រហម" ថ្ងៃទី ៥ ខែ តុលា ឆ្នាំ ២០០៤ ទំព័រ ២៥-២៦។

[108] Milan Markovic "ការជំនុំជម្រះរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ និងការប្តឹងជំទាស់ចៅក្រមដោយផ្អែកលើមូលដ្ឋាននៃសញ្ជាតិ" *Washington University Global Studies Law Review* ១៣(១) ឆ្នាំ ២០១៤ លេខយោងជើងទំព័រ ២៤៦។

[109] តុលាការ និងសាលាក្តីព្រហ្មទណ្ឌអន្តរជាតិបានសម្រេចដកចិត្តនាពេលមុនលើចៅក្រមដោយសារមានការលេចឡើងនូវភាពលម្អៀងដែលមិនអាចទទួលយកបាន ដែលកើតឡើងយ៉ាងមានប្រសិទ្ធភាពពីការខ្វះនូវភាពអាព្យាក្រឹត្យយ៉ាងច្បាស់ក្រឡែត។ នៅ

សូមសន្និដ្ឋានថា កាលៈទេសៈទាំងអស់នេះនាំឱ្យចៅក្រមជាតិលេចចេញនូវភាពលម្អៀងដែលមិនអាចទទួលយកបានដោយផ្អែកលើមូលដ្ឋានថា ចៅក្រមជាតិមានផលប្រយោជន៍ផ្ទាល់ខ្លួននៅក្នុងរឿងក្តីប្រឆាំងនឹង នួន ជា ហើយកំពុងធ្វើជាចៅក្រមជំនុំជម្រះលើរឿងក្តីខ្លួនឯងដោយមិនសមស្រប។

60. ការលេចចេញនូវភាពលម្អៀងរបស់ចៅក្រមជាតិ ត្រូវនឹងប្រភេទទីមួយនៃការលេចចេញនូវភាពលម្អៀងដូចបានបង្ហាញនៅក្នុងរឿងក្តី *Furundžija*[110] និងដូចបានពន្យល់នៅក្នុងរឿងក្តី *Pinochet*[111]៖ ភ័ស្តុតាងនៃភាពលម្អៀងជាលក្ខណៈបុគ្គលឃើញមានច្បាស់ ហើយជាលទ្ធផលវាអាចនាំឱ្យមានការដកចេញចៅក្រមជាតិ*ដោយស្វ័យប្រវត្តិ* ដោយពុំចាំបាច់ពិចារណាលើទស្សនៈវិស័យរបស់អ្នកសង្កេតការណ៍ដែលមិនលម្អៀងឡើយ។ ជាងនេះទៀត ប្រសិនបើមានការជំទាស់ថា ផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ចៅក្រមជាតិគឺជាប្រភេទទីមួយនៃការលេចចេញនូវភាពលម្អៀងដូចនៅក្នុងរឿក្តី *Furundžija* មែននោះ មេធាវីការពារក្តីសូមអះអាងថា ផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ចៅក្រមជាតិត្រូវនឹងប្រភេទទីពីរនៃការលេចចេញនូវភាពលម្អៀង ដូចនៅក្នុងរឿងក្តី *Furundžija* ដោយហេតុថា "កាលៈទេសៈនានាអាចនាំឱ្យអ្នកសង្កេតការណ៍មិនលម្អៀងម្នាក់ដែលបានទទួលព័ត៌មានសមស្របនោះ យល់ដឹងយ៉ាងសមហេតុផលអំពីភាពលម្អៀង"[112] ដូចបានពិភាក្សាចាប់ពីកថាខណ្ឌ ៥៣ ដល់ ៥៨ ខាងលើ។ ជាក់ស្តែង ផលប្រយោជន៍ផ្ទាល់ខ្លួនរបស់

---

សាលាក្តី ICTY ចៅក្រម Harhoff ត្រូវបានដិតចិត្តនាពេលថ្មីៗចេញពីរឿងក្តី Šešelj ដោយផ្អែកលើមូលដ្ឋាននៃយោបល់ដែលគាត់បានលើកឡើងនៅក្នុងលិខិតឯកជនថា វា "ជាការអនុវត្តរួម" នៅសាលាក្តី ICTY ក្នុងការសម្រេច (យ៉ាងត្រឹមត្រូវ តាមការយល់ឃើញរបស់ចៅក្រម) ឱ្យមេបញ្ជាការយោធាមានពិរុទ្ធភាពពីឧក្រិដ្ឋកម្មរបស់បុគ្គលិកក្រោមបង្គាប់របស់ពួកគេ ៖ *សូមមើល* រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង* Šešelj "សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តីស្នើសុំប្តឹងដិតចិត្តចៅក្រម Frederik Harhoff និងរបាយការដាក់ជូនអនុប្រធាន" រឿងក្តីលេខ IT-03-67-T ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១៣ កថាខណ្ឌ ១០-១១, ១៣។ នៅតុលាការ SCSL ចៅក្រម Robertson ត្រូវបានដិតចិត្តចេញពីរឿងក្តី *RUF* ដោយផ្អែកលើមូលដ្ឋាននៃសេចក្តីថ្លែងការណ៍យ៉ាងរំជើបរំជួលទាំងឡាយដែលគាត់បានលើកឡើងនៅក្នុងសៀវភៅរបស់គាត់ចំណងជើងថា *ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ៖ ការតស៊ូដើម្បីយុត្តិធម៌ពិភពលោក*ទាក់ទងនឹង RUF និងហេតុការណ៍នៅក្នុងយុត្តាធិការរបស់តុលាការ SCSL៖ *សូមមើល* រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Sesay និងអ្នកផ្សេងទៀត* "សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តីស្នើសុំប្តឹងដិតចិត្តចៅក្រម Robertson ចេញពីអង្គជំនុំជម្រះតុលាការកំពូល រឿងក្តីលេខ SCSL-04-15-AR ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៤។

[110] សាលក្រមរឿងក្តី Furundžija កថាខណ្ឌ ១៨៩។

[111] សាលក្រមរឿងក្តី Pinochet។

[112] សាលក្រមរឿងក្តី Furundžija កថាខណ្ឌ ១៨៩។

ចៅក្រមជាតិអាចថែមទាំងជាការលម្អៀងជាក់ស្ដែងតែម្ដង ដោយសារថា ប្រសិនបើយកតាមរឿងក្ដី *Kyprianou*[113] សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារក្ដីត្រង់កថាខណ្ឌ ៥៧ ដល់ ៥៨ ក៏ទុកសម្រាប់ជាការតវ៉ាលើសច្ចធារណ៍នៃភាពអព្យាក្រឹតរបស់ចៅក្រមជាតិផងដែរ[114] ហើយវាបានបង្ហាញជាភាពលម្អៀងជាក់ស្ដែងតែម្ដង។ មិនថាវាជាការលេចចេញនូវភាពលម្អៀង ឬភាពលម្អៀងជាក់ស្ដែង ផលវិបាកដែលនឹងកើតឡើងគឺដូចតែគ្នា ៖ ចៅក្រមជាតិគួរត្រូវបានដកចេញពីកិច្ចដំណើរការនីតិវិធីផ្សេងទៀតនៅក្នុងរឿងក្ដី នួន ជា។

## ឃ. ការប្រើប្រាស់ភាសាជាក់លាក់របស់ចៅក្រមនៅក្នុងសាលក្រមសំណុំរឿង ០០២/០១ នាំឱ្យមានការលេចចេញនូវភាពលម្អៀងដោយមិនអាចទទួលយកបាន

61. នៅក្នុងផ្នែកនេះ មេធាវីការពារក្ដីចោទប្រកាន់ថា មូលដ្ឋាននៃបណ្ដឹងជំទាស់ចិត្តអនុវត្តចំពោះគ្រប់ចៅក្រមទាំងអស់ ពុំមែនតែចំពោះចៅក្រមជាតិនោះទេ។ ជាពិសេស មេធាវីការពារក្ដីសន្និដ្ឋានថា នៅក្នុងសាលក្រមសំណុំរឿង ០០២/០១ ចៅក្រមបានបង្ហាញឱ្យឃើញពីកង្វះជាមូលដ្ឋាននូវភាពអព្យាក្រឹតចំពោះភ័ស្ដុតាង ឬសេចក្ដីសន្និដ្ឋានលើបញ្ហាជាច្រើន[115] ដែលបាននាំឱ្យលេចចេញនូវភាពលម្អៀងដែលមាននាពេលបច្ចុប្បន្ននេះ ហេតុដូច្នេះចៅក្រមទាំងនេះគួរតែត្រូវបានដកចេញ។ ដោយហេតុថា បញ្ហាទាំងនេះមានភាពពាក់ព័ន្ធនឹងកម្មវត្ថុសម្រាប់សំណុំរឿង ០០២/០២[116] កង្វះនូវភាពអព្យាក្រឹតរបស់ចៅក្រម ក៏នឹងនាំឱ្យមានការលេចចេញនូវភាពលម្អៀងនាពេលខាងមុខនៅក្នុងសំណុំរឿង ០០២/០២ ដែលជាមូលហេតុយកមកប្រើសម្រាប់ដកចេញចៅក្រមផងដែរ។ បញ្ហាទាំងឡាយដែលចៅក្រមបានបង្ហាញឱ្យឃើញពីកង្វះនៃភាពអព្យាក្រឹត គឺបញ្ហានៃការគំរាមកំហែងពីខ្មាំងផ្ទៃក្នុង និងខ្មាំងខាងក្រៅ គោលនយោបាយ និងសកម្មភាពរបស់បក្សកុម្មុយនីស្ដកម្ពុជាសកម្មភាព និងនយោបាយរបស់របប លន់ នល់ និងតួនាទីរបស់សម្ដេចឪព្រះនរោត្តម សីហនុ។

62. កង្វះនូវភាពអព្យាក្រឹតរបស់ចៅក្រមអាចត្រូវបានមើលឃើញតាមរយៈការប្រើប្រាស់ពាក្យបច្ចេកទេសចំនួនបួនបែប ៖ (i) គុណនាមស្រពិចស្រពិល ដូចជា *ដែលត្រូវបានអះអាង* ឬ *ដែលត្រូវបាន*

[113] សាលក្រមរឿងក្ដី Kyprianou កថាខណ្ឌ ១៣០។

[114] សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើរឿងក្ដី RUF កថាខណ្ឌ ៩។

[115] សាលក្រមរឿងក្ដី Akayesu កថាខណ្ឌ ២៦៩។ សាលក្រម Nahimana កថាខណ្ឌ ៧៨។

[116] មតិយោបល់របស់ចៅក្រម Buergenthal កថាខណ្ឌ ១១, ១៣។

*យល់ឃើញ* យកមកពិពណ៌នាភស្តុតាង (ii) សញ្ញាអម្ពត្តរៈឌឹងដោយបញ្ជាក់ថា ចៅក្រមមិនយល់ស្របជាមួយនឹងន័យត្រង់នៃពាក្យដែលពួកគាត់បានប្រើប្រាស់ ដូចជា "ខ្មាំង" (iii) ការជ្រើសរើសប្រើប្រាស់សញ្ញាអម្ពត្តរៈដើម្បីបង្ហាញអំពីមន្ទិលសង្ស័យចំពោះភស្តុតាង ឧទាហរណ៍ នៅក្នុងការសម្រេចថា "ស្រុកបានរាយការណ៍ទៅតំបន់អំពីបញ្ហានានា ដូចជា ការលើកទំនប់ ជីកប្រឡាយ ការបង្កបង្កើនផល សុខាភិបាល និង "*សមាសភាពល្អ និង មិនល្អ*"[117] និង (iv) នាមប្រមាថមើលងាយ ដូចជា *ការបិទបាំង*។

63. ***ការគំរាមកំហែងពីខ្មាំងផ្ទៃក្នុង និងខ្មាំងខាងក្រៅ*** ៖ អ្វីដែលគួរឱ្យកត់សម្គាល់បំផុតនោះគឺសាលក្រមសំណុំរឿង ០០២/០១ លាតត្រដាងឱ្យឃើញអំពីភាពមិនជឿជាក់របស់ចៅក្រមថា បក្សកុម្មុយនីស្តកម្ពុជាបានប្រឈមនឹងការគំរាមកំហែងជាក់ស្តែងមួយពីខ្មាំងផ្ទៃក្នុង និងខ្មាំងខាងក្រៅ - បញ្ហាមួយនេះគឺជាបញ្ហាចម្បងនៃរឿងក្តីរបស់ នួន ជា[118] ទាំងមូល និង ជាពិសេសទៅក្នុងសំណុំរឿង ០០២/០២។ នៅក្នុងសាលក្រមសំណុំរឿង ០០២/០១ ចៅក្រមបានយោងចំនួន ១០ ដង លើ *អ្នកដែលត្រូវបានអះអាង ឬ ដែលត្រូវបានយល់ឃើញថាជា*ខ្មាំងផ្ទៃក្នុង និងខ្មាំងខាងក្រៅ[119]។ ចៅក្រមបានប្រើសញ្ញាអម្ពត្តរៈចំនួន ៩ ដង សំដៅលើ "ខ្មាំង" "សមាសភាពមិនល្អ" "គេញ" "ជនក្បត់" ឬ "ការឈ្លានពាន"[120]។ ចៅក្រមបានជ្រើសរើសប្រើប្រាស់សញ្ញាអម្ពត្តរៈចំនួន ៤ ដង ដើម្បីបញ្ជាក់អំពីមន្ទិលសង្ស័យលើភស្តុតាង[121]។ ក្រៅពីឧទាហរណ៍ដែលបានយោងនៅក្នុងកថាខណ្ឌ ៦២ ខាងលើ មានពេលមួយនោះ ចៅក្រមបានសង្ខេបភស្តុតាងរបស់សាក្សីពាក់ព័ន្ធនឹងរបាយការណ៍ដែលសាក្សីបានទទួលលម្អិតអំពី "បញ្ហាកសិកម្ម គម្រោងសាងសង់ ការសម្រេចទិសដៅ

---

[117] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ២៨៤ (គូសបញ្ជាក់បន្ថែម)។

[118] ឯកសារ E295/6/3 សារណាបញ្ចប់ការពិភាក្សាដេញដោលរបស់មេធាវីការពារក្តីលើសំណុំរឿង ០០២/០១ កថាខណ្ឌ ៨, ២០០។ ឯកសារ E1/232.1 "ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ ៖ ថ្ងៃជំនុំជម្រះទី ២១៩ ("សារណាបញ្ចប់ការពិភាក្សាដេញដោលដោយផ្ទាល់មាត់របស់មេធាវីការពារក្តីថ្ងៃទី១") ទំព័រ ២៤ ជួរ ៧, ២១-២៥ ទំព័រ ២៦ ជួរ ១៥ ទំព័រ ២៨ ជួរ ៣-១១។

[119] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១១៧, ១១៨, ១៩៥, ១៩៩, ២៥៦, ២៧៨, ៥២៦, ៧៩៥ និងលេខយោងជើងទំព័រ ២៨៧, ១៥៧៩។ ទោះបីជាយ៉ាងនេះក៏ដោយ មេធាវីការពារក្តីកត់សម្គាល់ឃើញថា មេធាវីការពារក្តីបានរកឃើញយ៉ាងហោចណាស់ករណីលើកលែងមួយលើបញ្ហានេះ៖ *សូមមើល* កថាខណ្ឌ ២៩៨។

[120] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១១៧, ១២១, ២២១, ២៥៣, ៣៨៣, ៩០៨ (ពីរដង), ១០៦២, ១០៩៣។

[121] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ២៨៤, ២៨៨, ៣៨៣, ៩៩៨។

"*កំហុសឆ្គងរបស់ប្រជាជនខ្លះ*" កង្វះស្បៀងអាហារ និងចំនួនអ្នកឈឺ"[122]។

64. ការមិនជឿជាក់របស់ចៅក្រមថា បក្សកុម្មុយនីស្តកម្ពុជាបានប្រឈមនឹងការគំរាមកំហែងជាក់ស្តែងមួយពីខ្មាំង អាចមើលឃើញច្បាស់បំផុតនៅក្នុងសាលក្រមសំណុំរឿង 00២/0១ ដែលបានច្រានចោលលទ្ធភាពនៃការគំរាមកំហែងជាក់ស្តែងពីប្រទេសវៀតណាម។ ករណីនេះពុំមែនត្រឹមតែផ្ទុយជាមួយនឹងទឡ្ហីករណ៍របស់មេធាវីការពារក្តី[123] និងការពិភាក្សាយ៉ាងលម្អិតនៅក្នុងឯកសារទាំងឡាយដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ[124] អំពីការគំរាមកំហែងជាក់ស្តែងនៃការឈ្លានពានរបស់វៀតណាមប៉ុណ្ណោះទេ វាថែមទាំងផ្ទុយនឹងមតិទស្សនៈរបស់សហគមន៍អន្តរជាតិផងដែរ[125]។ ឧទាហរណ៍ ចៅក្រមបានប្រើប្រាស់សញ្ញាអម្ពត្តរះខឹងដើម្បីយោងលើ ""ការឈ្លានពាន" របស់ប្រទេសវៀតណាម"[126] និងបានពិពណ៌នាប្រទេសវៀតណាមថាជារដ្ឋមួយដែលបក្សកុម្មុយនីស្តកម្ពុជា "*ចាត់ទុក* [...] ថាជាគូប្រជែង និងជាការគំរាមកំហែងមួយ ត្រង់ចំណុចដែល[ពួកគេ]*ត្រូវបានចោទប្រកាន់ថា*បានស្វះស្វែងពង្រីកផលប្រយោជន៍កុម្មុយនីស្តផ្ទាល់ខ្លួន[របស់ពួកគេ]នៅក្នុងប្រទេសកម្ពុជា"[127]។

---

[122] ឯកសារ E313 សាលក្រមសំណុំរឿង 00២/0១ កថាខណ្ឌ ២៨៨។

[123] *សូមមើល ឧ.* ឯកសារ E295/6/3 សារណាបញ្ចប់ការពិភាក្សាដេញដោលរបស់មេធាវីការពារក្តីលើសំណុំរឿង 00២/0១ កថាខណ្ឌ ២០, ២៦, ១៨៣-១៨៨។

[124] *សូមមើល ឧ.* ឯកសារ E3/2376 សត្រូវបងប្អូនឯង។ ឯកសារ E3/1684 សំឡេងពីមន្ទីរ ស-២១។

[125] *សូមមើល ឧ.* ឯកសារ E307/5.2.2 កំណត់ហេតុផ្លូវការរបស់ក្រុមប្រឹក្សាសន្តិសុខនៃ អ.ស.ប "កិច្ចប្រជុំថ្ងៃទី ១១ ខែ មករា ឆ្នាំ ១៩៧៩" ឯកសារ អ.ស.ប លេខ S/PV.2108 ដែលនៅក្នុងឯកសារនេះ ការឈ្លានពានរបស់វៀតណាមចូលក្នុងរបបកម្ពុជាប្រជាធិបតេយ្យក្នុងខែ មករា ឆ្នាំ ១៩៧៩ ត្រូវបានពិពណ៌នាខុសៗគ្នាដោយសហគមន៍អន្តរជាតិ រួមទាំងសមាជិកអចិន្ត្រៃយ៍ចំនួនពីររបស់ក្រុមប្រឹក្សាសន្តិសុខនៃ អ.ស.ប ថាជា "ការឈ្លានពានប្រដាប់អាវុធទ្រង់ទ្រាយធំលើប្រទេសទន់ខ្សោយ" (ដោយឯកអគ្គរដ្ឋទូតចិន ត្រង់កថាខណ្ឌ ១៨) និង "ការឈ្លានពាន" (ដោយនាយករដ្ឋមន្ត្រីអូស្ត្រាលី និងអ្នកនាំពាក្យនៃក្រសួងការបរទេសអាមេរិក ត្រង់កថាខណ្ឌ ៨៨) និងជា "ការគំរាមកំហែងដល់សន្តិភាព" (ដោយរដ្ឋមន្ត្រីក្រសួងកិច្ចការក្រៅប្រទេស ត្រង់កថាខណ្ឌ ៨៨)។ ជាការពិតគ្មានអ្នកចូលរួមនៅក្នុងកិច្ចប្រជុំនេះធ្វើការរិះគន់ខ្លាំងជាងសម្តេចឪ ស៊ីហនុ ដែលសម្តែងពីការសោកស្តាយចំពោះ "អំពើឈ្លានពានជាក់ស្តែងទ្រង់ទ្រាយធំដោយសាធារណៈរដ្ឋសង្គមនិយមវៀតណាម [...] ដែលគោលបំណងរបស់ខ្លួនមិនមានអ្វីក្រៅតែពីលេបយកទឹកដីដ៏តូចរបស់កម្ពុជានោះទេ មិនខុសគ្នាពីពស់ថ្លាន់ដែលកំពុងស្រេកឃ្លានគ្រវីគ្រវាត់សត្វនោះទេ"។ សូមមើល នៅកថាខណ្ឌ 73, 75, 80-87។

[126] ឯកសារ E313 សាលក្រមសំណុំរឿង 00២/0១ កថាខណ្ឌ ៣៨៣។

[127] ឯកសារ E313 សាលក្រមសំណុំរឿង 00២/0១ លេខយោងជើងទំព័រ ១៥៧៩ (គូសបញ្ជាក់បន្ថែម)។

65. ***គោលនយោបាយ និងសកម្មភាពរបស់បក្សកុម្មុយនីស្តកម្ពុជា៖*** សាលក្រមសំណុំរឿង ០០២/០១ ក៏លាតត្រដាងឲ្យឃើញអំពីការស្អប់ខ្ពើមជាទូទៅរបស់ចៅក្រមចំពោះគោលនយោបាយ និង សកម្មភាពរបស់បក្សកុម្មុយនីស្តកម្ពុជាផងដែរ។ ឧទាហរណ៍ ការយោងចំនួនបួនលើកអំពីការ រំដោះទីក្រុង និងទីប្រជុំជនដោយបក្សកុម្មុយនីស្តកម្ពុជាបានបង្ហាញនៅក្នុងសញ្ញាអម្ពុត្តរៈខឹដងថាជា "ការរំដោះ"[128]។ តាមការពិត ចៅក្រមបានពន្យល់យ៉ាងច្បាស់ថា ពួកគាត់ពុំយល់ស្របជាមួយ បក្សកុម្មុយនីស្តលើអត្ថន័យនៃពាក្យនេះទេ[129]។ ចៅក្រមក៏បានមើលស្រាលលើជោគជ័យដែលបក្ស កុម្មុយនីស្តបានអះអាងថាសម្រេចបានផងដែរ ដោយបានយោងចំនួនពីរដងលើ "សមិទ្ធផលដែល អះអាងថាសម្រេចបាន" ដោយបក្សកុម្មុយនីស្តកម្ពុជា[130] រួមទាំងនៅក្នុង "ការកសាងជាតិ និងការ កែលម្អជីវភាពរស់នៅ"[131]។

66. ***សកម្មភាព និងនយោបាយនៃរបប លន់ នល់៖*** ចៅក្រមក៏ហាក់ដូចជាព្យាយាមបន្ថយសកម្មភាព និងនយោបាយនៃរបប លន់ នល់ រហូតដល់កម្រិតអប្បបរមា ដែលបានធ្វើឲ្យបរិបទសង្គ្រាមស៊ីវិល មានភាពពាក់ព័ន្ធតិចតួចជាមួយនឹងរឿងក្តីនេះ។ តាមពិត បញ្ហាទាំងនេះមានភាពពាក់ព័ន្ធដោយ ជៀសមិនរួចនៅក្នុងសំណុំរឿង ០០២/០២។ នៅក្នុងសាលក្រមសំណុំរឿង ០០២/០១ ចៅក្រមបាន ព្យាយាមធ្វើដូច្នេះតាមរយៈការប្រើប្រាស់សញ្ញាអម្ពុត្តរៈខឹដង។ ឧទាហរណ៍ សាលក្រមបានយោង ចំនួនពីរដងលើការអំពាវនាវរបស់ សីហនុ ឲ្យចាប់ផ្តាក់ដឹកនាំ លន់ នល់ ដោយថាជា "ឧក្រិដ្ឋជន សង្គ្រាម"[132] នៅពេលដែលការហៅដូច្នេះអាចមានភាពត្រឹមត្រូវចំពោះការពិពណ៌នាក្នុងបរិបទ សង្គ្រាមស៊ីវិលតែប៉ុណ្ណោះ និងបានយោងចំនួនពីរដងលើ "ជោគជ័យ" របស់បក្សកុម្មុយនីស្តកម្ពុជា នៅឧត្តុង្គថាជាជោគជ័យផ្នែកយោធាសាមញ្ញមួយ[133]។

67. ***តួនាទីរបស់ សីហនុ៖*** ភាសាប្រើប្រាស់នៅក្នុងសាលក្រមសំណុំរឿង ០០២/០១ បានបង្ហាញច្បាស់ ថា ចៅក្រមច្រានចោលលទ្ធភាពនៃព្រះបរមសពសម្តេចឪ នរោត្តម សីហនុ និងអ្នកគាំទ្រទ្រង់

[128] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ២៨៨ (គូសបញ្ជាក់បន្ថែម)។

[129] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ លេងយោងជើងទំព័រ ៣៨៤ (គូសបញ្ជាក់បន្ថែម)។

[130] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ២៦៥, ៣៨៣ (គូសបញ្ជាក់បន្ថែម)។

[131] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ២៦៥, ៣៨៣។

[132] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៨២១, ៨២៤។

[133] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៨៧៩, ៩៩៩។

ថាអាចមានតួនាទីសំខាន់ជាងនេះនៅក្នុងអំឡុងដំណាក់កាលដំបូងនៃសម័យកម្ពុជាប្រជាធិបតេយ្យ ឬថា ស្ថាប័ននីតិប្រតិបត្តិនៃសម័យកម្ពុជាប្រជាធិបតេយ្យគ្មានអ្វីក្រៅពីជាមុខមាត់បិទបាំងមួយតែប៉ុណ្ណោះ។ ដូចបរិយាយលម្អិតពេញលេញនៅទីនេះ អត្ថិភាពនៃក្រុមប្រកួតប្រជែងគ្នានៃភាគីជម្លោះក្នុងបក្សកុម្មុនីស្តកម្ពុជា គឺជាធាតុផ្សំសំខាន់មួយរបស់ក្រុមមេធាវីការពារ នួន ជា នៅក្នុងករណី ០០២/០២។ ក្រុមមួយក្នុងចំណោមក្រុមទាំងនេះ គឺក្រុមដែលមានភក្តីភាពចំពោះព្រះមហាវីរក្សត្រ សីហនុ។ ចៅក្រមបានយោងចំនួន ៥ ដង លើប្រព័ន្ធរដ្ឋបាលរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាថាគ្រាន់តែជា*មុខមាត់បិទបាំង*មួយតែប៉ុណ្ណោះ[134]។ ចៅក្រមក៏បានពិពណ៌នាសមាជជាតិនៃរណសិរ្សរួបរួមជាតិកម្ពុជាដែល "ត្រូវបានអះអាងថាបានប្រព្រឹត្តទៅនៅថ្ងៃទី ២៤ និង ២៥ ខែ កុម្ភៈ" ឆ្នាំ ១៩៧៥[135]។ ប្រសិនបើចៅក្រមជឿថា រដ្ឋាភិបាល GRUNK មានតែឈ្មោះ ហើយដូច្នេះសញ្ញាណដែលថាអង្គសំខាន់របស់បក្សកុម្មុនីស្តកម្ពុជា គឺក្រុមដែលមានភក្តីភាពចំពោះរដ្ឋាភិបាល GRUNK ដែលត្រូវបានវិនិច្ឆ័យនិងបដិសេធរួចហើយ។

68. ក្រោយពីបានពិនិត្យមើលទិដ្ឋភាពទាំងនេះនៅក្នុងសាលក្រមសំណុំរឿង ០០២/០១ រួចមក មេធាវីការពារក្តីសូមសន្និដ្ឋានថា ផ្នែកផ្សេងទៀតនៃសុន្ទរកថារបស់ចៅក្រម Cartwright នៅវិទ្យាស្ថាន Aspen មានភាពពាក់ព័ន្ធនៅក្នុងពេលនេះ។ ជាពិសេស នៅក្នុងសុន្ទរកនោះ ចៅក្រម Cartwright បានប្រដូច នួន ជា និង ខៀវ សំផន ថាជា "ជនផ្តាច់ការ"[136]។ ចៅក្រម Cartwright បានច្រានចោលទឡ្ហីករណ៍របស់ជនត្រូវចោទថា "មិនពិត" ដែលទឡ្ហីករណ៍នេះបានលើកឡើងថា សេចក្តីសម្រេចរបស់ពួកគេបានធ្វើឡើងដោយសេចក្តីស្រលាញ់ប្រជាជន ដោយចៅក្រម Cartwright បាននិយាយថា សេចក្តីសម្រេចទាំងនោះបានបង្ហាញយ៉ាងច្បាស់អំពី "ទស្សនៈវិទ្យាដ៏គួរឲ្យព្រឺក្បាល" "គំនិតអាក្រក់" "មនោគមន៍វិជ្ជា" និង "កង្វះការយកចិត្តទុកដាក់លើប្រជាជន" របស់ជនត្រូវចោទ"[137] ព្រមទាំងបានច្រានចោលព័ត៌មាន និងភ័ស្តុតាងដែលអាចស៊ីសង្វាក់គ្នាជាមួយនឹងរឿងក្តីរបស់ជនជាប់ចោទថា "ពុំដែលបានធ្លាប់ឮ" ឬ ផ្តល់ចម្លើយដោយសាក្សីណាមួយ "តែតាមពិត

---

[134] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ២៣០, ២៣៤, ៣២០, ៧៣១, ៧៣២។ ទោះបីជាយ៉ាងនេះក៏ដោយ ករណីលើកលែងមួយចំពោះបញ្ហានេះអាចឃើញលើកឡើងនៅត្រង់កថាខណ្ឌ ៧៣១ នៅពេលចៅក្រមទំនងជាយោងដោយពុំមានការឌឹងលើ "កងទ័ពរបស់បក្សកុម្មុយនីស្តកម្ពុជា/រណសិរ្សរួបរួមជាតិកម្ពុជា/កងទ័ពប្រជាជនរំដោះជាតិកម្ពុជា"។

[135] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៧០, ៣៧៧។

[136] ឯកសារ E350/12.38R សុន្ទរកថានៅវិទ្យាស្ថាន Aspen ម៉ោង ៥០:១០-៥១:១៦ ។

[137] ឯកសារ E350/12.38R សុន្ទរកថានៅវិទ្យាស្ថាន Aspen ម៉ោង ៥២:១៦-៥២:៤៣។

សាក្សីនេះជាសាក្សីអំពីមនោគមន៍វិជ្ជារបស់ជនជាប់ចោទយ៉ាងច្បាស់ក្រឡែត”[138] ហើយចំណុចចុងក្រោយ និងគួរឱ្យព្រួយបារម្ភនោះគឺចៅក្រម Cartwright បានពិពណ៌នាកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក ថា “តែប៉ុណ្ណឹងវាយុត្តិធម៌ហើយ” ដោយបានលើកឡើងថា “វាពិបាកនៅក្នុងបរិយាកាសនេះក្នុងការទទួលបាន “ការជំនុំជម្រះមួយប្រកបដោយភាពយុត្តិធម៌ទាំងស្រុងណាស់”[139]។

69. ក្រោយពីពិនិត្យមើលភាពស៊ីសង្វាក់គ្នារវាងមតិយោបល់ទាំងនេះ និងសំអាងហេតុផ្សេងៗគ្នានៅក្នុងសាលក្រមសំណុំរឿង ០០២/០១ ដូចបានរៀបរាប់លម្អិតនៅត្រង់កថាខណ្ឌ ៦៣ ដល់ ៦៧ ខាងលើ អ្នកសង្កេតការណ៍ដែលមិនលម្អៀងនឹងសន្និដ្ឋានថា យោបល់របស់ចៅក្រម Cartwright ឆ្លុះបញ្ចាំងនូវទស្សនៈយល់ឃើញរបស់ចៅក្រមទាំងអស់។ ដូច្នេះ យោបល់ទាំងនេះកាន់តែធ្វើឱ្យចៅក្រមខ្វះនូវភាពអព្យាក្រឹតទាក់ទងនឹងភ័ស្តុតាង និងសេចក្តីសន្និដ្ឋានមួយចំនួន ព្រមទាំងការស្អប់ខ្ពើមរបស់ចៅក្រមទាំងអស់គ្នាលើ នួន ជា និងមនោគមន៍វិជ្ជារបស់គាត់ ។ ក្រោយពីពិចារណាចំណុចទាំងអស់នេះរួមគ្នា ករណីនេះនាំឱ្យកើតមានការលេចចេញនូវភាពលម្អៀងដែលគួរតែត្រូវបានដកចេញ ។

70. កង្វះនូវភាពអព្យាក្រឹតរបស់ចៅក្រមទាក់ទងនឹងភ័ស្តុតាង និងសេចក្តីសន្និដ្ឋានមួយចំនួនអាចបញ្ជាក់ឱ្យឃើញថា ចៅក្រម*បានកំណត់ជាមុននូវ*ទស្សនៈយល់ឃើញដោយមិនសមរម្យអំពីរឿងក្តីរបស់ នួន ជា ជារួម[140] ក្រៅពី*ការធ្វើបុរេវិនិច្ឆ័យ*យ៉ាងជាក់ច្បាស់លើបញ្ហានានាពាក់ព័ន្ធនឹងកម្មវត្ថុនៃសំណុំរឿង ០០២/០២[141]។ អ្នកសង្កេតការណ៍ដែលមិនលម្អៀងអាចនឹងសន្និដ្ឋានថា បញ្ហាទាំងនេះនាំឱ្យកើតមាននូវការលេចចេញនៃភាពលម្អៀង ដែលមិនអាចទទួលបាននៅក្នុងចំណោមចៅក្រមក្នុងសំណុំរឿង ០០២/០២ ដែលជាថ្មីម្តងទៀតចៅក្រមគួរត្រូវដកចេញ។

---

[138] ឯកសារ E350/12.38R សុន្ទរកថានៅវិទ្យាស្ថាន Aspen ម៉ោង ៥៧:៣៩-៥៨:០៧, ៥៦:១០-៥៦:៣៨។

[139] ឯកសារ E350/12.38R សុន្ទរកថានៅវិទ្យាស្ថាន Aspen (គូសបញ្ជាក់បន្ថែម)។

[140] សាលក្រមនៅក្នុងរឿងក្តី Buscemi កថាខណ្ឌ ៦៨។

[141] មតិយោបល់របស់ចៅក្រម Buergenthal កថាខណ្ឌ ១៣។

**ង. កំហុសមួយចំនួននៅក្នុងសាលក្រមសំណុំរឿង ០០២/០១ បង្ហាញឱ្យឃើញនូវការលេចចេញនូវភាពលម្អៀងដែលមានស្រាប់ និងដែលមិនអាចទទួលយកបាន ដែលនឹងនាំឱ្យមានផលប៉ះពាល់លើសំណុំរឿង ០០២/០២**

71. នៅក្នុងផ្នែកនេះ មេធាវីការពារក្តីសូមសន្និដ្ឋានថា ការភ័ន្តច្រឡំមួយចំនួននៅក្នុងសាលក្រមនេះលាតត្រដាងពីការលេចចេញនូវភាពលម្អៀង ដែលមានស្រាប់ក្នុងចំណោមចៅក្រមទាំងអស់។ ដោយហេតុថា ភាពលម្អៀងនេះពាក់ព័ន្ធនឹងបញ្ហានានាដែលនឹងត្រូវជំទាស់នៅក្នុងសំណុំរឿង ០០២/០២ ហេតុដូច្នេះ ចៅក្រមគួរត្រូវបានដកចេញពីសំណុំរឿង ០០២/០២ នេះ។ នេះនឹងរងការចោទប្រកាន់ថា ចៅក្រមបានបង្ហាញនូវភាពលម្អៀងនេះតាមរយៈ ៖ (i) ការខកខានដោយមិនសមហេតុផល និងដោយមានការភ័ន្តច្រឡំក្នុងការឆ្លើយតបលើទៅនឹងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីអំពីអត្ថិភាពនៃការបាក់បែកផ្ទៃក្នុងរបស់បក្សកុម្មុយនីស្តកម្ពុជា (ii) ការសម្រេចដោយមិនសមហេតុផល និងដោយមិនចាំបាច់ថា បក្សកុម្មុយនីស្តកម្ពុជាមានគោលនយោបាយស្តីពីការដាក់បទបញ្ជាទាក់ទងនឹងអាពាហ៍ពិពាហ៍ (iii) ការខ្វះនូវភាពអព្យាក្រឹតចំពោះភ័ស្តុតាង និងសេចក្តីសន្និដ្ឋានទាក់ទងនឹងភ័ស្តុតាងអំពីប្រជាសាស្ត្រ និង (iv) ការផ្អែកលើសាលក្រមរឿងក្តី ឌុច ដើម្បីកំណត់និយមន័យលើពាក្យ "កម្ទេច"។

72. ដូចបានផ្តល់ទទ្បីករណ៍ខាងលើ នៅពេលសេចក្តីសម្រេចរបស់តុលាការបានផ្អែកលើភ័ស្តុតាងនៃភាពលម្អៀងដែលមានស្រាប់រួចទៅហើយនោះ អ្វីដែលត្រូវបង្ហាញគឺថា "សេចក្តីសម្រេចពិតជាបានបណ្តាលឱ្យមាន ឬត្រូវបានគេយល់ឃើញដោយសមហេតុផលថាមានបុរេវិនិច្ឆ័យប្រឆាំងនឹងអ្នកដាក់ពាក្យបណ្តឹង និងជាសេចក្តីសម្រេចដែលមិនពាក់ព័ន្ធទៅនឹងការអនុវត្តច្បាប់ដោយសុក្រឹត [...] ឬការវាយតម្លៃលើអង្គហេតុពាក់ព័ន្ធនានា"[142]។ ដំណើរការនេះគឺ *មិនមែន*ដើម្បីបង្ហាញថាតើសេចក្តីសម្រេចទាំងនោះ "អាចបង្កើតជាការភ័ន្តច្រឡំផ្នែកអង្គច្បាប់" ដែរ ឬទេ (ដែលជាកម្មវត្ថុនៃបណ្តឹងសាទុក្ខនេះ) នោះទេ *ក៏ប៉ុន្តែ* ដំណើរការនេះមានគោលបំណងដើម្បីបង្ហាញថាតើសេចក្តីសម្រេចដែលមានការភ័ន្តច្រឡំទាំងនោះ "អាចត្រូវបានគេយល់ឃើញយ៉ាងសមហេតុផលថាបាន

[142] ឯកសារ E55/4 សេចក្តីសម្រេចលើបណ្តឹងជំទាស់លើកទី១ កថាខណ្ឌ ១៣។ (សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើរឿងក្តី RUF) កថាខណ្ឌ ៦១-៦៣។

បង្កើតបានជាការលេចចេញនូវភាពលម្អៀង" ដែរឬទេ[143]។

## *(i) វចនាសម្ព័ន្ធនៃបក្សកុម្មុយនីស្តកម្ពុជា*

73. កំហុសដ៏ធ្ងន់ធ្ងរបំផុតដែលបង្ហាញចេញជាភ័ស្តុតាងនូវភាពលម្អៀងដែលមានស្រាប់នោះគឺចៅក្រមបានច្រានចោលភ័ស្តុតាង និងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីដែលបានលើកឡើងថា នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ភូមិភាគអាចមានលទ្ធភាព និងពិតជាបានបំពេញការងារដោយស្វយ័ត។ កំហុសដ៏ធ្ងន់ធ្ងរបំផុតបន្ទាប់មកទៀតគឺ ចៅក្រមខកខានក្នុងការឆ្លើយតបទៅនឹងទឡ្ហីករណ៍របស់មេធាវីការពារក្តីទាក់ទងនឹងការបាក់បែកផ្ទៃក្នុងដែលមានលក្ខណៈដោយឡែកពីគេ និងដែលធ្វើឲ្យមានភាពរង្គោះរង្គើនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ពោលគឺ បញ្ហាទាំងនេះហើយដែលជាចំណុចស្នូលនៃរឿងក្តីរបស់មេធាវីការពារក្តីនៅក្នុងសំណុំរឿង ០០២/០២ ប៉ុន្តែបញ្ហាទាំងនេះត្រូវបានគូសបង្ហាញរួចហើយនៅក្នុងសំណុំរឿង ០០២/០១[144]។

74. នៅក្នុងសំណុំរឿង ០០២/០១ មេធាវីការពារក្តីបានផ្តល់ទឡ្ហីករណ៍ថា នួន ជា មិនអាចត្រូវបានសម្រេចថាបានធ្វើសកម្មភាពនៅក្នុងសហឧក្រិដ្ឋកម្មរួមជាមួយនឹងចារីនៃឧក្រិដ្ឋកម្ម ដូចបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០១ នោះទេ ពីព្រោះចារី "គឺជាអ្នកធ្វើសកម្មភាពដោយឯករាជ្យ ឬស្ថិតនៅក្រោមបញ្ជាការរបស់មេដឹកនាំភូមិភាគនៅក្រៅរង្វង់នៃការគ្រប់គ្រងរបស់ នួន ជា"[145]។ សារណាបញ្ចប់ការពិភាក្សាដេញដោលរបស់មេធាវីការពារក្តីនៅក្នុងសំណុំរឿង ០០២/០១ បានបង្ហាញភ័ស្តុតាងគាំទ្រលម្អិតរួចហើយអំពីស្វយ័តភាពរបស់ភូមិភាគដែលមានទំនាក់ទំនងជាមួយនឹងឧក្រិដ្ឋកម្មដូចបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០១ រួមទាំង *ក្នុងចំណោមនោះ* សក្ខីកម្មរបស់សាក្សី និងចម្លើយរបស់អ្នកជំនាញ ដែលអង្គជំនុំជម្រះបានដកស្រង់មកប្រើប្រាស់[146]។

---

[143] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើរឿងក្តី RUF កថាខណ្ឌ ៦៣។

[144] ឯកសារ E295/6/3 សារណាបញ្ចប់ការពិភាក្សាដេញដោលរបស់មេធាវីការពារក្តីលើសំណុំរឿង ០០២/០១ កថាខណ្ឌ ៨, ២០០។ ឯកសារ E1/232.1 សារណាបញ្ចប់ការពិភាក្សាដេញដោលដោយផ្ទាល់មាត់របស់មេធាវីការពារក្តីថ្ងៃទី១ ទំព័រ ២៤ ជួរ ៧, ២១-២៥ ទំព័រ ២៦ ជួរ ១៥ ទំព័រ ២៨ ជួរ ៣-១១។

[145] ឯកសារ E295/6/3 សារណាបញ្ចប់ការពិភាក្សាដេញដោលរបស់មេធាវីការពារក្តីលើសំណុំរឿង ០០២/០១ កថាខណ្ឌ ៣០៥។

[146] *សូមមើល ឧ.* ឯកសារ E295/6/3 សារណាបញ្ចប់ការពិភាក្សាដេញដោលរបស់មេធាវីការពារក្តីលើសំណុំរឿង ០០២/០១ កថាខណ្ឌ ៣០៧-៣០៩, ៤៣៥, ៤៣៧។

75. ឧទាហរណ៍ នៅក្នុងអំឡុងពេលនៃការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលដោយផ្ទាល់មាត់ និងជាសាធារណៈរបស់មេធាវីការពារក្តីនៅក្នុងសំណុំរឿង ០០២/០១ មេធាវីការពារក្តីបានបង្ហាញផ្នែកខ្លះនៃទឡ្ហីករណ៍នេះដូចខាងក្រោម ៖

*[ការ]ពិតដែលកើតឡើងមុនថ្ងៃ ១៧ មេសា ឆ្នាំ ៧៥ គឺថា វាមានផ្នែកពីរសំខាន់នៅក្នុងបក្សកុម្មុយនីស្តកម្ពុជាផងដែរ។* ផ្នែកទាំងពីរនោះគឺ [សោ] ភឹម ហើយនឹង រស់ ញឹម ដែលធ្វើការដឹកនាំចលនាប្រឆាំងនឹងមជ្ឈិមបក្ស។ *ចលនាទាំងពីរនេះគឺព្យាយាមដើម្បីធ្វើវិទ្ធង្សនាចំពោះគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ចាប់តាំងពីការជម្លៀសប្រជាជនចេញពីទីក្រុងត្រូវបានបញ្ចប់មកម្ល៉េះ។* ទំហំនៃការក្បត់របស់សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ [សោ] ភឹម រស់ ញឹម វន វ៉េត និងកុយ ធួន ដែលទទួលបានការគាំទ្រពីវៀតណាម ហើយបន្ទាប់មកត្រូវបានគាំទ្រដោយសមាជិកមានលំដាប់ថ្នាក់ទី១ ទី២ និងទី៣ នៃរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ន មិនត្រូវបានដឹងឮឡើយ រហូតដល់ ១៩៧៧ ឬក៏៧៨ ប៉ុន្តែហេតុការណ៍ទាំងអស់នេះកើតឡើងមុនពេលនេះជាយូរមកហើយ [...][147]។

វាប្រាកដណាស់ថា *មេដឹកនាំភូមិភាគ គឺត្រូវបំពេញការងារដោយស្វ័យភាព* និងតាមឆន្ទានុសិទ្ធិទូលំទូលាយ ប៉ុន្តែប្រការនេះមិនជាអ្វីដែលសំខាន់បំផុតដែលទាក់ទងនឹង រស់ ញឹម និង [សោ] ភឹម។ ការពិតដ៏សំខាន់បំផុតអំពី រស់ ញឹម និង [សោ] ភឹម គឺថា ពួកគេគឺជាសមាជិកដឹកនាំ និងសមាជិកស្ថាបនិករបស់បក្សកុម្មុយនីស្តកម្ពុជា ប៉ុន្តែពួកគេ*ជំទាស់យ៉ាងខ្លាំងក្លាទៅនឹង ប៉ុល ពត និង នួន ជា* ដែលដំបូងជំទាស់ដោយសម្ងាត់ទេ ប៉ុន្តែក្រោយមកជំទាស់ដោយចំហ។ ការពិតសំខាន់អំពី រស់ ញឹម និង [សោ] ភឹម គឺថា*បក្សកុម្មុយនីស្តកម្ពុជាមិនមែនជាស្ថាប័នមួយដែលមានការឯកភាពគ្នាតែមួយនោះទេ*[148]។

76. មេធាវីការពារក្តីក៏បានផ្តល់ទឡ្ហីករណ៍អំពីភាពពាក់ព័ន្ធដោយផ្ទាល់នៃស្វយ័តភាពរបស់ភូមិភាគ និងការបាក់បែកផ្ទៃក្នុងបក្សកុម្មុយនីស្តកម្ពុជាជាមួយនឹង ឧទាហរណ៍ ឧក្រិដ្ឋកម្មដែលត្រូវបានចោទ

---

[147] ឯកសារ E1/232.1 សារណាបញ្ចប់ការពិភាក្សាដេញដោលដោយផ្ទាល់មាត់របស់មេធាវីការពារក្តីថ្ងៃទី១ ទំព័រ ២៤ ជួរ ៦-១៧ (គូសបញ្ជាក់បន្ថែម)។

[148] ឯកសារ E1/232.1 សារណាបញ្ចប់ការពិភាក្សាដេញដោលដោយផ្ទាល់មាត់របស់មេធាវីការពារក្តីថ្ងៃទី១ ទំព័រ ២៥ ជួរ ១១-១៧ (គូសបញ្ជាក់បន្ថែម)។

ប្រកាន់នៅទួលពោធិ៍ជ្រៃ[149]។ បញ្ហាទាំងនេះត្រូវបានយកមកពិភាក្សាលម្អិតរួចហើយនៅក្នុងឯកសារទាំងឡាយដែលចៅក្រមបានដកស្រង់យកតាម[150]។ ពោលគឺ ចៅក្រមខកខានក្នុងការឆ្លើយតបទៅនឹងលទ្ធភាពនៃការបាក់បែកផ្ទៃក្នុងបក្សកុម្មុយនីស្តកម្ពុជានៅក្នុងសាលក្រមលសំណុំរឿង ០០២/០១។

77. ផ្ទុយមកវិញ ចៅក្រមបានសម្រេចថា នួន ជា បានចូលរួមជាមួយនឹង សោ ភឹម រស់ ញឹម វន វេត និង កុយ ធួន ដែលជាបុគ្គលដដែលដែលមេធាវីការពារក្តីបានកំណត់អត្តសញ្ញាណថាជាសមាជិកសំខាន់ៗនៃគូសត្រូវផ្ទៃក្នុងរបស់បក្សកុម្មុយនីស្តកម្ពុជានៅក្នុងសហឧក្រិដ្ឋកម្មរួម[151] ដើម្បី "បង្កើតបដិវត្តន៍សង្គមនិយមយ៉ាងឆាប់រហ័សតាមរយៈមធ្យោបាយចាំបាច់តាម "សន្ទុះមហាលោតផ្លោះ" និងដើម្បីការពារបក្សប្រឆាំងនឹងខ្មាំងផ្ទៃក្នុង ក៏ដូចជាខ្មាំងខាងក្រៅ"[152]។ ចៅក្រមក៏បានសម្រេចថា សោ ភឹម រស់ ញឹម និងបុគ្គលផ្សេងទៀត បានរាយការណ៍ទៅ និងអនុវត្តតាមបញ្ជា និងការណែនាំពី នួន ជា[153] ដែលទាំងអស់នេះស្ថិតនៅក្នុងបរិបទនៃបក្សកុម្មុយនីស្តកម្ពុជា ដែលចៅក្រមបានចាត់ទុកថាបក្សនេះមានរចនាសម្ព័ន្ធប្រមូលផ្តុំខ្ពស់ រាងពីរ៉ាមីត[154] និង "តឹងរ៉ឹង"[155]។ នៅក្នុងរចនាសម្ព័ន្ធនេះ នួន ជា ទំនងជា "បានអនុវត្តអំណាចតាមព្រឹត្តិហេតុ (*de facto*) លើកម្មាភិបាលខ្មែរក្រហមទាំងអស់ផងដែរ"[156] ហើយ ជាពិសេសនោះ យោងតាមចៅក្រម នួន ជា "បានប្រើប្រាស់សិទ្ធអំណាចតាមព្រឹត្តិហេតុ (*de facto*) ទៅលើ រស់ ញឹម" និង សោ ភឹម[157]។

---

[149] ឯកសារ E295/6/3 សារណាបញ្ចប់ការពិភាក្សាដេញដោលរបស់មេធាវីការពារក្តីលើសំណុំរឿង ០០២/០១ កថាខណ្ឌ ៤៨, ៩១៣, ៩៣៦-៩៣៧។

[150] *សូមមើល ឧ.* ឯកសារ E3/2376 ណាយ៉ាន់ ចាន់ដា "សត្រូវបងប្អូនឯង" ឆ្នាំ ១៩៨៦។ ឯកសារ E3/1684 David Chandler "សំឡេងពីមន្ទីរ ស-២១ ៖ ភាពព្រឺខ្លាច និងប្រវត្តិក្នុងគុកសម្ងាត់របស់ ប៉ុល ពត" ("សំឡេងពីមន្ទីរ ស-២១")។

[151] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៧៧៧, ៨៣៦, ៨៦៩។

[152] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៧៧៧។

[153] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៧៣៩, ៧៧៣, ៨០៧, ៨៤៨, ៩១៣, ៩៣៣, ៩៣៤, លេខយោងជើងទំព័រ ១៧៦០។

[154] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ២២៣។

[155] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៩១៣។

[156] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៩១៣។

[157] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៩៣៤។

78. ការរកឃើញដោយភាន់ច្រឡំទាំងនេះ គឺដោយសារតែការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងមិនកោះហៅបុគ្គលម្នាក់ដែលអាចនិយាយដោយផ្ទាល់ទៅកាន់ពួកគេ គឺ ហេង សំរិន។ ក្នុងតួនាទីជាមេបញ្ជាការរងកងពលរបស់ភូមិភាគបូ៌ា ថ្នាក់លើផ្ទាល់របស់ ហេង សំរិន គឺ ចាន់ ចក្រី ដែលភស្តុតាងចង្អុលបង្ហាញ យ៉ាងច្បាស់ថា គាត់ធ្វើសកម្មភាពសំងាត់យ៉ាងសកម្មប្រឆាំងនឹងមជ្ឈឹមបក្សតាំងពីឆ្នាំ១៩៧៥[158]។ ពិតណាស់ថ្នាក់លើផ្ទាល់របស់ ចក្រី គឺ សោ ភឹម។ ពិតណាស់វានឹងក្លាយរឿងគួរឱ្យអស្ចារ្យមួយប្រសិនបើការបះបោលដែលបរាជ័យរបស់ ចក្រី នៅឆ្នាំ១៩៧៥ ការបរាជ័យចុងក្រោយរបស់ សោ ភឹម នៅឆ្នាំ១៩៧៨ និងការសម្រេចចុងក្រោយរបស់វៀតណាមក្នុងការប្រើប្រាស់កំលាំងទ័ពរបស់ខ្លួនជាកំលាំងវាយលុកជាមួយ ហេង សំរិន គឺមិនទាក់ទងគ្នានោះ។ ហេតុដូច្នេះវាមានតែនៅក្នុងបរិបទនៃការ(មិន)រកឃើញ ដែលថាមូលហេតុសម្រាប់ភាពចចេសរបស់ចៅក្រមជាតិនៅពេលប្រឈមនឹងសារសំខាន់លើសលុបនៃការស្តាប់សក្ខីកម្មរបស់ ហេង សំរិន កាន់តែជាក់ច្បាស់។ វាប្រាកដណាស់ដើម្បីធានាថាការប្រឌិតឡើងនៃ ឋានុក្រមដែលមានលក្ខណៈឯកភាព និងតឹងរ៉ឹងរបស់បក្សកុម្មុនីស្តកម្ពុជា អាចទ្រទ្រង់ខ្លួនឯងបាន នោះក្រុមដែលលើកដំបូងដឹកនាំដោយ សោ ភឹម ហើយក្រោយមកដឹកនាំដោយ ហេង សំរិន អាចបន្តផ្ទេរការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មរបស់ខ្លួនទៅឱ្យ ប៉ុល ពត និង នួន ជា (រួមទាំងជនដែលប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងទាហានសាធារណរដ្ឋខ្មែរ និងជនជាតិចាម) ស្របពេលជាមួយគ្នាធ្វើឱ្យស្មុគ្រស្មាញនូវ "សុបិន្តអនុត្តរភាពតំបន់" របស់វៀតណាមដែលជាអ្នកឧបត្ថម្ភ[159]។

79. នៅពេលមិនធ្វើការឆ្លើយតប (និងជាក់ស្តែង មិនពិចារណា) ភស្តុតាង និងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីទាក់ទងនឹងការបាក់បែកផ្ទៃក្នុងបក្សកុម្មុយនីស្តកម្ពុជា ចៅក្រមបានបង្ហាញយ៉ាងច្បាស់លាស់អំពីកង្វះនូវភាពអព្យាក្រឹតលើបញ្ហាដ៏សំខាន់បំផុតនេះ។ សេចក្តីសន្និដ្ឋានតែមួយគត់ដែលបើកចំហចំពោះអ្នកសង្កេតការណ៍ដែលមិនលម្អៀងគឺថា ករណីនេះបានបង្កើតទៅជាការលេចចេញនូវភាពលម្អៀងដែលមានស្រាប់លើបញ្ហាដែលបន្តមានភាពពាក់ព័ន្ធ ដែលគួរដកចៅក្រមចេញ។

---

[158] ឯកសារ E295/6/3 សារណាបិទកិច្ចពិភាក្សាដេញដោលលើភស្តុតាងរបស់ក្រុមមេធាវីការពារ នៅកថាខណ្ឌ១៨៦។

[159] E307/5.2.2, កំណត់ហេតុផ្លូវការនៃការកិច្ចប្រជុំរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិនាថ្ងៃទី១១ ខែមករា ឆ្នាំ១៩៧៩", កថាខណ្ឌ 102 (សន្ទរកថារបស់តំណាងចិន)

80. ម្យ៉ាងវិញទៀត ការកខកខានដ៏មិនសមហេតុផលដោយចៅក្រមក្នុងការឆ្លើយតបទៅនឹងទឡ្ហីករណ៍របស់មេធាវីការពារក្តីអំពីអត្ថិភាពនៃការបាក់បែកផ្ទៃក្នុងរបស់បក្សកុម្មុយនីស្តកម្ពុជា បង្ហាញនូវទស្សនៈយល់ឃើញដែលបានកំណត់ជាមុន និងមិនផ្តល់ប្រយោជន៍ដល់រឿងក្តីរបស់មេធាវីការពារក្តី និងដល់ទឡ្ហីករណ៍ចម្បងចំពោះសំណុំរឿង ០០២/០២។ ឧទាហរណ៍ ការខកខាននេះទាក់ទងនឹងអត្ថិភាព និងលក្ខណៈនៃជម្លោះប្រដាប់អាវុធនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ សំអាងហេតុនៃសហឧក្រិដ្ឋកម្មរួមទាក់ទងនឹងការបោសសម្អាតផ្ទៃក្នុង និងមន្ទីរសន្តិសុខ និងមន្ទីរសន្តិសុខស-២១។ ដូច្នេះ ចៅក្រមគួរត្រូវបានដកចេញពីសំណុំរឿង ០០២/០២។

### *(ii) អត្ថិភាពនៃគោលនយោបាយទាក់ទងនឹងការដាក់បទបញ្ជាទាក់ទងនឹងអាពាហ៍ពិពាហ៍*

81. ផលវិបាកពិសេសមួយនៃការបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណុំរឿង ០០២ ទៅតាមវិធីមួយដែលអង្គជំនុំជម្រះសាលាដំបូងបានធ្វើឡើងគឺដើម្បីបំបែកការបង្កើតអត្ថិភាពនៃគោលនយោបាយ និងការអនុវត្តគោលនយោបាយទាំងនេះឲ្យដាច់ចេញពីគ្នា ទោះបីជាភស្តុតាងស្តីពីការអនុវត្តគោលនយោបាយទាំងនេះ មានសារៈសំខាន់ចំពោះការបង្កើតអត្ថិភាពនៃគោលនយោបាយទាំងនេះក៏ដោយ។ នៅក្នុងសាលក្រមសំណុំរឿង ០០២/០១ ការបំបែកកិច្ចដំណើរការនីតិវិធីបានបណ្តាលឲ្យមានសេចក្តីសម្រេចដោយពុំចាំបាច់ និងដោយមិនសមហេតុផលមួយ "បញ្ញត្តិស្តីពីការរៀបអាពាហ៍ពិពាហ៍ គឺជាគោលនយោបាយមួយរបស់បក្សកុម្មុយនីស្តកម្ពុជា"[160] ដោយផ្អែកលើភស្តុតាងរបស់សាក្សីថា ការរៀបអាពាហ៍ពិពាហ៍របស់ពួកគេត្រូវបានរៀបចំ។ ប្រសិនបើចៅក្រមអាចសម្រេចអំពីអត្ថិភាព នៃគោលនយោយដាក់បទបញ្ជាទាក់ទងនឹងអាពាហ៍ពិពាហ៍ ដោយផ្អែកលើភស្តុតាងនៃការកើតមានឡើងវិញនៃករណីទាំងនេះនៅតាមទីតាំងឧក្រិដ្ឋកម្ម នោះចៅក្រមមិនគួរសម្រេចទាល់តែសោះលើបញ្ហាណាមួយក្នុងចំណោមបញ្ហាទាំងពីរនេះ ដោយចៅក្រមគួររង់ចាំការធ្វើតេស្តលើភស្តុតាងអំពីទីតាំងឧក្រិដ្ឋកម្មជាមុនសិន ដែលនឹងធ្វើឡើងនៅពេលណាមួយនាពេលខាងមុខនៅក្នុងអំឡុងពេលនៃការជំនុំជម្រះលើសំណុំរឿង ០០២/០២។ ចៅក្រមគួរតែកុំសន្និដ្ឋានលើសំអាងហេតុទាំងនេះ ដូចដែលធ្លាប់បានធ្វើឡើងយ៉ាងត្រឹមត្រូវទាក់ទងនឹងបញ្ហាអត្ថិភាពនៃគោលនយោបាយកំណត់គោលដៅលើជនជាតិចាម ពុទ្ធសាសនិកជន និងជនជាតិវៀត

[160] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១៣០។

ណោម[161]។

82. ក្នុងចំណោមភ័ស្តុតាងដែលចៅក្រមបានផ្អែកលើដើម្បីធ្វើការសម្រេចលើអត្ថិភាពនៃគោលនយោបាយស្តីពីការដាក់បទបញ្ជាទាក់ទងនឹងអាពាហ៍ពិពាហ៍ គ្មានឯកសារណាមួយរបស់បក្សកុម្មុយនីស្តកម្ពុជាបានលើកឡើងថា គោលនយោបាយបែបនេះមានអត្ថិភាពនោះឡើយ[162]។ អត្ថិភាពនៃគោលនយោបាយក្នុងការបង្កើនចំនួនប្រជាជន[163] ពុំអាចប្រដូចគ្នាដោយជៀសមិនរួចនឹងអត្ថិភាពនៃគោលនយោបាយស្តីពីការដាក់បទបញ្ជាទាក់ទងនឹងអាពាហ៍ពិពាហ៍តែទាល់សោះ។

83. ភ័ស្តុតាងតែមួយគត់ដែលទំនងភ្ជាប់ទំនាក់ទំនងរវាងគោលនយោបាយស្តីពីចំនួនប្រជាជនជាមួយនឹងការដាក់បទបញ្ជាទាក់ទងនឹងអាពាហ៍ពិពាហ៍គឺចេញមកពីសក្ខីកម្មរបស់សាក្សី ជួន ធី (អតីតមេបញ្ជាការកងវរសេនាតូចនៃបក្សកុម្មុយនីស្តកម្ពុជា) និងមតិយោបល់របស់អ្នកជំនាញ Philip Short[164]។ មតិយោបល់របស់ Short ពុំបានយោងលើភ័ស្តុតាងដោយផ្ទាល់នានាថា ជាឯកសារសំអាងផ្លូវច្បាប់នោះឡើយ[165]។ ម្យ៉ាងវិញទៀត ភ័ស្តុតាងរបស់គាត់មានភាពច្បាស់លាស់អំពីថាតើការរៀបចំអាពាហ៍ពិពាហ៍ គឺជាគោលនយោបាយមួយពីមជ្ឈិមបក្សនៃបក្សកុម្មុយនីស្តកម្ពុជា ឬក៏យ៉ាងណា ឬវាគ្រាន់តែជាការអនុវត្តដែលបានប្រព្រឹត្តឡើងដោយកម្មាភិបាលមូលដ្ឋាន*ខ្លះ* តែប៉ុណ្ណោះដើម្បីអនុវត្តគោលនយោបាយរបស់បក្សស្តីពីចំនួនប្រជាជន។ តាមការពិត Short បានផ្តល់សក្ខីកម្មនៅក្នុងតុលាការថា ជីវភាពគ្រួសារមានភាពខុសគ្នាធំធេង "អាស្រ័យលើទីកន្លែងដែលអ្នករស់នៅក្នុងប្រទេសកម្ពុជា និងគោលនយោបាយដែលអនុវត្តដោយកម្មាភិបាល*មូលដ្ឋាន*"[166]។ សក្ខីកម្មរបស់ ជួន ធី លើអ្វីដែលគាត់បានឮពី ប៉ុល ពត នៅក្នុងពេលនោះ គឺគ្រាន់តែជាភ័ស្តុតាងចចាមអារ៉ាមតែប៉ុណ្ណោះ[167]។

---

[161] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១១៩។

[162] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១២៨-១២៩, ៧៧៣ លេខយោងជើងទំព័រ ៣៧១-៣៧៤។

[163] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១២៨ លេខយោងជើងទំព័រ ៣៧១។

[164] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១២៨ លេខយោងជើងទំព័រ ៣៧១។

[165] ឯកសារ E1/192.1 ប្រតិចារឹក ថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១៣ ទំព័រ ១១៩។ ឯកសារ E3/9 "ប៉ុល ពតៈ ប្រវត្តិនៃសុបិន្តអាក្រក់មួយ" ទំព័រ ៣២៥-៣២៦។

[166] ឯកសារ E1/190.1 ប្រតិចារឹក ថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០១៣ ទំព័រ ៩-១០ (គូសបញ្ជាក់បន្ថែម)។

[167] ឯកសារ E3/4593 "កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី" ចុះថ្ងៃទី ២ ខែ មីនា ឆ្នាំ ២០១០ ERN 00513314 (គូសបញ្ជាក់បន្ថែម)។

84. ចៅក្រមក៏បានបញ្ជាក់ផងដែរថា សេចក្តីសម្រេចរបស់ពួកគាត់បានផ្អែកលើអត្ថិភាពនៃ "ភ័ស្តុតាងមួយចំនួនដែលបានបង្ហាញយ៉ាងច្បាស់អំពីការរៀបអាពាហ៍ពិពាហ៍ដោយមិនស្ម័គ្រចិត្តនេះ"[168]។ ទោះបីជាយ៉ាងនេះក្តី អត្ថិភាពនៃហេតុការណ៍ "ខ្លះ" នៅទីកន្លែងទាំងនោះពុំពាក់ព័ន្ធនឹងគោលនយោបាយដែលបានអះអាងថាចេញមកពីមជ្ឈិមបក្សនោះឡើយ ជាពិសេសក្រោយពីបានស្តាប់ភ័ស្តុតាងរបស់ Short ដែលបានបង្កើតជាមូលដ្ឋាននៃសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ។ ភ័ស្តុតាងទាំងនេះបានលើកឡើងថា ស្ថានការណ៍មានភាពខុសៗគ្នាអាស្រ័យទៅតាមកម្មាភិបាលមូលដ្ឋាន។

85. អាស្រ័យហេតុនេះ មេធាវីការពារក្តីសូមសន្និដ្ឋានថា ការសម្រេចរបស់ចៅក្រមអំពីអត្ថិភាពនៃគោលនយោបាយនៃការដាក់បទបញ្ជាទាក់ទងនឹងរៀបអាពាហ៍ពិពាហ៍ គឺជាការភ័ន្តច្រឡំដោយសារការសម្រេចទាំងនេះមិនសមហេតុផល និងពុំមានភាពចំបាច់។ម្យ៉ាងវិញទៀត មេធាវីការពារក្តីសូមសន្និដ្ឋានបន្ថែមទៀតថា ការសម្រេចដូច្នេះបង្ហាញថា វាពុំមែន"ជាសេចក្តីសម្រេចដែលមិនពាក់ព័ន្ធទៅនឹងការអនុវត្តច្បាប់ដោយសុក្រឹត [...] ឬ ជាសេចក្តីសម្រេចដែលមិនពិចារណាវាយតម្លៃលើអង្គហេតុពាក់ព័ន្ធនានា"[169] នោះទេ ដោយសារចៅក្រមពុំទាន់បានស្តាប់ភ័ស្តុតាងស្តីពីការអនុវត្តគោលនយោបាយសំខាន់ៗទាំងនេះនៅឡើយ ទាក់ទងនឹងបញ្ហាណាមួយក្នុងចំណោមបញ្ហាទាំងពីរនេះ។ ទោះបីជាមេធាវីការពារក្តីពុំត្រូវធ្វើការទាយស្មានក៏ដោយ វាបានបង្ហាញឲ្យយើងឃើញថា ចៅក្រមបែរជាមានការភ័យខ្លាចថា តុលាការនឹងមិនអាចចេញសាលក្រមលើហេតុការណ៍ដែលត្រូវបានចោទប្រកាន់ថាបានកើតឡើងនៅក្នុងអំឡុងពេលនៃសម័យកម្ពុជាប្រជាធិបតេយ្យទៅវិញ។ ក៏ប៉ុន្តែ មិនថាដោយសារមូលហេតុអ្វីក៏ដោយនោះទេ ការសម្រេចនៅក្នុងសាលក្រមសំណុំរឿង ០០២/០១ ថា បក្សកុម្មុយនីស្តកម្ពុជាពុំមានគោលនយោបាយដាក់បទបញ្ជាទាក់ទងនឹងអាពាហ៍ពិពាហ៍បាននាំឲ្យមានការលេចចេញនូវភាពលម្អៀងក្នុងចំណោមចៅក្រម។ ក្រោយពីពិចារណាឃើញថា ការដាក់បទបញ្ជាទាក់ទងនឹងអាពាហ៍ពិពាហ៍នឹងបង្កើតជាផ្នែកចំបងមួយនៃសំណុំរឿង ០០២/០២ ចៅក្រមគួរត្រូវបានដកចេញពីពីសំណុំរឿង ០០២/០២ ដើម្បីធានានូវភាពអព្យាក្រឹតនៃការជំនុំជម្រះ។

---

[168] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១៣០។

[169] ឯកសារ E55/4 សេចក្តីសម្រេចលើបណ្តឹងជំទាស់លើកទី១ កថាខណ្ឌ ១៣។ សេចក្តីសម្រេចក្នុងរឿងក្តី *Karemera* កថាខណ្ឌ ១៣។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើរឿងក្តី RUF កថាខណ្ឌ ៦១-៦៣។

## *(iii) ការយោងលើការវិភាគអំពីប្រជាសាស្ត្រ*

86. នៅក្នុងសាលក្រមសំណុំរឿង ០០២/០១ ចៅក្រមបានទទួលស្គាល់ការវិភាគអំពីប្រជាសាស្ត្រនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ៖

> នៅឆ្នាំ ២០០៨ មជ្ឈមណ្ឌលឯកសារកម្ពុជា [...] បានរកឃើញសាកសពមនុស្សប្រមាណ ១.៣០០.០០០ នាក់ នៅក្នុងទីតាំងរណ្តៅសាកសពរួមចំនួន ៣៩០ កន្លែង នៅទូទាំងប្រទេសកម្ពុជា។ *អ្នកជំនាញជាច្រើនបានសន្និដ្ឋានថា មានលទ្ធភាពខ្ពស់ជាងនេះដែលថា ទីតាំងរណ្តៅសាកសពរួមទាំងនោះមានផ្ទុកនៅតែសំណល់សាកសព ដែលគ្រាន់តែជាឧទាហរណ៍នៃអ្នកដែលបានស្លាប់ ដោយសារតែលទ្ធផលនៃគោលនយោបាយ និងការប្រព្រឹត្តិទាំងឡាយរបស់ខ្មែរក្រហមនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះ។* [...]។ សរុបមក ការប៉ាន់ប្រមាណបង្ហាញថាមានប្រជាជនកម្ពុជាចំនួនពី ៦០០.០០០ នាក់ទៅ ៣.០០០.០០០ នាក់ បានស្លាប់ដោយសារតែលទ្ធផលនៃគោលនយោបាយ និងការប្រព្រឹត្តិរបស់ពួកខ្មែរក្រហម។ *នៅក្នុងរង្វង់តួលេខនេះ អ្នកជំនាញជាច្រើនទទួលយកការប៉ាន់ប្រមាណអំពីចំនួនអ្នកស្លាប់ពី ១.៥០០.០០០ ទៅ ២.០០០.០០០ នាក់ ថាជាចំនួនដែលត្រឹមត្រូវបំផុត*[170]។

87. មេធាវីការពារក្តីសូមសន្និដ្ឋានថា ការយោងលើការវិភាគអំពីប្រជាសាស្ត្រនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យគឺជាការសម្រេចយ៉ាងមានប្រសិទ្ធភាពដោយចៅក្រមថា៖ ការស្លាប់មនុស្ស "ចន្លោះពី ១.៥ ទៅ ២ លាននាក់" បានកើតឡើងក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ ការសម្រេចដូច្នេះគឺដោយសារចៅក្រមបាននិយាយបញ្ជាក់យ៉ាងជាក់លាក់ថា "អ្នកជំនាញទទួលយក" ចំនួនស្លាប់ពីចន្លោះ ១.៥ ទៅ ២ លានថាជាចំនួនត្រឹមត្រូវ ហើយបន្ទាប់មកពុំជំទាស់អំពីភាពត្រឹមត្រូវនៃចំនួនដែលបានស្នើឡើងនេះនៅក្នុងចំណុចណាផ្សេងក្នុងសាលក្រមនោះឡើយ។

88. ក្នុងពេលជាមួយគ្នានោះដែរ ចៅក្រមពុំបានពិភាក្សាអំពីទឡ្ហីករណ៍ផ្ទុយដែលមេធាវីការពារក្តីបានដាក់ជូននៅក្នុងអំឡុងពេលនៃសំណុំរឿង ០០២/០១ ដែលថា ការស្លាប់មនុស្សជាច្រើននាក់ដែលបានលើកឡើងថាមានការជាប់ទាក់ទងជាមួយនឹងបក្សកុម្មុយនីស្តកម្ពុជា តាមពិតអាចបានកើតឡើងនៅមុន ឬក្រោយសម័យកម្ពុជាប្រជាធិបតេយ្យ និងបណ្តាលមកពី ឧទាហរណ៍ដូចជា

[170] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១៧៤ (លេខយោងជើងទំព័រត្រូវបានលុបចោល គូសបញ្ជាក់បន្ថែម)។

ផែនការការងារដោយបង្ខំ ក-៥ ទៅវិញនោះទេ[171]។ ចៅក្រមក៏ពុំបានឆ្លើយតបឱ្យបានសមស្រប លើអង្គហេតុគួរឱ្យកត់សម្គាល់ និងដែលដឹងឮជាទូទៅដែលចៅក្រមខ្លួនឯងបានលើកឡើងថា ការប៉ាន់ស្មានលើការស្លាប់មនុស្សនៅក្នុងអំឡុងពេលនៃសម័យកម្ពុជាប្រជាធិបតេយ្យមានភាពខុសៗគ្នាខ្លាំងបំផុត ដោយការប៉ាន់ស្មានចំនួនមនុស្សស្លាប់តិចបំផុត និងច្រើនបំផុតគឺត្រឹមប្រហែល ២.៤ លាននាក់។

89. ដូច្នេះ មេធាវីការពារក្ដីសូមសន្និដ្ឋានថា ការសម្រេចនេះ និងការពិភាក្សាពាក់ព័ន្ធផ្សេងទៀតលើភ័ស្តុតាងអំពីប្រជាសាស្ត្របានបង្ហាញឱ្យឃើញថា ចៅក្រមមានការលេចឡើងនូវភាពលម្អៀងដែលមានស្រាប់ ដែលក៏មានផលប៉ះពាល់ផងដែរលើសំណុំរឿង ០០២/០២ ដែលគួរដកចៅក្រមចេញ។ ក្នុងន័យម្យ៉ាងទៀត បើទោះបីជាគេពុំទទួលស្គាល់ថា ការយោងលើការវិភាគអំពីប្រជាសាស្ត្រនេះគឺជាការសម្រេចតាមផ្លូវតុលាការក៏ដោយ ក៏យ៉ាងហោចណាស់វាបានបង្ហាញឱ្យឃើញនូវកង្វះភាពអព្យាក្រឹតក្នុងចំណោមចៅក្រមចំពោះភ័ស្តុតាងអំពីបញ្ហាសំខាន់បំផុតសម្រាប់សំណុំរឿង០០២/០២ *ដោយក្នុងនោះ*រួមទាំងពាក់ព័ន្ធនឹងបញ្ហាប្រល័យពូជសាសន៍ និងមន្ទីរសន្តិសុខ។ មេធាវីការពារក្ដីសូមអះអាងថា ករណីនេះនាំដល់ការបង្កើតទស្សនៈយល់ឃើញ*ជាមុន*ឬជាស្រេចដោយមិនសមរម្យអំពីទិដ្ឋភាពនៃរឿងក្ដីរបស់ នួន ជា នៅក្នុងសំណុំរឿង ០០២/០២ ដែលជាថ្មីម្ដងទៀត ចៅក្រមគួរត្រូវបានដកចេញ។

### *(iv) ការផ្អែកមូលដ្ឋានលើសាលក្រម ឌុច ដើម្បីកំណត់និយមន័យពាក្យ "កម្មេច"*

90. នៅក្នុងសាលក្រមសំណុំរឿង ០០២/០១ ចៅក្រមបានសង្កេតឃើញថា "[មាន]*ភ័ស្តុតាង*បង្ហាញថា បក្សកុម្មុយនីស្តកម្ពុជាបានបង្កើតគោលនយោបាយមួយបន្ថែមទៀត គឺការអប់រំកែប្រែ "សមាសភាពមិនល្អ" និង "កម្មេច" អ្នកទាំងឡាយណាដែលត្រូវបានរកឃើញថាជាខ្មាំង"[172]។ លេខយោងជើងទំព័រសម្រាប់ឃ្លានេះបានរៀបរាប់សាលក្រម ឌុច ថាជា "ភ័ស្តុតាង" មួយផ្នែក[173]។ ដូចគ្នានេះដែរ នៅក្នុងកថាខណ្ឌដដែលនេះ ចៅក្រមបានយោងម្ដងទៀតលើសាលក្រម ឌុច ថាជាធាតុផ្សំមួយ

---

[171] *សូមមើល ឧ.* ឯកសារ E295/6/3 សារណាបញ្ចប់ការពិភាក្សាដេញដោលរបស់មេធាវីការពារក្ដីលើសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៨។

[172] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១១៧ (គូសបញ្ជាក់បន្ថែម)។

[173] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ លេខយោងជើងទំព័រ ៣២៦។

នៃភ័ស្តុតាងនៅពេលកំណត់និយមន័យពាក្យ “កម្ទេច”[174]។

91. ការស្នាក់ស្នើរនៃយុត្តិសាស្ត្របច្ចុប្បន្នក្នុងការអនុញ្ញាតឱ្យមានបណ្តឹងជំទាស់ចៅក្រម ដោយសារតែចៅក្រមបានធ្វើសវនាការលើរឿងក្តីជាន់គ្នាជាច្រើនរួចមកហើយនោះគឺ ភាគច្រើនដោយផ្អែកលើការជឿជាក់ថា ចៅក្រមវិជ្ជាជីវៈនឹង “ធ្វើការសម្រេចដោយយុត្តិធម៌លើបញ្ហានានានៅចំពោះមុខខ្លួនដោយផ្អែក *ទាំងស្រុងតែទៅលើ*ភ័ស្តុតាងដែលបានរកឃើញនៅក្នុងរឿងក្តីជាក់លាក់នេះ”[175]។ ករណីដែលថា ចៅក្រមបានយោងលើផ្នែកសំអាងហេតុនៅក្នុងសាលក្រម ខុច លើកមុនហាក់ដូចជាសាលក្រមនេះគឺជាភ័ស្តុតាងនៅក្នុងរឿងក្តីបច្ចុប្បន្នអញ្ចឹង បើទោះបីជាមានយុត្តិសាស្ត្រយ៉ាងច្បាស់ថា ផ្នែកសំអាងហេតុលើរឿងក្តីមុនពុំអាចចងកាតព្វកិច្ចដោយស្វ័យប្រវត្តិលើរឿងក្តីក្រោយៗនោះក៏ដោយ[176] ក៏វាបង្ហាញឱ្យឃើញថា ចៅក្រមពុំមានលទ្ធភាពធានាថា ពួកគាត់ “មិនអាចធ្វើការវិនិច្ឆ័យដោយអនាគតិ” លើរឿងក្តីបច្ចុប្បន្ននោះទេ[177]។

92. ក្រោយពីពិនិត្យឃើញមានការខកខានរបស់ចៅក្រមក្នុងការផ្អែកទាំងស្រុងតែទៅលើភ័ស្តុតាងនៅក្នុងសំណុំរឿង ០០២/០១ ដើម្បីចេញសាលក្រមសំណុំរឿង ០០២/០១ រួចមក វាសមហេតុផលដែលយើងត្រូវមានការភ័យខ្លាចថា ចៅក្រមអាចពុំមានទស្សនៈយល់ឃើញអព្យាក្រឹត និងមិនលម្អៀងក្នុងការជំនុំជម្រះលើសំណុំរឿង ០០២/០២ នោះឡើយ។ ម្យ៉ាងវិញទៀត ដូចបានបង្ហាញនៅក្នុងចំណុចខាងក្រោម ក្រោយពីពិចារណាឃើញថា ការសម្រេចជាច្រើនរបស់ចៅក្រមនៅក្នុងសាលក្រមសំណុំរឿង ០០២/០១ នាំឱ្យកើតមានការធ្វើបុរេវិនិច្ឆ័យលើបញ្ហាសំខាន់ៗទាក់ទងនឹងការចោទប្រកាន់អំពីពិរុទ្ធភាពរបស់ជនជាប់ចោទនៅក្នុងសំណុំរឿង ០០២/០២ មេធាវីការពារក្តីសូមសន្និដ្ឋានថា វាអាចលេចចេញនូវភាពលម្អៀងដែលមិនអាចទទួលយកបាន ប្រសិនបើចៅក្រមដដែលបន្តចូលរួមជំនុំជម្រះលើសំណុំរឿង ០០២/០២។

---

[174] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ លេងយោងជើងទំព័រ ៣៣០។

[175] សាលដីកាក្នុងរឿងក្តី Akayesu កថាខណ្ឌ ២៦៩។ សាលក្រមក្នុងរឿងក្តី Nahimana កថាខណ្ឌ ៧៨ (គូសបញ្ជាក់បន្ថែម)។

[176] *សូមមើល ឧ.* សេចក្តីសម្រេចក្នុងរឿងក្តី Brđanin កថាខណ្ឌ ៦។

[177] ញត្តិលើកទីមួយស្នើសុំប្តឹងជំទាស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៥។ សេចក្តីសម្រេចក្នុងរឿងក្តី Brđanin កថាខណ្ឌ ១៨-១៩។

## ច. ការសម្រេចរបស់ចៅក្រមនៅក្នុងសាលក្រមសំណុំរឿង ០០២/០១ អំពីអង្គហេតុទាក់ទងនឹងសំណុំរឿង ០០២/០២ នាំឲ្យលេច*ចេញ*នូវភាពលម្អៀងទាក់ទងនឹងសំណុំរឿង ០០២/០២

93. យុត្តិសាស្ត្របានបង្ហាញឲ្យឃើញថា *ការកំណត់ជាមុន* របស់ចៅក្រមលើបញ្ហាមួយ ឬ ច្រើនទាក់ទងនឹងការចោទប្រកាន់អំពីពិរុទ្ធភាពរបស់ជនជាប់ចោទ ឬ *ការសន្និដ្ឋានជាមុន* ទស្សនៈអវិជ្ជមានលើករណីរបស់ភាគីណាមួយនោះ ជាពិសេស ទស្សនៈអំពីសុពលភាព និងភាពអាចទុកចិត្តបាននៃទឡ្ហីករណ៍របស់ភាគី អាចនាំដល់ការដកចៅក្រមចេញពីរឿងក្ដីនោះបាន។ ការសម្រេចជាច្រើនដែលបានធ្វើឡើងនៅក្នុងសាលក្រមសំណុំរឿង ០០២/០១ គឺជាការធ្វើការកំណត់ជាមុនលើបញ្ហានានាទាក់ទងនឹងការចោទប្រកាន់អំពីពិរុទ្ធភាពរបស់ជនជាប់ចោទនៅក្នុងសំណុំរឿង ០០២/០២ ឬគឺជាទស្សនៈអវិជ្ជមានដែលបានសន្និដ្ឋានជាមុនលើរឿងក្ដីរបស់មេធាវីការពារក្ដី។ ដូច្នេះ ករណីទាំងនេះនាំឲ្យលេចចេញនូវភាពលម្អៀងរបស់ចៅក្រមទាក់ទងនឹងសំណុំរឿង ០០២/០២។

94. យើងត្រូវបញ្ជាក់ឡើងវិញលើបញ្ហានេះថា ដូចអង្គជំនុំជម្រះតុលាការកំពូលបានសង្កេតឃើញរួចហើយនោះថា លក្ខខណ្ឌនៃភាពអព្យាក្រឹត ដែលបានមើលឃើញក្នុងបរិបទនៃរបៀបដែលសំណុំរឿង ០០២ ត្រូវបានបំបែកនោះ តម្រូវថា ភ័ស្តុតាងនាំឲ្យមានព្យសនកម្មដែលត្រូវបានស្ដាប់ដោយចៅក្រមរួចហើយនោះត្រូវដកចេញពីការជំនុំជម្រះនាពេលក្រោយ ឬចៅក្រមទាំងនេះត្រូវដកខ្លួនចេញពីការជំនុំជម្រះ[178]។ មេធាវីការពារក្ដីសូមសន្និដ្ឋានថា ករណីនេះត្រូវយកមកពិចារណានៅពេលដែលអង្គជំនុំជម្រះសម្រេចថាតើត្រូវ ឬមិនត្រូវដិតចិត្តចៅក្រមទាំងនេះ។

## *(អ) ផលប៉ះពាល់នៃផ្នែកសំអាងហេតុនៅក្នុងសំណុំរឿង ០០២/០១ និងវិសាលភាពនៃសំណុំរឿង ០០២/០២*

95. ដីកាដំណោះស្រាយបានចោទប្រកាន់ថា ដើម្បីសម្រេចគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានរៀបចំគោលនយោបាយចំនួន ៥ ("គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាចំនួន ៥ ដូចដែលរងការចោទប្រកាន់" ឬ "គោលនយោបាយចំនួន ៥")៖ ការផ្លាស់ទីលំនៅដែលធ្វើឡើងជាច្រើនលើកច្រើនសារទៅលើប្រជាជន ការបង្កើតសហករណ៍ និងការដ្ឋាន ការអប់រំ "សមាសភាពមិនល្អ" និងការកម្ទេច "ខ្មាំង" ការចេញវិធានការណ៍ជាពិសេស

[178] ឯកសារ E301/9/1/1/3 សេចក្ដីសម្រេចរបស់ អ.ជ.ត.ក លើបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៨៣។

ចំពោះក្រុមមនុស្សជាក់លាក់នានា ការដាក់បទបញ្ញាទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍[179]។

96. អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចមួយកាលពីថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១៤ ដោយក្នុងនោះបានរៀបរាប់លម្អិតអំពីវិសាលភាពនៃសំណុំរឿង ០០២/០២[180]។ នៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ប្រធានបទមួយចំនួន រួមមាន គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាចំនួន ៥ ដូចដែលបានចោទប្រកាន់ និងតួនាទីរបស់ជនជាប់ចោទ ត្រូវបានដាក់ដោយមានការកត់សម្គាល់មិនច្បាស់លាស់អំពីការកំណត់លក្ខណៈសម្បត្តិ ដោយលើកឡើងថា ការពិភាក្សាអំពីប្រធានបទទាំងនេះនឹងត្រូវ "កម្រិតត្រឹមតែបទល្មើសជាក់លាក់មួយចំនួនដែលពាក់ព័ន្ធ"[181]។ មានការស្នើឡើងនៅក្នុងសាលក្រមសំណុំរឿង ០០២/០១ ផងដែរថា ដោយហេតុថា "អត្ថិភាព" នៃគោលនយោបាយទាំង ៥ របស់បក្សកុម្មុយនីស្តកម្ពុជាត្រូវបានពិនិត្យនៅក្នុងសំណុំរឿង ០០២/០១ រួចហើយ គឺនៅសល់តែ "ការអនុវត្ត" គោលនយោបាយតែប៉ុណ្ណោះ ដែលនៅបើកចំហសម្រាប់ការពិភាក្សាក្នុងពេលជំនុំជម្រះនាពេលខាងមុខ[182]។

97. នៅក្នុងអំឡុងពេលជំនុំជម្រះលើសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានពិនិត្យមើលគោលនយោបាយទាំង ៥ របស់បក្សកុម្មុយនីស្តកម្ពុជាដូចដែលរងការចោទប្រកាន់ ទោះបីជាមានតែគោលនយោបាយចំនួន ២ ប៉ុណ្ណោះដែលស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ ក៏ដោយ[183]។ ជាការឆ្លើយតបទៅនឹងការព្រួយបារម្ភរបស់ភាគីអំពីថាតើការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ លើបញ្ហានានា ដូចជា គោលនយោបាយទាំង ៥ របស់បក្សកុម្មុយនីស្តកម្ពុជាដូចដែលរងការចោទប្រកាន់ នឹងមានផលប៉ះពាល់ជាក់លាក់សម្រាប់រឿងក្តីក្រោយៗទៀតដែរឬទេ ហើយថាតើផលប៉ះពាល់នោះនឹងមានកម្រិតត្រឹមណាខ្លះនោះ អង្គជំនុំជម្រះសាលាដំបូងបានពន្យល់ថា គោលបំណងនៃការដាក់បញ្ចូល "ចំណុចយោង" លើគោលនយោបាយ

---

[179] ឯកសារ D427 "ដីកាដំណោះស្រាយ" ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ កថាខណ្ឌ ១៥៦-១៥៩។

[180] ឯកសារ E301/9/1.1 "ឧបសម្ព័ន្ធ ៖ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹការជំនុំជម្រះសំណុំរឿងលេខ ០០២/០២" ចុះថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១៤ ("វិសាលភាពនៃសំណុំរឿង ០០២/០២")។

[181] ឯកសារ E301/9/1.1 វិសាលភាពនៃសំណុំរឿង ០០២/០២ ទំព័រ ១, ២។

[182] *សូមមើល* ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ លេងយោងជើងទំព័រ ២៨៧។

[183] ឯកសារ E124/7.3 "ឧបសម្ព័ន្ធ ៖ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹការជំនុំជម្រះដំណាក់កាលដំបូងនៅក្នុងសំណុំរឿងលេខ ០០២" ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១២ ("វិសាលភាពនៃសំណុំរឿង ០០២/០១")។ *សូមមើលផងដែរ* ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ លេងយោងជើងទំព័រ ២៨៧។

ទាំង ៥ របស់បក្សកុម្មុយនីស្តកម្ពុជានៅក្នុងការជំនុំជម្រះលើកទី ១ គឺគ្រាន់តែ "ដើម្បីឱ្យមានលទ្ធភាពបង្ហាញពីរបៀបដែលគោលនយោបាយត្រូវបានបង្កើតឡើង"[184] តែប៉ុណ្ណោះ។ ក្រោយមកអង្គជំនុំជម្រះតុលាការកំពូលបានសម្រេចយ៉ាងច្បាស់ថា ពុំមាន "ភាពរួមគ្នា" ក្នុងចំណោមសំអាងហេតុលើរឿងក្តីតូចៗដែលត្រូវបានបំបែកចេញពីសំណុំរឿង ០០២ នោះទេ ហើយ "ធាតុរួមនៃអង្គហេតុក្នុងសំណុំរឿងទាំងអស់ក្នុងសំណុំរឿង ០០២ *ត្រូវបង្ហាញសារជាថ្មី*"[185]។

98. ដូច្នេះ សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីលើកឡើងថា បើទោះជាមានការកំណត់លក្ខណៈសម្បត្តិដោយស្រពិចស្រពិលនៅក្នុងបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូង លើវិសាលភាពនៃសំណុំរឿង ០០២/០២ ហើយបើទោះជាមានការចង្អុលបញ្ជាក់ខាងលើក្នុងសាលក្រមសំណុំរឿង ០០២/០១ ក៏ដោយ ក៏បញ្ហាអង្គហេតុទាក់ទងនឹងសំណុំរឿង ០០២/០២ រួមទាំងអត្ថិភាពនៃគោលនយោបាយពាក់ព័ន្ធ និងតួនាទីជាក់លាក់របស់ជនជាប់ចោទទាក់ទងនឹងបទចោទពាក់ព័ន្ធ *ត្រូវបង្ហាញសារជាថ្មី*នៅក្នុងការជំនុំជម្រះលើសំណុំរឿង ០០២/០២ ដដែល។

## *(ii) អត្ថិភាពនៃគោលនយោបាយទាំង ៥ របស់បក្សកុម្មុយនីស្តកម្ពុជាដែលរងការចោទប្រកាន់*

99. ខុសពីសំណុំរឿង ០០២/០១ ដែលបទចោទពាក់ព័ន្ធជាប់ទាក់ទងនឹងគោលនយោបាយចំនួន ២ ប៉ុណ្ណោះ សំណុំរឿង ០០២/០២ ជាប់ទាក់ទងនឹងបទចោទដែលមានទំនាក់ទំនងជាមួយនឹងគោលនយោបាយទាំងអស់ចំនួន ៥[186]។ ផ្នែកស្ទើរតែទាំងអស់នៅក្នុងដីកាដំណោះស្រាយពាក់ព័ន្ធនឹងអត្ថិភាពទូទៅនៃគោលនយោបាយទាំង ៥ និងទំនាក់ទំនងរបស់គោលនយោបាយទាំងអស់នេះជាមួយនឹងសហឧក្រិដ្ឋកម្មរួមដែលរងការចោទប្រកាន់[187] ព្រមទាំងអង្គហេតុជាក់លាក់ទាក់ទងនឹងការបង្កើត និងការវិវឌ្ឍគោលនយោបាយនីមួយៗ[188] ស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង

---

[184] ឯកសារ E141 "ការឆ្លើយតបទៅលើបញ្ហាដែលបានលើកឡើងដោយភាគីផ្សេងៗមុនពេលសវនាការ និងការកំណត់ពេលវេលានៃកិច្ចប្រជុំមិនផ្លូវការជាមួយនឹងមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១" ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ២ ("អនុស្សារណៈរបស់ អ.ជ.ស.ដ ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១")។

[185] ឯកសារ E301/9/1/1/3 សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៨៥ (គូសបញ្ជាក់បន្ថែម)។

[186] ឯកសារ E124/7.3 បញ្ជីនៃវិសាលភាពលើសំណុំរឿង ០០២/០១។

[187] ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៦-១៥៩។

[188] ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ១៦០-១៦៧, ១៦៨-១៧៧, ១៧៨-២០៤, ២០៥-២១៥, ២១៦-២២០។

០០២/០២[189]។ ដូច្នេះ ដរាបណាអង្គហេតុដែលត្រូវបានចោទប្រកាន់នៅក្នុងផ្នែកទាំងនេះជាប់ទាក់ទងនឹងសំណុំរឿង ០០២/០២ អង្គហេតុទាំងនេះត្រូវបង្ហាញសារជាថ្មី។

100. នៅក្នុងសាលក្រមសំណុំរឿង ០០២/០១ ចៅក្រមខ្លួនឯងយល់ឃើញថា ពួកគាត់ជឿជាក់ថាមានអត្ថិភាពនៃគោលនយោបាយទាំង ៥ របស់បក្សកុម្មុយនីស្តកម្ពុជា[190] ដែលចៅក្រមបានសម្រេចថាគោលនយោបាយទាំង ៥ នេះបានបង្កើតឡើងដើម្បីសម្រេចគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម។ នៅក្នុងសំណុំរឿង ០០២/០២ សហឧក្រិដ្ឋកម្មរួមគឺជាទម្រង់ចំបងមួយនៃការទទួលខុសត្រូវដែលត្រូវបានចោទប្រកាន់លើ នួន ជា។ ដូច្នេះ ការសម្រេចទាក់ទងនឹងអត្ថិភាព ការបង្កើត និងការវិវឌ្ឍគោលនយោបាយគឺជាបញ្ហាសំខាន់បំផុតដែលជាប់ទាក់ទងនឹងការចោទប្រកាន់អំពីពិរុទ្ធភាពរបស់ នួន ជា នៅក្នុងសំណុំរឿង ០០២/០២។ ដោយហេតុថា បញ្ហាអង្គហេតុទាំងនេះត្រូវបង្ហាញសារជាថ្មីនៅក្នុងសំណុំរឿង ០០២/០២ មេធាវីការពារក្តីសូមសន្និដ្ឋានថា ការកំណត់ជាមុនរបស់ចៅក្រមលើបញ្ហាទាំងនេះដូចបានបង្ហាញដោយសាលក្រមសំណុំរឿង ០០២/០១ នាំឱ្យមានការលេចចេញនូវភាពលម្អៀងដែលមិនអាចទទួលយកបាន ប្រសិនបើចៅក្រមនៅបន្តចូលរួមជំនុំជម្រះលើសំណុំរឿង ០០២/០២ ទៀតនោះ។

## *(iii) គោលនយោបាយស្តីពីការកំណត់គោលដៅ "ខ្មាំង" ជាពិសេស "ប្រជាជនថ្មី" និងអតីតមន្ត្រីរាជការនៃរបបសាធារណរដ្ឋខ្មែរ*

101. ដីកាដំណោះស្រាយចោទប្រកាន់ថា ៖ ទិដ្ឋភាពមួយនៃគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួមគឺដើម្បីការពារបក្សពីខ្មាំងខាងក្រៅបក្ស និងក្នុងបក្ស[191]។ បក្សកុម្មុយនីស្តកម្ពុជាបានកំណត់ក្រុមមួយចំនួនថាជា "ខ្មាំង" រួមទាំង "ប្រជាជនថ្មី" (អ្នករស់នៅក្នុងក្រុងដែលត្រូវបានជម្លៀសក៏ហៅថា

[189] ឯកសារ E301/9/1.1 វិសាលភាពនៃសំណុំរឿង ០០២/០២ ទំព័រ ១-២ ដែលយោងលើដីកាដំណោះស្រាយ កថាខណ្ឌ ១៥៦-១៥៩, ១៦០-១៦៣, ១៦៥, ១៦៧, ១៦៨-២០៣, ២០៥-២១៥, ២១៦-២២០។ ការកំណត់បទចោទនៅក្នុងផ្នែកនេះនៃបញ្ជីទាក់ទងនឹងទិដ្ឋភាពខ្លះនៃគោលនយោបាយស្តីពីការផ្លាស់ទីលំនៅរបស់ប្រជាជន គោលនយោបាយសិក្សាធិការ និងកាប់សម្លាប់ និងគោលនយោបាយកំណត់គោលដៅគឺដើម្បីកម្រិតបទចោទដែលនឹងត្រូវយកមកជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០២។

[190] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១១២, ១១៦, ១១៨, ១២៧, ១៣០ ការសម្រេចទាក់ទងនឹងគោលនយោបាយស្តីពីការកំណត់គោលដៅបានកម្រិតត្រឹមការកំណត់គោលដៅលើទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ-ដែលជាប្រធានបទមួយក៏ទាក់ទងនឹងសំណុំរឿង ០០២/០២ ផងដែរ។

[191] ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៦។

"ប្រជាជន ១៧ មេសា" ឬ "ប្រជាជនបញ្ញើ"[192]) និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ[193]។ ប្រជាជនទាំងនេះត្រូវបានគេកំណត់គោលដៅនៅក្នុងពេលផ្លាស់ទីលំនៅប្រជាជន នៅតាមសហករណ៍ និងការដ្ឋាន ហើយត្រូវបានគេអប់រំ ឬសម្លាប់ចោលនៅតាមមន្ទីរសន្តិសុខ[194] ដែលចាត់ទុកជាការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយ និងបទចោទផ្សេងទៀតដែលត្រូវបានចោទប្រកាន់[195]។ ដីកាដំណោះស្រាយភាគច្រើនដែលទាក់ទងនឹងការកំណត់គោលដៅលើ "ប្រជាជនថ្មី" និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២[196]។

102. នៅក្នុងសាលក្រមសំណុំរឿង ០០២/០១ ចៅក្រមជឿជាក់ថាមានអត្ថិភាពនៃគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាស្តីពីការអប់រំ "សមាសភាពអាក្រក់" និងការសម្លាប់ខ្មាំង[197] ព្រមទាំងគោលនយោបាយរបស់បក្សក្នុងការកំណត់គោលដៅ "ប្រជាជនថ្មី" និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ[198]។

103. ចំពោះការកំណត់គោលដៅ "ប្រជាជនថ្មី" ចៅក្រមបានសម្រេចថា ៖ **(i)** "[តាំង]ពីមុនរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានបណ្តុះកំហឹងយ៉ាងខ្លាំងក្លា ក្នុងចំណោមអ្នកគាំទ្រខ្លួន ប្រឆាំងនឹងអ្នករស់នៅទីក្រុង" ហើយ "ភាពស្អប់ខ្ពើម និងការមិនទុកចិត្ត" លើប្រជាជនថ្មីបានកើតឡើង

---

[192] ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ២២៧។

[193] ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ១៤១៧។

[194] *សូមមើល ឧ.* ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ២២៧, ២៣៤-២៣៥, ២៦៥, ៣០៥-៣០៦, ៣១៩, ៣៤៣, ៣៤៦, ៣៦០, ៣៦៦, ៤៣២, ៤៧៩, ៤៩៨, ៥០០, ៥២៣-៥២៤, ៥៤១, ៥៧៦, ៦៥៣, ៦៧៣, ៦៩៤-៦៩៧, ៧០៥-៧១៣។

[195] *សូមមើល ឧ.* ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៧៣-១៤៧៨ ជាពិសេស កថាខណ្ឌ ១៤១៧ (ការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយ)។

[196] ឯកសារ E301/9/1.1 បញ្ជីវិសាលភាពនៃសំណុំរឿង ០០២/០២ ទំព័រ ១-៤ ដែលយោងលើដីកាដំណោះស្រាយ កថាខណ្ឌ ១៥៦-១៥៩, ៣០៥-៣០៦, ៣១៩, ៣៤៣, ៣៤៦, ៣៦០, ៣៦៦, ៤៣២, ៤៩៨, ៥០០, ១៣៧៣-១៤៧៨។

[197] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១១៧-១១៨។

[198] ជាទូទៅ ចៅក្រមបានសម្រេចថា ទាំងអតីតអ្នករដ្ឋការ ទាំងទាហាននៃរបបសាធារណរដ្ឋខ្មែរ និង "ប្រជាជនថ្មី" ត្រូវបានកំណត់អត្តសញ្ញាណថាជាខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា។ *សូមមើល* ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៦៩។

"នៅគ្រប់ពេលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ"[199] **(ii)** បក្សកុម្មុយនីស្តកម្ពុជាបានបែងចែករវាង "ប្រជាជនមូលដ្ឋាន" (កសិករ) និង "ប្រជាជនថ្មី" (អ្នករស់នៅទីក្រុង) ហើយបានចាត់ទុកអ្នករស់នៅទីក្រុង "ថាជាខ្មាំងសង្គម និងនយោបាយរបស់បដិវត្តន៍ និងប្រព័ន្ធសម្ភូហភាព" ព្រមទាំងធ្វើ "ការតស៊ូវណ្ណៈ" ប្រឆាំងនឹងពួកគេ និងបានព្យាយាមអប់រំពួកគេ[200] ហើយ **(iii)** "ប្រជាជនថ្មី" ត្រូវបានរើសអើស "ដោយហេតុផលនយោបាយ"[201] និងត្រូវបានកំណត់គោលដៅនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅរបស់ប្រជាជននៅតាមសហករណ៍ និងការដ្ឋាន[202]។

104. ចំពោះការកំណត់គោលដៅលើអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ចៅក្រមបានសម្រេចថា ៖ **(i)** ទាហាន និងអ្នករដ្ឋការនៃរបប លន់ នល់ ត្រូវបាន "កំណត់ថាជាខ្មាំងសំខាន់" ហើយ "គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការកំណត់គោលដៅទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរមានអត្ថិភាពនៅមុនឆ្នាំ ១៩៧៥" និង "បានបន្តក្នុងពេញសម័យកម្ពុជាប្រជាធិបតេយ្យ"[203] **(ii)** គោលនយោបាយនេះកាន់តែតឹងតែងខ្លាំងឡើងពីពេលមួយទៅពេលមួយ ហើយឈានដល់ការកាប់សម្លាប់ក្នុងទ្រង់ទ្រាយធំលើទាហាននៃរបបសាធារណរដ្ឋខ្មែរក្រោយពេលចាប់ខ្លួន រួមទាំង ការសម្លាប់*ជាឈុត* ក្រោយពេលដណ្តើមបានឧត្តុង្គ[204] ហើយ **(iii)** នៅក្នុងអំឡុងពេលនៃសម័យកម្ពុជាប្រជាធិបតេយ្យ អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរត្រូវបានកំណត់អត្តសញ្ញាណថាជា "សត្រូវធំ" ត្រូវបានកំណត់គោលដៅដោយហេតុផលនយោបាយ បានទទួលរងនូវ "ការតស៊ូវណ្ណៈ" និងការអប់រំ ឬ កម្ចាត់ចោល[205]។

---

[199] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១១២, ៧៨៧។ ចំពោះការសម្រេចលើការស្អប់ខ្ពើម និងការសង្ស័យលើ "ប្រជាជនក្រុង" *សូមមើលផងដែរ* កថាខណ្ឌ ១១១, ៥១៧, ៥៧១, ៨៧៣។

[200] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១៩៥, ៦១៣-៦១៦, ៦២១, ៦៥៣, ៧៨៣-៧៨៤, ៧៨៨, ៧៩៥, ៨០៥, ៨៧៣, ៩០៣។

[201] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៧១, ៨០៥។

[202] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៥១៧, ៥៧១, ៦១៣-៦១៦, ៦២១, ៦៣៤-៦៣៥, ៦៥៣, ៩៥៧។

[203] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១១៨, ១២០, ១២៧, ៨១៤។

[204] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១២៧។

[205] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១៦៩, ៦១៣, ៦៣៤, ៨០៥, ៨១៤-៨១៥, ៨១៧-៨១៨, ៨២៨, ៨៣១, ៨៣៣-៨៣៤, ៩០៣។

105. គោលនយោបាយរើសអើសដែលបានចោទប្រកាន់ថាបានកំណត់គោលដៅលើ “ប្រជាជនថ្មី” និងទាហាន ព្រមទាំងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរពុំទាក់ទងដោយផ្ទាល់នឹងឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញដោយហេតុផលនយោបាយនោះទេ ដែលជនជាប់ចោទត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០២។ គោលនយោបាយទាំងនេះក៏ជាប់ទាក់ទងយ៉ាងប្រទាក់ក្រឡាគ្នាជាមួយនឹងគោលនយោបាយចំនួនបួនទៀតក្នុងចំណោមគោលនយោបាយទាំងប្រាំរបស់បក្សកុម្មុយនីស្តកម្ពុជាដែលត្រូវបានចោទប្រកាន់ថាបានបង្កើតជាឧបករណ៍ដើម្បីសម្រេចបានគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម (ដែលជាទម្រង់ចំបងនៃការទទួលខុសត្រូវដែលត្រូវបានចោទប្រកាន់លើ នួន ជា នៅក្នុងសំណុំរឿង ០០២/០២)។ វាបានបង្ហាញឱ្យឃើញថា អត្ថិភាពនៃគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាដូចដែលបានចោទប្រកាន់ថាបានកំណត់គោលលដៅលើ “ប្រជាជនថ្មី” និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរគឺជាបញ្ហាសំខាន់ទាក់ទងនឹងការចោទប្រកាន់អំពីពិរុទ្ធភាពរបស់ជនជាប់ចោទនៅក្នុងសំណុំរឿង ០០២/០២។ មេធាវីការពារក្តីសូមសន្និដ្ឋានថា ការកំណត់ជាមុនរបស់ចៅក្រមលើបញ្ហាទាំងនេះនឹងនាំឱ្យលេចចេញនូវភាពលម្អៀង ប្រសិនបើចៅក្រមនៅតែបន្តចូលរួមជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០២។

## *(iv) តួនាទីរបស់ នួន ជា នៅក្នុងការបង្កើត និងការអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា*

106. ដីកាដំណោះស្រាយបានចោទប្រកាន់ថា នួន ជា មានតួនាទីជាន់ខ្ពស់នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា និងសម័យកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងបានទទួលការងារឃោសនាអប់រំ និងមានអំណាចលើបញ្ហាសន្តិសុខ និងយោធា។ ដូច្នេះ គាត់ត្រូវបានចោទប្រកាន់ថាបានចូលរួមនៅក្នុងការបង្កើត និងជំរុញគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា និងទទួលខុសត្រូវលើឧក្រិដ្ឋកម្មដែលទាក់ទងនឹងប្រតិបត្តិការសន្តិសុខ ឬយោធាពាក់ព័ន្ធនានា[206]។ កថាខណ្ឌចំនួនមួយតែប៉ុណ្ណោះនៅក្នុងដីកាដំណោះស្រាយទាក់ទងនឹងតួនាទីរបស់ នួន ជា ដែលស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២[207]។

107. នៅក្នុងសាលក្រមសំណុំរឿង ០០២/០១ ចៅក្រមបានសម្រេចថា ៖ **(i)** ជាទូទៅ “[ដោយសារ]

---

[206] ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ៨៦២-៨៩៣។

[207] ឯកសារ E301/9/1.1 បញ្ជីវិសាលភាពលើសំណុំរឿង ០០២/០២ ទំព័រ ២ ដែលយោងលើដីកាដំណោះស្រាយ កថាខណ្ឌ ៨៦២-៩០១, ៩០៣-៩៩៣។

មានតួនាទីខ្ពស់នៅក្នុងថ្នាក់ដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា នួន ជា *ទទួលខុសត្រូវ*លើសកម្មភាព *ទាំងអស់*របស់បក្ស ដែលលើសពីតួនាទី និងការទទួលខុសត្រូវដែលត្រូវបានប្រគល់ជូនគាត់ជាផ្លូវការក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ" **(ii)** នួន ជា និង ប៉ុល ពត "បានអនុវត្តសិទ្ធិ *អំណាចធ្វើសេចក្តីសម្រេចចុងក្រោយ*របស់បក្ស" ហើយ **(iii)** "នួន ជា មានតួនាទី និងបានអនុវត្តនូវសិទ្ធិអំណាចរបស់ខ្លួនដើម្បី *បង្កើត និងអនុវត្ត*នូវគោលនយោបាយ និងសេចក្តីសម្រេចរបស់បក្សកុម្មុយនីស្តកម្ពុជា"[208]។

108. លើសពីនេះ ក្រោយពីការសម្រេចថា នួន ជា មិនមែនជាសមាជិកនៃគណៈកម្មាធិការយោធា ចៅក្រមបានសន្និដ្ឋានថា "សមាជិកភាពពិតប្រាកដនៅក្នុងគណៈកម្មាធិការយោធា មិនសូវជាសំខាន់ប៉ុន្មានទេ ដោយសារ នួន ជា មានមុខតំណែងជាន់ខ្ពស់នៅក្នុងគណៈកម្មាធិការមជ្ឈិមបក្ស"[209] និងបានសម្រេចថា អំណាច និងការគ្រប់គ្រងរបស់ នួន ជា បានគ្របដណ្តប់រហូតដល់បញ្ហាសន្តិសុខ យោធា និងវិន័យ ហើយគាត់ក៏បានចូលរួមនៅក្នុងការបោសសម្អាត និងដាក់វិន័យលើកម្មាភិបាលផងដែរ[210]។

109. នៅក្នុងសាលក្រមសំណុំរឿង ០០២/០១ ចៅក្រមក៏បានរកឃើញផងដែរថា ៖ **(i)** នួន ជា មាន "ជំនឿតាំងពីយូរមកហើយ" ថា ប្រជាជនក្រុងពុករលួយ[211] ហើយគាត់គឺជា "អ្នកគាំទ្រយ៉ាងខ្លាំងក្លាចំពោះការធ្វើការ "តស៊ូវណ្ណៈ"" **(ii)** តាមរយៈតួនាទីរបស់គាត់ខាងឃោសនាអប់រំ នួន ជា "បានជំរុញមាគ៌ាបក្សស្តីពីការប្រុងប្រយ័ត្នចំពោះខ្មាំងខាងក្នុង និងខ្មាំងខាងក្រៅ" និងបានបំពាក់បំប៉នប្រជាជនមូលដ្ឋានឱ្យស្អប់ខ្មាំងដែលត្រូវបានកំណត់អត្តសញ្ញាណ រួមទាំង "ប្រជាជនថ្មី" និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ហើយ **(iii)** នួន ជា "*បានដឹង*ថា ការបំពាក់បំប៉នមនោគមន៍វិជ្ជាឱ្យមានការស្អប់ខ្ពើមបែបនេះ ប្រាកដជានឹងនាំឱ្យមានអំពើហិង្សា" និង "*បានដឹង*ថា មានភវនីយភាពច្បាស់លាស់ដែលថា នឹងមានការប្រព្រឹត្តិឧក្រិដ្ឋកម្មផ្សេងៗ"[212]។

110. តួនាទីរបស់ នួន ជា ជារួម និងជាពិសេស ពាក់ព័ន្ធនឹងការបង្កើត និងការជំរុញគោលនយោបាយ

---

[208] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៩៨, ៨៥៧, ៨៦១, ៨៨៤, ៨៩៣ (គូសបញ្ជាក់បន្ថែម)។

[209] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៣៣, ៣៩១។

[210] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៣២៩, ៣៩០, ៣៩១, ៨៩៣-៨៩៦។

[211] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១១១, ៨៧៣។

[212] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៨៩០, ៨៧៣, ៨៨៧, ៩១៩, ៩២៦ (គូសបញ្ជាក់បន្ថែម)។

ស្តីពីការកំណត់គោលដៅលើខ្មាំង (រួមទាំង "ប្រជាជនថ្មី" និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ) ព្រមទាំងការចូលរួមនៅក្នុងការងារយោធា និងសន្តិសុខ មានការពាក់ព័ន្ធយ៉ាងខ្លាំងនឹងសំណុំរឿង ០០២/០២ និងជាបញ្ហាសំខាន់ទាក់ទងនឹងការចោទប្រកាន់អំពីពិរុទ្ធភាពរបស់ នួន ជា នៅក្នុងសំណុំរឿង ០០២/០២។ ជាពិសេស ករណីនេះ រួមទាំងការទទួលខុសត្រូវរបស់គាត់ចំពោះអំពើប្រល័យពូជសាសន៍ដែលបានចោទប្រកាន់ថាបានកើតឡើងលើជនជាតិវៀតណាម និងជនជាតិចាម និងការសម្លាប់អ្នកជាប់ឃុំនៅមន្ទីរសន្តិសុខ ស-២១ ព្រមទាំងការបោសសម្អាតផ្ទៃក្នុង។

111. ការសម្រេចខាងលើរបស់ចៅក្រមមិនត្រឹមតែជា*ការកំណត់ជាមុន* លើបញ្ហានានាទាក់ទងនឹងការចោទប្រកាន់អំពីពិរុទ្ធភាពរបស់ នួន ជា នៅក្នុងសំណុំរឿង ០០២/០២ ប៉ុណ្ណោះនោះទេ វាបាននាំដល់ទស្សនៈអវិជ្ជមាន*ដែលមានការសន្និដ្ឋានជាមុន*ដល់រឿងក្តីនាពេលខាងមុខរបស់មេធាវីការពារក្តីនៅក្នុងសំណុំរឿង ០០២/០២។ ដូច្នេះ មេធាវីការពារក្តីសូមសន្និដ្ឋានថា ការសម្រេចទាំងនេះនឹងនាំឱ្យលេចចេញនូវភាពលម្អៀងដែលមិនអាចទទួលយកបាន ប្រសិនបើចៅក្រមនៅតែបន្តចូលរួមជំនុំជម្រះក្នុងសំណុំរឿង ០០២/០២។

## *(v) ទស្សនៈយល់ឃើញរបស់ជនជាប់ចោទ និងលើរឿងក្តីរបស់មេធាវីការពារក្តី*

112. នៅក្នុងសាលក្រមសំណុំរឿង ០០២/០១ ចៅក្រមបានសម្រេចថា ៖ **(i)** ភាគច្រើននៃ "វណ្ណៈដឹកនាំថ្មី" ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ (ពោលគឺ "កសិករថ្នាក់ទាបបំផុត") "ទទួលការអប់រំក្នុងប្រព័ន្ធតិចតួចបំផុត" ហើយ "ពួកគេទាំងអស់បានឆ្លងកាត់វិន័យ ទទួលបានការបំពាក់បំប៉នមនោគមន៍វិជ្ជា ហើយត្រូវបានបង្រៀនយ៉ាងតឹងរ៉ឹងឱ្យ*បោកបញ្ឆោត*ប្រជាជន និងអនុវត្តតាមគោលការណ៍*រក្សាការសម្ងាត់*"[213] **(ii)** បក្សកុម្មុយនីស្តកម្ពុជាបានប្រើប្រាស់ទស្សនៈអំពីការទម្លាក់គ្រាប់បែកដោយសហរដ្ឋអាមេរិក ជា "លេស" ដើម្បី "បោកបញ្ឆោត" ប្រជាជនក្រុងដើម្បីជម្លៀសក្រុងភ្នំពេញ **(iii)** ក្រោយមក បក្សកុម្មុយនីស្តកម្ពុជាបានផ្តល់ហេតុផលនៃការផ្លាស់ទីលំនៅប្រជាជនក្នុងទ្រង់ទ្រាយធំ "ដោយយក*លេស*ថា ដោយសារពួកគេយកចិត្តទុកដាក់លើប្រជាជន" **(iv)** ស្រដៀងគ្នានេះដែរ បក្សកុម្មុយនីស្តកម្ពុជាបានប្រមូលផ្តុំទាហាននៃសាធារណរដ្ឋខ្មែរដោយមធ្យោបាយ "បោកបញ្ឆោត" នៅមុនពេលសម្លាប់ពួកគេចោល និង **(v)** "ការភូតកុកហាក់ដែលត្រូវបានយកមកប្រើប្រាស់ដើម្បីគ្រប់គ្រងលើស្ថានភាព និងប្រជាជនគឺជា "មូលដ្ឋានដ៏សំខាន់" របស់របប

---

[213] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៨៤០ (គូសបញ្ជាក់បន្ថែម)។

នោះ”[214]។

113. យោងតាមយុត្តិសាស្ត្រដូចបានបង្ហាញខាងលើ *ការសន្និដ្ឋានមុន*លើទស្សនៈអវិជ្ជមានដល់រឿងក្តីរបស់ភាគីមួយ ដូចជា ទស្សនៈអំពីសុពលភាព និងភាពអាចទុកចិត្តបាននៃទឡ្ហីករណ៍ និងយុទ្ធសាស្ត្ររបស់ភាគី អាចនាំឱ្យមានការភ័យខ្លាចដ៏សមហេតុផលមួយអំពីភាពលម្អៀង។ នៅក្នុងរឿងក្តី *Buscemi ទល់នឹង ប្រទេសអ៊ីតាលី* តុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចថា វាមានការភ័យខ្លាចដ៏សមហេតុផលមួយអំពីភាពលម្អៀង ដោយហេតុថាចៅក្រមទាំងនេះបានបង្ហាញទស្សនៈរួចហើយថា ការរៀបរាប់ហេតុការណ៍របស់ម្ចាស់បណ្តឹង ពុំ “ត្រឹមត្រូវ” ហើយម្ចាស់បណ្តឹងគឺជាជនកុហក “នៅមុនពេលធ្វើការជំនុំជម្រះក្តីនៅក្នុងតុលាការនោះ”[215]។

114. មេធាវីការពារក្តីសូមសន្និដ្ឋានថា ការសម្រេចរបស់ចៅក្រមដូចបានលើកឡើងខាងលើបានបង្ហាញយ៉ាងច្បាស់ថា ចៅក្រមមានទស្សនៈអវិជ្ជមានអំពីបក្សកុម្មុយនីស្តកម្ពុជា និងអំពីទឡ្ហីករណ៍សំខាន់ៗមួយចំនួនរបស់ជនជាប់ចោទ ដោយបានពិពណ៌នាទឡ្ហីករណ៍ទាំងនេះថាជាការបោកបញ្ឆោត ឬត្រឹមតែជាលេសតែប៉ុណ្ណោះ ហើយដោយយល់ឃើញថា សារតារមូលដ្ឋាន និងទឡ្ហីករណ៍ដែលជនជាប់ចោទនឹងលើកឡើងគឺវានឹងដូចគ្នាដែលនៅក្នុងសំណុំរឿង ០០២/០២ ហេតុដូច្នេះចៅក្រមគួរត្រូវបានដកចេញពីក្នុសំណុំរឿង ០០២/០២ ដោយសារចៅក្រមពុំមានភាពអព្យាក្រឹតដែលអាចទទួលយកបាន។

## ង. ការសម្រេចរបស់ចៅក្រម ណុន ចៅក្រមសុខន និងចៅក្រម *Lavergne* នៅក្នុងសាលក្រម ឧុច លើអង្គហេតុពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ នាំឱ្យលេច*ចេញ*នូវភាពលម្អៀងទាក់ទងនឹងសំណុំរឿង ០០២/០២[216]

115. នៅក្នុងផ្នែកនេះ មេធាវីការពារក្តីលើកសេចក្តីសន្និដ្ឋានស្រដៀងទៅនឹងសេចក្តីសន្និដ្ឋានដែលបានលើកឡើងក្នុងផ្នែក ង ខាងលើ ពោលគឺ ការសម្រេចរបស់ចៅក្រមនៅក្នុងសាលក្រមសំណុំរឿង

---

[214] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១២០, ៥១១, ៥៣០, ៥៤៨, ៦៣៤, ៨០៣, ៨៥៣, ៩៥៤, ៩៨៧, ១០១០, ១០៤៨។

[215] សាលក្រមក្នុងរឿងក្តី Buscemi កថាខណ្ឌ ៤០-៤១, ៦៨។

[216] ពាក្យសុំត្រង់ផ្នែកនេះទាក់ទងតែជាមួយនឹងចៅក្រមចំនួន ៣ រូប ដែលជាសមាជិកក្រុមប្រឹក្សាជំនុំជម្រះយ៉ាងសកម្មនៅក្នុងសំណុំរឿង ០០១ ហើយពុំអនុវត្តចំពោះចៅក្រម ឧត្តរ៉ា ដែលជាចៅក្រមបម្រុងនៅក្នុងរឿងក្តីនេះឡើយ។

០០១ លើអង្គហេតុពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២។ ទោះបីជាយ៉ាងនេះក៏ដោយ ទឡ្ហីករណ៍នៅក្នុងផ្នែកនេះទាក់ទងតែចំពោះចៅក្រម ណុន ចៅក្រមសុខន និងចៅក្រម Lavergne តែប៉ុណ្ណោះ ដោយសារចៅក្រមទាំងនេះបានជំនុំជម្រះនៅក្នុងសំណុំរឿង ០០១ និងសំណុំរឿង ០០២/០១ យ៉ាងសកម្ម ចំណែកចៅក្រម ឧត្ដារ៉ា ជាចៅក្រមបម្រុងនៅក្នុងសំណុំរឿង ០០១។

116. នៅក្នុងសេចក្ដីសម្រេចលើបណ្ដឹងជំទាស់លើកទីមួយ ក្រុមប្រឹក្សាជំនុំជម្រះពិសេសបាន សម្រេចថា សេចក្ដីសន្និដ្ឋានដែលបានលើកឡើងដោយចៅក្រមក្នុងសំណុំរឿង ០០១ ទាក់ទងនឹង នួន ជា ពុំមែនជាការកំណត់ជាមុនលើពិរុទ្ធភាពរបស់គាត់ ដែលអាចប្ដឹងជំទាស់បាន ដោយសារសេចក្ដីសន្និដ្ឋានទាំងនេះពាក់ព័ន្ធតែធាតុផ្សំខ្លះនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់គាត់នៅក្នុងសំណុំរឿង ០០២[217]។ ក៏ប៉ុន្តែ ដូចមេធាវីការពារក្ដីបានសន្និដ្ឋានខាងលើ ករណីនេះផ្ទុះបញ្ចាំងនូវការបកស្រាយដោយភាន់ច្រឡំលើ "ការធ្វើបុរេវិនិច្ឆ័យលើពិរុទ្ធភាព"[218]។ ចៅក្រមពុំមានភាពចាំបាច់ត្រូវធ្វើបុរេវិនិច្ឆ័យលើគ្រប់ និងរាល់ធាតុផ្សំដែលដាក់បន្ទុកលើជនជាប់ចោទឡើយ។ ប៉ុន្តែ វាមានលក្ខណៈគ្រប់គ្រាន់ ប្រសិនបើចៅក្រមបានសន្និដ្ឋានជាមុនលើទស្សនៈទូទៅមួយអំពី "លក្ខខណ្ឌនៃ*ការចូលរួមរបស់*ម្ចាស់បណ្ដឹង [] ថាមាន*លក្ខណៈឧក្រិដ្ឋ ឬក៏មិនមានលក្ខណៈឧក្រិដ្ឋ*"[219]។ម្យ៉ាងវិញទៀត ដូចចៅក្រម Buergenthal បានផ្ដល់ទឡ្ហីករណ៍រួចហើយ វាមានលក្ខណៈគ្រប់គ្រាន់ក្នុងការរកឃើញថា ចៅក្រមមានលេចចេញនូវភាពលម្អៀង ប្រសិនបើចៅក្រមរូបនោះ "បានធ្វើបុរេវិនិច្ឆ័យលើបញ្ហា *មួយ ឬ ច្រើន* ពាក់ព័ន្ធនឹងកម្មវត្ថុយុត្តាធិការ"[220]។

117. ហេតុដូច្នេះ មេធាវីការពារក្ដីសូមសន្និដ្ឋានថា ការសម្រេចនៅក្នុងសាលក្រម ឌុច ពិតជាបានបង្កើតឱ្យឃើញពីការលេចចេញនូវភាពលម្អៀងដែលមិនអាចទទួលយកបាន បើទោះជាការសម្រេចទាំងនោះពុំបង្ហាញអំពីការធ្វើបុរេវិនិច្ឆ័យលើធាតុផ្សំមួយ និងធាតុផ្សំទាំងអស់នៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ក៏ដោយ។ មេធាវីការពារក្ដីសូមសន្និដ្ឋានទៀតថា ទឡ្ហីករណ៍បែបនេះបានលើកឡើងទាន់ពេលវេលា ដូច្នេះអាចទទួលយកបាន។ ដោយសារថា ចៅក្រមបានសំអាងលើសក្ខីកម្មរបស់ កាំង ហ្គេកអ៊ាវ *ហៅ* ឌុច នៅក្នុងសាលក្រមសំណុំរឿង ០០២/០១ និងសំអាងហេតុនៅក្នុង

---

[217] *សូមមើល* កថាខណ្ឌ ៧ ខាងលើ។

[218] *សូមមើល* ឯកសារ E55/4 សេចក្ដីសម្រេចលើកទីមួយលើសំណើសុំប្ដឹងជំទាស់ កថាខណ្ឌ ២១, ២៤។

[219] សាលក្រមក្នុងរឿងក្ដី Poppe កថាខណ្ឌ ២៨ (គូសបញ្ជាក់បន្ថែម)។

[220] មតិយោបល់របស់ចៅក្រម Buergenthal កថាខណ្ឌ ១១។

សាលក្រម ឌុច[221] មេធាវីការពារក្តីត្រូវបានអនុញ្ញាតឲ្យបង្ហាញភ័ស្តុតាងពីមុនៗដើម្បី "រៀបរាប់លម្អិតបន្ថែម ឬ សម្រាប់គាំទ្រ" ភ័ស្តុតាងថ្មី ពីព្រោះថា ភ័ស្តុតាងពីមុនៗមានភាពពាក់ព័ន្ធលើបរិបទបច្ចុប្បន្នដែលលេចចេញពីការសម្រេចនៅក្នុងសាលក្រមសំណុំរឿង ០០២/០១[222]។ លើសពីនេះ ក្រោយពេលវិសាលភាពនៃសំណុំរឿង ០០២/០២ ត្រូវបានជូនដំណឹងជាក់លាក់ដល់ភាគីនៅថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១៤ តែប៉ុណ្ណោះ ទើបមេធាវីការពារក្តីអាចបង្ហាញជាក់លាក់ថាតើកថាខណ្ឌណាខ្លះនៅក្នុងដីកាដំណោះស្រាយទាក់ទងនឹងមន្ទីរសន្តិសុខ ស-២១ ដែលនឹងត្រូវជំទាស់នៅក្នុងការជំនុំជម្រះលើសំណុំរឿង ០០២/០២[223]។

118. ទាក់ទងនឹងមន្ទីរសន្តិសុខ ស-២១ ដីកាដំណោះស្រាយចោទប្រកាន់*ក្នុងចំណោមចំណុចជាច្រើន*ថា "អ្នកជាប់ឃុំជាង ១២.២៧៣ នាក់ ដែលសមាសភាពត្រូវបានរៀបរាប់ពីខាងលើ ត្រូវបានសម្លាប់ចោល"[224]។ យោងតាមសំដីផ្ទាល់ដែលត្រូវបានដកស្រង់ចេញពីសាលក្រម ឌុច "*ផ្អែកតាមគោលនយោបាយក្នុងការ "កម្ទេច" ខ្មាំងនៃបក្សកុម្មុយនីស្តកម្ពុជា អ្នកជាប់ឃុំទាំងឡាយដែលបានជាប់ឃុំនៅមន្ទីរ ស-២១ ត្រូវតែសម្លាប់ទាំងអស់ គ្មានអ្នក ជាប់ឃុំណាម្នាក់ត្រូវបានដោះលែងឡើយ*"[225]។ ""ការពិត" ដែលបាននិយាយនៅក្នុងចម្លើយសារភាព គឺត្រូវបានកំណត់ទុកជាមុនរួចទៅហើយព្រោះថាអ្នកសួរចម្លើយបានបង្ខំឲ្យអ្នកជាប់ឃុំផ្តល់នូវចម្លើយដែលបានកំណត់ទុកជាមុន..."[226] "អ្នកសួរចម្លើយបានប្រើប្រាស់វិធីធ្វើទារុណកម្មតាមរូបភាពផ្សេងគ្នា"[227] ដោយរាប់បញ្ចូលទាំងការរំលោភ[228] ហើយ (យោងតាមការរៀបរាប់តាមសាលក្រម ឌុច ស្ទើរតែដូចទាំងអស់) "កុមារ[មួយ]ចំនួនដែលនាំទៅមន្ទីរ ស-២១ ត្រូវបានសម្លាប់នៅក្នុងបរិវេណនៃមន្ទីរនោះ។ ជាធម្មតា កុមារតូចៗដែលមានអាយុតិចត្រូវបានសម្លាប់ភ្លាមៗ បន្ទាប់ពីបានបំបែកចេញពីឪពុកម្តាយរបស់ពួកគេ

---

[221] *សូមមើល* ឯកសារ E313 សាលក្រមលើសំណុំរឿង០០២/០១ ដូចដែលបានលើកឡើងនៅកថាខណ្ឌ ៩១ ខាងលើ ។

[222] ឯកសារ ៧ សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំប្តឹងជំទាស់ចៅក្រម Lemonde កថាខណ្ឌ ២០។

[223] ឯកសារ E301/9/1.1 វិសាលភាពសំណុំរឿង ០០២/០២។

[224] ឯកសារ D427 "ដីកាដំណោះស្រាយ" កថាខណ្ឌ ៤៦០។

[225] ឯកសារ D427 "ដីកាដំណោះស្រាយ" កថាខណ្ឌ ៤៦១។

[226] ឯកសារ D427 "ដីកាដំណោះស្រាយ" កថាខណ្ឌ ៤៥៥។

[227] ឯកសារ D427 "ដីកាដំណោះស្រាយ" កថាខណ្ឌ ៤៥២។

[228] ឯកសារ D427 "ដីកាដំណោះស្រាយ" កថាខណ្ឌ ៤៥៧-៤៥៩។

ប៉ុន្តែកុមារខ្លះត្រូវបានគេឃុំខ្លួនមួយរយៈខ្លី មុនពេលយកទៅសម្លាប់”[229]។

119. មេធាវីការពារក្តីកត់សម្គាល់ឃើញថា នៅក្នុងពាក្យសុំប្តឹងជំទាស់ អង្គជំនុំជម្រះសាលាដំបូងលើកទីមួយដែលមេធាវីការពារក្តីបានដាក់នៅក្នុងខែ កុម្ភៈ ឆ្នាំ ២០១១ មេធាវីការពារក្តីបានផ្តោតលើការសម្រេចក្នុងសាលក្រម ឌុច ដែលបានបង្ហាញធាតុផ្សំទូទៅនៃឧក្រិដ្ឋកម្មជាក់លាក់នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ។ ទោះបីជាមេធាវីការពារក្តីបានដកស្រង់ការសម្រេចទាំងនោះសារជាថ្មីដើម្បីគាំទ្រលើពាក្យសុំនេះក៏ដោយ (ត្រង់កថាខណ្ឌ ១២១ ខាងក្រោម) មេធាវីការពារក្តីក៏បានយកសំអាងហេតុថ្មីៗនៅក្នុងសាលក្រម ឌុច មកដាក់បញ្ចូលនៅក្នុងពាក្យសុំនេះ។

120. សំអាងហេតុមួយចំនួននៅក្នុងសាលក្រម ឌុច បង្ហាញថា ចៅក្រម ណុន ចៅក្រមសុខន និង ចៅក្រម Lavergne *បានធ្វើការកំណត់ជាមុន*លើបញ្ហាមួយចំនួន ដែលត្រូវបង្ហាញសារជាថ្មីឡើងវិញនៅក្នុងសំណុំរឿង ០០២/០២។ ឧទាហរណ៍នៃសំអាងហេតុទាំងនេះរួមមាន ៖ **(i)** ***ចំពោះការកាប់សម្លាប់នៅ ស-២១*** ទោះបី “តួលេខនៃអ្នកជាប់ឃុំដែលបានស្លាប់ និងត្រូវបានគេសម្លាប់ មិនអាចកំណត់ចំនួនឱ្យបានច្បាស់លាស់ [...] អង្គជំនុំជម្រះអាចកំណត់បានថា ចំនួនអ្នកជាប់ឃុំមានមិនតិចជាង ១២.២៧២ នាក់នោះឡើយ”[230] **(ii)** ***ចំពោះលទ្ធភាពនៃការដោះលែងចេញពី ស-២១*** “ជនគ្រប់រូបដែលត្រូវ បានឃុំខ្លួននៅមន្ទីរស-២១ សុទ្ធតែរង់ចាំការសម្លាប់ទាំងអស់””[231] ហើយថា “ផ្អែកតាមគោលនយោបាយក្នុងការ “កម្ទេច” ខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា អ្នកជាប់ឃុំទាំងឡាយដែល បានជាប់ឃុំនៅមន្ទីរស-២១ ត្រូវតែសម្លាប់ទាំងអស់ គ្មានអ្នកជាប់ឃុំណាម្នាក់ត្រូវបានដោះលែងឡើយ”[232] **(iii)** ***ចំពោះ “គោលនយោបាយកម្ទេច” ដូចដែលបានចោទប្រកាន់*** គោលនយោបាយនេះគឺ “សម្រាប់ “មន្ទីរស-២១ បក្សទាំងមូល កងទ័ព អាជ្ញាធរមូលដ្ឋាន និងផ្នែកសន្តិបាលទូទាំងប្រទេស” ហើយ “ពាក្យនេះមិនពាក់ព័ន្ធត្រឹមតែការសម្លាប់តែប៉ុណ្ណោះ

[229] ឯកសារ D427 “ដីកាដំណោះស្រាយ” កថាខណ្ឌ ៤៧១។

[230] សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ ឯកសារ E188 សាលក្រម ឌុច កថាខណ្ឌ ៣៤០។ *សូមមើលផងដែរ* កថាខណ្ឌ ១៤១ ២០៨។

[231] សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ ឯកសារ E188 សាលក្រម ឌុច កថាខណ្ឌ ១៨០។

[232] សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ ឯកសារ E188 សាលក្រម ឌុច កថាខណ្ឌ ២០៦។ ដូចបញ្ជាក់ខាងលើការសម្រេចនេះគឺដកស្រង់ដោយផ្ទាល់ពីដីកាដំណោះស្រាយសំណុំរឿង០០២។

នោះទេ គឺវាទាក់ទងទៅនឹងការកម្ទេចដោយផ្នែកចិត្តសាស្ត្រផងដែរ [...] កម្ទេច មានន័យជ្រាលជ្រៅជាងពាក្យថាសម្លាប់ទៅទៀត”[233] **(iv)** ***ចំពោះការសួរចម្លើយ*** “ដោយសារតែអ្នកជាប់ឃុំទាំងអស់ត្រូវបានគេចាត់ទុកថាមានកំហុសរួច ហើយ ដូច្នេះតួនាទីរបស់អ្នកសួរចម្លើយគឺ “ធ្វើឲ្យត្រឹមត្រូវទៅតាមសេចក្តីសម្រេចរបស់បក្សក្នុងការស្រង់យកចម្លើយឲ្យបានពេញលេញ”[234] **(v)** លើការធ្វើទារុណកម្មថា ការគម្រាមកំហែង “ត្រូវបានប្រើប្រាស់ជាទូទៅក្នុងការអនុវត្ត” និងយ៉ាងហោចណាស់មានករណីរំលោភមួយបានកើតឡើង;[235] និង **(vi)** ***ចំពោះការសម្លាប់ កុមារតូចៗ*** “ជាធម្មតា កុមារតូចៗដែលមានអាយុតិចត្រូវបានសម្លាប់ភ្លាមៗ បន្ទាប់ពីបានបំបែកចេញពីឪពុកម្តាយរបស់ពួកគេ ប៉ុន្តែ កុមារខ្លះត្រូវបានគេឃុំខ្លួនមួយរយៈខ្លីមុនពេលយកទៅសម្លាប់”[236] (ដូចបានលើកឡើងខាងលើ ការសម្រេចនេះគឺយកទៅតាមពាក្យពេចន៍ស្ទើរតែដូចបេះបិទនៅក្នុងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២)។

121. លើសពីនេះ នៅក្នុងសាលក្រម ឌុច ចៅក្រម ណុន ចៅក្រមសុខន និងចៅក្រម Lavergne បានធ្វើការកំណត់ជាមុនរួចហើយថា ធាតុផ្សំទូទៅសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរនៅ ស-២១ ត្រូវបានបង្ហាញហួសពីវិមតិសង្ស័យ[237]។ ស្រដៀងគ្នានេះដែរ ចៅក្រម ណុន ចៅក្រមសុខន និងចៅក្រម Lavergne បានរកឃើញហួសពីវិមតិសង្ស័យរួចហើយថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ*ជាក់លាក់* និងការរំលោភបំពានធ្ងន់ធ្ងរពិតជាបានប្រព្រឹត្តឡើងនៅ ស-២១ មែន[238]។ អាស្រ័យហេតុនេះ ក្រៅពីបញ្ហាទាំងឡាយដូចបានលើកឡើងខាងលើ

---

[233] សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ ឯកសារ E188 សាលក្រម ឌុច កថាខណ្ឌ ១០០។

[234] សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ ឯកសារ E188 សាលក្រម ឌុច កថាខណ្ឌ ១៥៥។

[235] សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ ឯកសារ E188 សាលក្រម ឌុច កថាខណ្ឌ៣៥៩, ៣៦៦។

[236] សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ ឯកសារ E188 សាលក្រម ឌុច កថាខណ្ឌ ២១៥។

[237] សាលក្រមក្នុងរឿងក្តី Poppe កថាខណ្ឌ ៣-៦។ សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ ឯកសារ E188 សាលក្រម ឌុច កថាខណ្ឌ ៣២០-៣២១, ៣២៥, ៣២៧ (ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ) និង ៤៣២-៤២៦ (ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ)។

[238] សាលក្រមក្នុងរឿងក្តី Poppe កថាខណ្ឌ ៧-៨។ សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ ឯកសារ E188 សាលក្រម ឌុច៖ *ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ* កថាខណ្ឌ ៣៣៩-៣៤១ (ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល) ៣៤៦ (ការធ្វើឲ្យទៅជាទាសករ) ៣៥១ (ការដាក់ពន្ធនាគារដោយចេតនា និងតាមទំនើងចិត្ត) ៣៥៩-៣៦០ (ការធ្វើទារុណកម្ម) ៣៧២-៣៧៣ (អំពើអមនុស្សធម៌ផ្សេងទៀត) ៣៨១-៣៩០ (ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ។ *ការរំលោភ*

ដែលចៅក្រមបាន*ធ្វើការកំណត់ជាមុន*រួចហើយនោះ បញ្ហាទាំងអស់ដែលនៅសល់សម្រាប់ ក.ស.ព បង្ហាញពិរុទ្ធភាពរបស់ នួន ជា នៅក្នុងសំណុំរឿង ០០២/០២ គឺការភ្ជាប់ទំនាក់ទំនងរបស់ គាត់ ជាមួយនឹង "ប្រព័ន្ធធ្វើបាប" នៅ ស-២១[239]។ ដូច្នេះ មេធាវីការពារក្តីសូមសន្និដ្ឋានថា ការសម្រេច ទាំងនេះនៅក្នុងសាលក្រម ឌុច គឺជា*ការធ្វើការកំណត់ជាមុន* លើបញ្ហាទាំងឡាយដែលមាន សារៈសំខាន់បំផុតលើការសម្រេចអំពីពិរុទ្ធភាពរបស់ នួន ជា ដូចបានចោទប្រកាន់នៅក្នុងសំណុំ រឿង ០០២/០២ ដែលវាអាចធ្វើឲ្យអ្នកសង្កេតការណ៍ដែលមិនលម្អៀងម្នាក់យល់ថា បញ្ហានេះនាំឲ្យ លេចចេញនូវភាពលម្អៀងដែលមិនអាចទទួលយកបាន ជាហេតុតម្រូវឲ្យដកចៅក្រម ណុន ចៅក្រមសុខន និងចៅក្រម Lavergne ចេញពីការជំនុំជម្រះនៅក្នុងសាលក្រមសំណុំរឿង ០០២/០២។

## ជ. ការសម្រេចនៅក្នុងសំណុំរឿង ០០២/០១ និងសាលក្រម ឌុច គឺជាការច្រានចោលបន្ទុកក្នុងការបង្ហាញភស្តុតាង

122. ការសម្រេចរបស់ចៅក្រមនៅក្នុងសំណុំរឿង ០០២/០១ និងនៅក្នុងសាលក្រម ឌុច មិនត្រឹមតែនាំឲ្យចៅក្រមលេចចេញនូវភាពលម្អៀងដែលមិនអាចទទួលយកបានប៉ុណ្ណោះនោះទេ មេធាវីការពារក្តីសូមសន្និដ្ឋានថា ការសម្រេចទាំងនេះក៏បណ្តាលឲ្យមានការច្រានចោលបន្ទុកក្នុងការបង្ហាញភ័ស្តុតាងយ៉ាងមានប្រសិទ្ធភាពផងដែរ។ ការឆ្លើយតបទៅនឹងបទចោទនៅក្នុងករណី០០២/០២ នៅចំពោះមុខចៅក្រមដែលបានសម្រេចលើបញ្ហាសំខាន់ៗជាច្រើន នឹងតម្រូវឲ្យមេធាវីបញ្ចុះបញ្ចូលចៅក្រមទាំងនោះថាពួកគេមានកំហុស ជំនួសឲ្យការបង្ហាញថា សហព្រះរាជអាជ្ញាមិនបានបំពេញបន្ទុកនៃការបង្ហាញភស្តុតាង។ ប្រសិនបើចៅក្រមនៅបន្តធ្វើជាក្រុមប្រឹក្សាជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ទៀត ករណីនេះនឹងនាំឲ្យមានការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើសិទ្ធិជាមូលដ្ឋាន និងសិទ្ធិ

---

*បំពានលើអនុសញ្ញាទីក្រុងហ្សឺណែវ* ៤៣៧ (ការសម្លាប់ដោយចេតនា) ៤៤៨ (ការធ្វើទារុណកម្ម) ៤៤៩ (ការប្រព្រឹត្ត អមនុស្សធម៌) ៤៥៧ (ការធ្វើឲ្យឈឺចាប់ដោយចេតនា) ៤៦២-៤៦៣ (ការដកហូតសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌) ៤៦៨-៤៦៩ (ការដាក់ពន្ធនាគារតាមទំនើងចិត្ត ឬដោយខុសច្បាប់)។

[239] សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ ឯកសារ E188 សាលក្រម ឌុច កថាខណ្ឌ ៥១៤ ("[ឌុច]បាន ប្រព្រឹត្តអំពើ [...] ដើម្បីប្រតិបត្តិការមន្ទីរស២១ ដែលត្រូវបានគេចាត់ទុកថាជាកន្លែង ឃុំខ្លួន សួរចម្លើយ និងសម្លាប់ដោយ ខុសច្បាប់ចំពោះជនទាំងឡាយដែលគេយល់ថាជាសត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជា ទាំងជនជាតិខ្មែរ និងជនបរទេស។ ប្រព័ន្ធសហការរួមនៃការធ្វើបាប និងការធ្វើទារុណកម្ម ត្រូវបានអនុវត្តដោយចេតនាដើម្បីបង្ក្រាបអ្នកជាប់ឃុំ និងទាញយក ចម្លើយសារភាព ពីអ្នកជាប់ឃុំក្នុងពេលសួរចម្លើយ")។

មិនអាចរំលោភបានរបស់ នួន ជា ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ពោលគឺ សិទ្ធិ "ត្រូវសន្មតទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ"[240]។

## ឈ. ចៅក្រមបានបង្ហាញនូវកង្វះសុចរិតភាពផ្នែកវិជ្ជាជីវៈដែលមិនអាចទទួលយកបាន

123. រហូតដល់ពេលនេះ មេធាវីការពារក្ដីបានធ្វើការចោទប្រកាន់ជាច្រើនចំណុចថា ចៅក្រមមានលេចចេញនូវភាពលម្អៀងដែលមានរួចស្រាប់ ឬនាពេលខាងមុខ ហើយលើសពីនេះ ក្នុងករណីចៅក្រមជាតិវិញ ពួកគាត់ខ្វះនូវភាពឯករាជ្យ។ ការចោទប្រកាន់ទាំងនេះបានយោងលើភស្តុតាងគាំទ្រស្រដៀងគ្នាជាច្រើន រួមទាំង ការសម្រេចនៅក្នុងសាលក្រមសំណុំរឿង ០០២/០១ ផងដែរ (ដែលភស្តុតាងទាំងនេះមួយចំនួនក៏ត្រូវបានចោទប្រកាន់ថាមានការភាន់ច្រឡំផងដែរ) ការសម្រេចនៅក្នុងសាលក្រម ឌុច ព័ត៌មានលើលក្ខណៈចម្រូងចម្រាស់នៃបរិបទតុលាការជាតិ និងសេចក្ដីថ្លែងការណ៍គួរឱ្យព្រួយបារម្ភដោយអតីតចៅក្រមអន្តរជាតិនៃ អ.វ.ត.ក ចំនួនពីររូបនៅក្នុងសុន្ទរកថាថ្លែងឡើងនៅវិទ្យាស្ថាន Aspen និងនៅក្នុងសៀវភៅរបស់ចៅក្រម Lemonde ដែលបានវាយប្រហារលើចំណុចសំខាន់របស់ស្ថាប័នតុលាការនេះ។ ជាការពិតណាស់ ដើម្បីបញ្ជាក់លើចំណុចចុងក្រោយនេះ មេធាវីការពារក្ដីសូមលើកឡើងចំណុចសំខាន់ចុងក្រោយថា ការលេចចេញនូវភាពលម្អៀងទាំងស្រុងរបស់ចៅក្រមដូចបានចោទប្រកាន់ នៅពេលយកមកពិចារណារួមគ្នា វាមិនត្រឹមតែបង្ហាញថា ចៅក្រមខ្វះសុចរិតភាពផ្នែកវិជ្ជាជីវៈចាំបាច់ក្នុងនាមជាចៅក្រមនៅក្នុងអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក នេះប៉ុណ្ណោះទេ វាថែមទាំងធ្វើឱ្យប៉ះពាល់ដល់នីត្យានុកូលភាពនៃ អ.វ.ត.ក ទាំងមូលផងដែរ។

124. នៅក្នុងរឿងក្ដីរបស់ *Katanga* នៃតុលាការ ICC ចៅក្រម Van den Wyngaert បានផ្ដល់ការសង្កេតមួយដ៏ឆ្លាតវៃអំពីបញ្ហាប្រឈមដែលចៅក្រមតតាំង និងភារកិច្ចដែលក្រុមត្រូវបំពេញនៅពេលធ្វើជាចៅក្រមជំនុំជម្រះនៅក្នុងសាលក្រមលើរឿងក្ដីទាំងឡាយ ដែលពាក់ព័ន្ធនឹងការចោទប្រកាន់លើឧក្រិដ្ឋកម្មឃោរឃៅធំៗ។ មេធាវីការពារក្ដីបានចាត់ទុកការសង្កេតរបស់លោកស្រីចៅក្រមរូបនេះថាមានការពាក់ព័ន្ធទាំងស្រុងនឹងបរិបទនៃ អ.វ.ត.ក ហេតុដូច្នេះ មេធាវីការពារក្ដីសូមលើកឡើងការសង្កេតនេះទាំងស្រុងដូចខាងក្រោម ៖

---

[240] រដ្ឋធម្មនុញ្ញកម្ពុជា មាត្រា ៣៨។ ច្បាប់ អ.វ.ត.ក មាត្រា ៣៥ ថ្មី។ សេចក្ដីប្រកាសជាសាកលស្ដីពីសិទ្ធិមនុស្ស មាត្រា ១១(១)។ កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៤។

ការជំនុំជម្រះប្រភេទនេះគឺជាការជំនុំជម្រះដ៏ពិបាក និងស្មុគស្មាញ ទាំងផ្នែកអង្គច្បាប់ និងទស្សនៈលើភស្តុតាង។ ម្យ៉ាងវិញទៀត ការជំនុំជម្រះទាំងនេះមានការប្រឈមលើបញ្ហាមនុស្សជាតិ។ *ការអាណិតអាសូរលើស្ថានភាពលំបាករបស់ជនរងគ្រោះ និងការយល់ដឹងជាបន្ទាន់ថា តុលាការនេះត្រូវបានបង្កើតឡើងដើម្បី "បញ្ចប់និទណ្ឌភាព" គឺជាកត្តាជំរុញដ៏មានអានុភាព។ ក៏ប៉ុន្តែ ភាពជោគជ័យ ឬ ការបរាជ័យរបស់តុលាការនេះមិនអាចវាស់វែងតែលើ "មនុស្សអាក្រក់" ដែលត្រូវបានសម្រេចឱ្យមានពិរុទ្ធភាព និងជនរងគ្រោះស្កុតត្រង់ដែលបានទទួលសំណងប៉ុណ្ណោះទេ។ សំខាន់បំផុត ភាពជោគជ័យ និងការបរាជ័យត្រូវបានកំណត់ថាតើកិច្ចដំណើរការនីតិវិធីជារួមមានភាពយុត្តិធម៌ និងត្រឹមត្រូវដែរឬទេ។*

ខ្ញុំយល់ឃើញថា *ការជំនុំជម្រះសំខាន់បំផុតត្រូវមានភាពយុត្តិធម៌ចំពោះជនជាប់ចោទ។ ការពិចារណាអំពីភាពយុត្តិធម៌ផ្នែកនីតិវិធីសម្រាប់អយ្យការ និងជនរងគ្រោះ និងមេធាវីតំណាងរបស់ពួកគេ ទោះបីជាវាពាក់ព័ន្ធក៏ដោយ មិនអាចកេងប្រយោជន៍លើសិទ្ធិរបស់ជនជាប់ចោទនោះទេ។* ជារួមមក ការលើកឡើងទាំងអស់នេះគឺថាមានតែជនជាប់ចោទតែម្នាក់គត់ដែលត្រូវបានយកមកជំនុំជម្រះ និងអាចប្រឈមនឹងការបាត់បង់សេរីភាព និងទ្រព្យសម្បត្តិរបស់គេ។ ដើម្បីឱ្យតុលាការមានអំណាចតាមផ្លូវច្បាប់ និងផ្លូវសីលធម៌ អាចចេញសាលក្រមតាមផ្លូវច្បាប់ និងតាមផ្លូវសីលធម៌លើនរណាម្នាក់បាននោះ ជាពិសេស នៅពេលវាពាក់ព័ន្ធនឹងការចោទប្រកាន់ធ្ងន់ធ្ងរបែបនេះ ដូចជាឧក្រិដ្ឋកម្មអន្តរជាតិ ខ្ញុំយល់ឃើញថា វាមានសារៈសំខាន់ត្រូវសង្កេតមើលឱ្យបានហ្មត់ចត់លើភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី និងត្រូវអនុវត្តបទដ្ឋាននៃការបង្ហាញភស្តុតាងឱ្យមានភាពស៊ីសង្វាក់គ្នា និងរឹងមាំ។ *វាមិនជាការល្អគ្រប់គ្រាន់នោះទេ ប្រសិនបើការជំនុំជម្រះភាគច្រើនមានភាពយុត្តិធម៌។ វាត្រូវតែយុត្តិធម៌ទាំងអស់*[241]។

125. នៅក្នុងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី នៅ អ.វ.ត.ក ការតវ៉ាទាំងឡាយដែលចៅក្រម Van den Wyngaert គូសបញ្ជាក់ ពោលគឺ ការអាណិតស្សូរដល់ជនរងគ្រោះ និងគោលបំណងក្នុងការបញ្ចប់និទណ្ឌភាព គឺត្រូវសង្កត់ធ្ងន់ធ្ងរលើគុណសម្បត្តិជាមូលដ្ឋានមួយក្នុងចំណោមគុណសម្បត្តិដែលចៅក្រមគួរមានគឺ សុចរិតភាពផ្នែកសីលធម៌របស់ចៅក្រម[242]។

126. សុចរិតភាពផ្នែកសីលធម៌របស់ចៅក្រម[243] ត្រូវបានឱ្យនិយមន័យដោយសាស្ត្រាចារ្យ Hans

[241] មតិយោបល់របស់ចៅក្រម Van den Wyngaert រឿងក្តី Katanga កថាខណ្ឌ ៣១០ ៣១១ (គូសបញ្ជាក់បន្ថែម)។

[242] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៣(៣)។ *សូមមើល ផងដែរ* ច្បាប់ អ.វ.ត.ក មាត្រា ១០ថ្មី។

[243] នៅក្នុងសាលក្រមនេះ ទស្សនទាននេះត្រូវបានហៅថាជា "សុចរិតភាពផ្នែកសីលធម៌"។

Kelsen និងត្រូវបានដកស្រង់យល់ស្របនៅក្នុងមតិយោបល់ជំទាស់របស់ចៅក្រមល្បីល្បាញមួយរូបគឺចៅក្រម Radhabinod នៅសាលាក្តីយោធាអន្តរជាតិ Tokyo សម្រាប់ចុងបូព៌ា ថាជា៖

> វិធីធានាសេរីភាពមួយពីការធ្វើបុរេវិនិច្ឆ័យ ការត្រៀមខ្លួនជាស្រេចក្នុងការប្រឈមនឹងផលវិបាកកើតចេញពីទស្សនៈយល់ឃើញដែលមិនមានរួមគ្នា ការគោរពដំណើរការតុលាការ និងការស្ម័គ្រចិត្តលះបង់ ដែលជាភារកិច្ចរបស់តុលាការត្រូវបំពេញ[244]។

127. មេធាវីការពារក្តីសន្និដ្ឋានថា នៅក្នុងសាលក្រមសំណុំរឿង ០០២/០១ និងសេចក្តីសម្រេចចុងក្រោយលើសាក្សីពាក់ព័ន្ធ ចៅក្រមពុំបានបំពេញតាមលក្ខខណ្ឌនៃបទដ្ឋានស្តីពីសុចរិតភាពផ្នែកសីលធម៌របស់តុលាការដែលជាលក្ខខណ្ឌតម្រូវសម្រាប់ចៅក្រមនៅសាលាក្តីនោះឡើយ។ បណ្តឹងជំទាស់...

មានបញ្ហាជាងនេះគឺ ចៅក្រមទំនងជាបង្ហាញឱ្យឃើញនូវការខ្វះ "ការគោរពដំណើរការតុលាការ" រួមទាំងករណីដែលចៅក្រមមិនបានឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី និង នៅក្នុងករណីចៅក្រមជាតិ ចៅក្រមជាតិមិនព្រមកោះហៅសាក្សីសំខាន់បំផុតនៅក្នុងសំណុំរឿង ០០២។ ជាក់ស្តែង ក្នុងពេលជំនុំជម្រះលើសាលក្រមសំណុំរឿង ០០២/០១ និងមុនពេលចេញសាលក្រម ចៅក្រម Cartwright បានពិពណ៌នាសំណុំរឿង ០០២/០១ ថាជាការជំនុំជម្រះមួយ "មានភាពយុត្តិធម៌" ហើយត្រឹមប៉ុណ្ណឹងនៅក្នុងសុន្ទរកថារបស់លោកស្រីនៅវិទ្យាស្ថាន Aspen។ វាមិនមានការផ្លាស់ប្តូរអ្វីសោះ តាមពិតវាមិនពាក់ព័ន្ធ ប្រសិនបើវាមិនត្រឹមត្រូវថា ចៅក្រម Cartwright បានបង្ហាញផងដែរថា លក្ខខណ្ឌនៅក្រោមបទដ្ឋានដូចនេះមាននៅតុលាការអន្តរជាតិផ្សេងទៀត[245]។ អកុសល និងដូចចៅក្រម Van den Wyngaert បានលើកឡើង "វាមិនជាការល្អគ្រប់គ្រាន់នោះទេប្រសិនបើការជំនុំជម្រះភាគច្រើនមានភាពយុត្តិធម៌។ *វាត្រូវតែយុត្តិធម៌ទាំងអស់*"[246]។

128. ក្រៅពីការសន្និដ្ឋានជាទូទៅថា សេចក្តីសម្រេច និងទង្វើទាំងអស់របស់ចៅក្រមបង្ហាញនូវកង្វះសុចរិតភាពផ្នែកវិជ្ជាជីវៈចាំបាច់ក្នុងនាមជាចៅក្រមនៅក្នុងអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក និងថែមទាំងបានប៉ះពាល់ដល់នីត្យានុកូលភាពនៃ អ.វ.ត.ក ទាំងមូល មេធាវីការពារក្តីក៏បានធ្វើសេចក្តីសន្និដ្ឋានជាក់លាក់បន្ថែមចំនួនពីរទៀតទាក់ទងនឹងសញ្ញាណនៃសុចរិតភាព។

129. សញ្ញាណទីមួយ មេធាវីការពារក្តីសូមសន្និដ្ឋានថា នៅក្នុងសាលក្រមសំណុំរឿង ០០២/០១ ចៅក្រមបានផ្អែកហួសហេតុពេកលើសក្ខីកម្មរបស់អ្នកជំនាញ ជាពិសេស Philip Short, David Chandler, Ben Kiernan, Elizabeth Becker, Stephen Heder, François Ponchaud, Craig Etcheson, និង Henri Locard[247]។ ឧទាហរណ៍ យោងតាមការគណនាប៉ាន់ស្មានដោយមេធាវីការពារក្តី វាបានបង្ហាញឱ្យឃើញថា នៅក្នុងសាលក្រមសំណុំរឿង ០០២/០១ ចៅក្រមបាន

---

[245] កសព បានអះអាងក្នុងជំហរនេះ។ សូមមើល ឯកសារ **F2/2** "ចម្លើយតបរបស់ កសព ទៅនឹងសំណើលើទី១ និងទី២របស់ នួន ជា ស្នើសុំទទួលយក និងពិចារណាលើភស្តុតាងបន្ថែមពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខលើសាលក្រមសំណុំរឿង ០០២/០១" ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៤ កថាខណ្ឌ១៨។

[246] មតិយោបល់របស់ចៅក្រម Van den Wyngaert រឿងក្តី Katanga កថាខណ្ឌ ៣១១ (គូសបញ្ជាក់បន្ថែម)។

[247] ទោះបីជាត្រូវបានកោះហៅជាផ្លូវការក្នុងនាមសាក្សីក៏ដោយ ក៏បុគ្គលពីរនាក់ចុងក្រោយនេះបានផ្តល់សក្ខីកម្មក្នុងនាមអ្នកជំនាញយ៉ាងមានប្រសិទ្ធភាព។

យោងលើអ្នកជំនាញ/ពាក់កណ្តាលអ្នកជំនាញAnglo-Frenchទាំងប្រាំបីនាក់សរុបទាំងអស់៧៩១ដង[248] ច្រើនជាងការយោងលើសាក្សី អ្នកជំនាញ ឬ ដើមបណ្តឹងផ្សេងទៀតដែលបានផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១ ក្រៅពី ឌុច ទៅទៀត។ បណ្តឹងមិនចិត្តនេះពុំមែនធ្វើឡើងដើម្បីវាយតម្លៃលើអង្គច្បាប់នៃការប្រើប្រាស់ដ៏ច្រើនលើសលប់លើភ័ស្តុតាងរបស់អ្នកជំនាញនោះទេ។ ក៏ប៉ុន្តែ មេធាវីការពារក្តីសូមសន្និដ្ឋានថា ការសំអាងលើអ្នកស្រាវជ្រាវមកពីប្រទេសដែល នួន ជា គិតថា ជាប្រទេសអាណានិគម និងចក្រពត្តិ បែបនេះធ្វើឱ្យចោទជាបញ្ហាអំពី "ការគោរពពិតប្រាកដលើដំណើរការតុលាការ" ដោយចៅក្រម និងឆន្ទៈក្នុងការពិចារណាលើអង្គសេចក្តីពិតប្រាកដនៃអង្គហេតុ និងបញ្ហានានានៅក្នុងរឿងក្តី ជាជាងតាមរយមនោគមន៍វិជ្ជា។ វាអាចបង្ហាញឱ្យឃើញផងដែរថា ចៅក្រមតែងតែជឿជាក់លើទ្រឹស្តីនៃហេតុការណ៍ដូចបានលើកឡើងនៅក្នុងសៀវភៅមួយចំនួន[249] ដែលបានបោះពុម្ពផ្សាយនៅមុនពេល អ.វ.ត.ក ចាប់ផ្តើមដំណើរការ ហើយ ជំហរចៅក្រម Cartwright និង Lavergne គឺពិតជារឿងមនោគមវិជ្ជាដោយសារតែ "អ្នកជំនាញ" ទាំង៨ មកពីប្រទេសដែលមានមនោគមន៍វិជ្ជាដូចគ្នា។ ពិតណាស់ ប្រសិនបើវាជាការពិតនោះ ចៅក្រមបានសម្តែងល្ខោនយ៉ាងមានប្រសិទ្ធភាពធ្វើឱ្យដំណើរការដែលបានចំណាយទឹកប្រាក់ជាង ២០០ លានដុល្លារសហរដ្ឋអាមេរិកក្នុងរយៈពេល៧ ឆ្នាំ នេះចេញបានត្រឹមសាលក្រមមួយលើសំណុំរឿង ០០២/០១។

130. សញ្ញាណទីពីរ មេធាវីការពារក្តីសូមសន្និដ្ឋានថា ការលេចចេញនូវសុចរិតភាពរបស់ចៅក្រម Lavergne ដែលបានស្តែងឱ្យឃើញនៅពេលចេញមតិយោបល់ភាគតិច (រួមជាមួយនឹងចៅក្រម Cartwright) នៅក្នុងសេចក្តីសម្រេចស្តាពរអំពីសាក្សី ពុំបានប្រកាន់ខ្ជាប់រហូតដល់ដំណាក់កាលចុងក្រោយនោះទេ។ ការពិតណាស់ មេធាវីការពារក្តីមិនយល់សោះហេតុអ្វីបានជាចៅក្រម Lavergne បែរជាសម្រេចដូច្នេះទៅវិញថា ក្រោយពីបានសម្រេចនៅក្នុងមតិយោបល់ភាគតិចថា

---

[248] យោងតាមការពិនិត្យមើលឡើងវិញពីដំបូង និងតាមការប៉ាន់ស្មានលើភ័ស្តុតាងដែលត្រូវបានដកស្រង់នៅក្នុងសំណុំរឿង វាហាក់ដូចជាបង្ហាញឱ្យឃើញថា Philip Short ត្រូវបានដកស្រង់ប្រហែលជា ២៦៦ ដង David Chandler ១១៧ ដង, Ben Kiernan ៤៦ដង Elizabeth Becker ៦៩ ដង Stephen Heder ១៤៩ ដង និង François Ponchaud ប្រហែលជា ១២៣ ដង Craig Etcheson ១២ ដង, and Henri Locard ៩ ដង ។ *សូមមើល* ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១។

[249] ឯកសារ E3/1684 សម្លេងពីមន្ទីរ ស-២១ និងឯកសារ E3/9 Philip Short "ប៉ុលពត ៖ ប្រវត្តិនៃសុបិន្តអាក្រក់មួយ" ឆ្នាំ ២០០៤។ E3/20, 'When the War Was Over'; E3/1593, 'The Pol Pot Regime'; E3/1815, 'How Pol Pot Came to Power'; E243.1, 'Cambodia: Year Zero'។

សក្ខីកម្មរបស់ ហេង សំរិន មិនត្រឹមតែ "ជាប់ពាក់ព័ន្ធ*ជាចម្បង*" ប៉ុណ្ណោះទេ សក្ខីកម្មនេះអាចមាន "ព័ត៌មានដែលមិនអាចដឹងដល់សាក្សីដែលត្រូវបានស្នើសុំផ្សេងទៀតនៅក្នុងសំណុំរឿង ០០២/០១"[250] ចៅក្រម Lavergne បែរជាជឿហួសពីវិមតិសង្ស័យលើភ័ស្តុតាងដែលបានបង្ហាញនៅក្នុងសំណុំរឿង ០០២/០១[251]។ ជាថ្មីម្តងទៀត យោបល់របស់ចៅក្រម Van den Wyngaert នៅក្នុងមតិយោបល់ភាគតិចរបស់គាត់ក្នុងរឿងក្តី Katanga បង្ហាញនូវការពិតថា៖

> ខ្ញុំយល់ឃើញថា វាចម្លែកនៅពេលទទួលស្គាល់ថា ភ័ស្តុតាងសំខាន់ៗបាត់ចេញពីក្នុងសំណុំរឿង ប៉ុន្តែបែរជាបាន*សម្រេចយ៉ាងជាក់លាក់ហួសពីវិមតិសង្ស័យលើចំណុចទាំងឡាយ ដែលភ័ស្តុតាងបាត់ទាំងនោះអាចផ្តល់ជាពន្លឺមួយផ្សេងពីនេះ*។ [...] យើងចាំបាច់ត្រូវពិចារណាអំពីសារៈសំខាន់នៃភ័ស្តុតាងដែលបានបាត់នោះចំពោះបន្ទុកនៃការបង្ហាញភ័ស្តុតាង។ ជាការពិតណាស់ គេអាចឆ្ងល់ថា តើ គេអាចឈានដល់លក្ខខណ្ឌអប្បបរមាដែរឬទេនៅពេលបញ្ហាចោទជាច្រើននៅឃើញមាន និងក្នុងករណីដែលវាបង្ហាញឱ្យឃើញច្បាស់ថា ប្រសិនបើមានភ័ស្តុតាងច្រើន និងប្រសើរជាងនេះ វាអាចនាំឱ្យមានចម្លើយខុសពីនេះស្រឡះទៅវិញ[252]។

131. កាលពីខែមុន កិច្ចប្រជុំពេញអង្គនៃតុលាការ ICC បានលើកអំពីលទ្ធភាពដែលចៅក្រមអាចចេញមតិយោបល់ភាគតិចមកធ្វើជាឧទាហរណ៍អំពីសុចរិតភាពរបស់តុលាការ។ កិច្ចប្រជុំពេញអង្គបានយល់ស្របចាត់ទុកចំណុចនេះជាយន្តការមួយដែល៖

> [អាចឱ្យ] ចៅក្រមរក្សានូវ*សុចរិតភាព* ក្នុងការគិតពិចារណាត្រឹមត្រូវ...ការពារកិច្ចដំណើរការនីតិវិធីពីការអូសទាញឱ្យមានការឯកភាពគ្នាដោយបង្ខិតបង្ខំ ផ្តល់ជាចលករដ៏ចាំបាច់មួយសម្រាប់បង្កើតច្បាប់ និងការពារភាពជាប់គាំងក្នុងការធ្វើសេចក្តីសម្រេច [...] និងបង្ហាញដល់ភាគី អ្នកចូលរួម និងសាធារណៈជនទូទៅថា រឿងក្តីនេះត្រូវបានវាយតម្លៃ

---

[250] ឯកសារ E312 សេចក្តីសម្រេចចុងក្រោយលើសាក្សី កថាខណ្ឌ ១០៨។

[251] ដូចចៅក្រម Van den Wyngaert ស្នើឡើង ការខ្វះភ័ស្តុតាងប្រភេទនេះអាចចោទជាបញ្ហាថាតើលក្ខខណ្ឌអប្បបរមានៃការបង្ហាញភ័ស្តុតាងបានបំពេញដែរឬទេ៖ *សូមមើល* មតិយោបល់របស់ចៅក្រម Van den Wyngaert រឿងក្តី Katanga កថាខណ្ឌ ១៤៨។

[252] មតិយោបល់របស់ចៅក្រម Van den Wyngaert រឿងក្តី Katanga កថាខណ្ឌ ១៤៨-១៤៩។

យ៉ាងហ្មត់ចត់[253]។

132. ប្រសិនបើចៅក្រម Lavergne បានបំពេញការងារតាមគោលការណ៍សុចរិតភាពផ្នែកសីលធម៌របស់តុលាការមែននោះ មេធាវីការពារក្តីសូមសន្និដ្ឋានថា ការខកខានក្នុងការកោះហៅ ហេង សំរិន គួរនាំឱ្យចៅក្រមសម្រេចថា នួន ជា មិនមានពិរុទ្ធភាព។ ប្រសិនបើចៅក្រមរូបនេះបានបំពេញការងារតាមគោលការណ៍សុចរិតភាពផ្នែកសីលធម៌របស់តុលាការមែននោះ គាត់គួរមិនទទួលស្គាល់ក្នុងពេលដំណាលគ្នាថា ចៅក្រមជាតិច្បាស់ណាស់ថាមិនមានឆន្ទៈក្នុងការកោះហៅ ហេង សំរិន ហើយក្នុងពេលជាមួយគ្នានោះដែរ ចៅក្រមរូបនេះបានធ្វើការសម្រេចយ៉ាងកំសាកថា៖

> យើងយល់ឃើញច្បាស់ថា ប្រសិនបើមានបណ្តឹងឧទ្ធរណ៍ បញ្ហានេះអាចនឹងត្រូវបានដោះស្រាយដោយសារតែ*អង្គជំនុំជម្រះតុលាការកំពូល មានអំណាចកោះហៅសាក្សី* និងទទួលខុសត្រូវក្នុងការកំណត់ចុងក្រោយអំពីផលប៉ះពាល់ណាមួយដែលកើតចេញពីការខកខានមិនបានកោះហៅសាក្សី។ ដោយពិចារណាទៅលើលទ្ធផលនេះ *យើងមិនបញ្ចេញមតិយោបល់អំពីបញ្ហានៃភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីក្នុងការជំនុំជម្រះ ដែលសហសេវិកជាតិរបស់យើងលើកឡើងនោះទេ*[254]។

133.ម្យ៉ាងវិញទៀត ប្រសិនបើចៅក្រម Lavergne បានបំពេញការងារតាមគោលការណ៍សុចរិតភាពផ្នែកសីលធម៌របស់តុលាការមែននោះ ចៅក្រម Lavergne ប្រាកដជាមិនកាយកប់មតិជំទាស់របស់គាត់ថាតើគួរ ឬមិនគួរកោះហៅ ហេង សំរិន នៅក្នុងសេចក្តីសម្រេចដោយឡែកនោះទេ។ វាគួរតែដាក់បញ្ចូលនៅក្នុងសាលក្រមសំណុំរឿង ០០២/០១ បាត់ទៅហើយ ដែលជាកន្លែងមួយសមស្របជាង។ ដូច្នេះ នៅក្នុងករណីចៅក្រម Lavergne ខកខាន "ក្នុងការប្រឈមនឹងផលវិបាកនៃទស្សនៈយល់ឃើញដែលអាចមិនមានរួមគ្នា" និង "ក្នុងការលះបង់ដែលជាភារកិច្ចរបស់ចៅក្រមត្រូវបំពេញ" - ឧទាហរណ៍ តាមរយៈភាពក្លាហានឈានដល់ការសម្រេចមិនប្រជាប្រិយ តែការពិត - គឺជាចំណុចមួយធ្ងន់ធ្ងរបំផុត ទោះបីជាចៅក្រមទាំងអស់បានខកខានដូចគ្នាក៏ដោយ។ យ៉ាងហោចណាស់ ការខកខាននេះក៏គួរនាំឱ្យមានការប្តឹងជំទាស់ចៅក្រម Lavergne ដោយសារកង្វះនូវភាព

---

[253] រឿងក្តី *អយ្យការ ទល់នឹង Katanga* រឿងក្តីលេខ ICC-01/04-01/07 "សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះលើពាក្យសុំរបស់មេធាវីតំណាងជនរងគ្រោះស្នើសុំប្តឹងជំទាស់ចៅក្រម Christine Van den Wyngaert ចេញពីក្នុងរឿងក្តី *អយ្យការ ទល់នឹង Katanga*" ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៤ កថាខណ្ឌ ៥១។

[254] ឯកសារ E312 សេចក្តីសម្រេចស្តាពរស្តីពីសាក្សី កថាខណ្ឌ ១១១។

អញ្ញាក្រឹតលើបញ្ហាសំខាន់ៗបំផុតទាំងអស់ ដែលនឹងស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ពោលគឺ ការទទួលខុសត្រូវរបស់ នួន ជា ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់លើគាត់។

## V. សេចក្តីសន្និដ្ឋាន

134. នៅក្នុងការរៀបរាប់ដ៏មានឥទ្ធិពលមួយលើការជំនុំជម្រះក្នុងរឿងក្តី *Eichmann* Hannah Arendt បានលើកយោបល់ថា ៖

> ការជំនុំជម្រះលើរឿងក្តី [*Eichmann*] មានគោលបំណង*គ្មានអ្វីក្រៅពីការផ្តល់យុត្តិធម៌* ទោះបីជាគោលបំណងបិទបាំងដ៏ធំមួយ - "ការកត់ត្រាទុកនូវរបបអ៊ីត្លែរ..." - អាចបន្ថយតម្លៃការងារចម្បងលើអង្គច្បាប់ក៏ដោយ ពោលគឺ *ការថ្លឹងថ្លែងលើបទចោទដាក់បន្ទុកលើជនជាប់ចោទ ការចេញសាលក្រម និងការដាក់ទណ្ឌកម្មសមស្រប*[255] ។

135. មេធាវីការពារក្តីសូមសន្និដ្ឋានថា ការងារនេះហើយដែលចៅក្រមទាំងអស់*គួរតែបានបំពេញ* និង*ចាំបាច់ត្រូវបំពេញ*នៅក្នុងសំណុំរឿង ០០២/០១។ ទោះបីជាយ៉ាងនេះក៏ដោយ សព្វថ្ងៃនេះ ទស្សនៈរបស់ Hannah Arendt អំពីគោលបំណងនៃការជំនុំជម្រះនីមួយៗ ត្រូវតែយកជម្នះលើទស្សនៈដ៏ពេញនិយម នៅក្នុងករណីដូចករណីទាំងនេះ សាលាក្តីមានកាតព្វកិច្ចពិសេសលើអង្គហេតុដែលថា រឿងក្តីរបស់ចៅក្រមមិនមែនពាក់ព័ន្ធនឹងការលួចកង់នោះទេ ប៉ុន្តែ វាពាក់ព័ន្ធនឹងការចោទប្រកាន់លើឧក្រិដ្ឋកម្មដ៏ព្រៃផ្សៃធំៗ។ វាប្រាកដណាស់ថា អង្គជំនុំជម្រះសាលាដំបូងយល់ពី អវតក ក្នុងន័យនេះ ហើយបានស្វែងរកការប្រើសាលក្រមនៅក្នុងករណី០០២/០១ ដើម្បីបន្សល់ទុកមរតកដែលនិយាយទៅកាន់ប្រជាជនកម្ពុជា។ តែប្រសិនបើគោលបំណងដែលមានទំងន់នេះ គឺជាគោលបំណងត្រឹមត្រូវសម្រាប់ចៅក្រមទាំងប្រាំរូបនៃអង្គជំនុំជម្រះនេះ នោះករណីនេះ នឹងតម្រូវឱ្យមានការពិនិត្យពិច័យឱ្យបានហ្មត់ចត់ ដើម្បីភាពត្រឹមត្រូវនៃដំណើរការនីតិវិធី និងសច្ចៈភាពនៃលទ្ធផលរបស់វា។ ករណីនេះគឺពុំមែនដោយសារតែភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ និងវិសាលភាពនៃការរងគ្រោះដែលកើតចេញពីឧក្រិដ្ឋកម្មដូចបានចោទប្រកាន់ទាំងនេះនោះទេ វាគឺដោយសារ*ផលប៉ះពាល់ដែលបង្ហាញឱ្យឃើញថា* សាលាក្តីទាំងឡាយដូចសាលាក្តីនេះគួរមាន នៅក្នុងបរិបទជាក់លាក់ដែលខ្លួនបានបង្កើតឡើង ព្រមទាំងនៅក្នុងបរិបទអន្តរជាតិដ៏ទូលំទូលាយជាងនេះ។ អ.វ.ត.ក

---

[255] Hannah Arend, 'Eichmann in Jerusalem: A Report on the Banality of Evil' ឆ្នាំ ១៩៦៣ ទំព័រ ២៥១។

*គួរ*បង្ហាញថា គ្មាននរណាម្នាក់នៅពីលើច្បាប់នោះទេ។ អ.វ.ត.ក គួរបង្ហាញផងដែរថា ច្បាប់មានសុចរិតភាពរបស់វា និងមានបំណងស្វែងរកការពិត ពុំមែនការសងសឹក ប្រសិនបើ អ.វ.ត.ក ចង់ធ្វើជា "*តុលាការគំរូ*" ដូចអង្គជំនុំជម្រះបានពិពណ៌នាមែននោះ[256]។

136. ក៏ប៉ុន្តែ គោលបំណងរបស់សាលាក្តីនេះត្រូវបានកំណត់រួចហើយ។ ប្រសិនបើចៅក្រមនៅបន្តចូលរួមជំនុំជម្រះលើសាលក្រមសំណុំរឿង ០០២/០២ ទៀតនោះ ករណីនេះនឹងរំលោភ*សិទ្ធិជាមូលដ្ឋាន*របស់ នួន ជា *ក្នុងការទទួលបានការជំនុំជម្រះមួយប្រកបដោយយុត្តិធម៌* ដោយសាលាក្តីឯករាជ្យ និងមិនលម្អៀង ហើយវានឹងធ្វើឱ្យប៉ះពាល់ដល់តម្លៃ "យុត្តិធម៌" ដែលបានផ្តល់ជូននៅក្នុងសាលាក្តីនេះ។ វានឹងធ្វើឱ្យអន្តរាយធ្ងន់ធ្ងររហូតដល់បទដ្ឋានគតិយុត្តនៅក្នុងប្រទេសកម្ពុជាដោយធ្វើឱ្យកាន់តែបាត់បង់ជំនឿថែមទៀតលើប្រព័ន្ធតុលាការ និងធ្វើឱ្យសញ្ញាណដែលមានពីមុនមកកាន់តែមានភាពរឹងមាំថា ស្ថាប័នមួយចំនួនដំណើរការឡើងដើម្បីបង្ហាញតែអំណាចគ្មានវិចារណញ្ញាណ ពោលគឺការបង្ហាញអំណាចដែលគ្មានចង់បានអ្វីក្រៅពីយុត្តិធម៌សម្រាប់អ្នកឈ្នះ ហើយវានឹងធ្វើឱ្យការរៀបរាប់ផ្នែកមនោគមន៍វិជ្ជាដ៏មានលក្ខណៈនយោបាយខ្លាំងដែលអ្នកឈ្នះដូចជា ហេង សំរិន ដែលសម្តេចឪធ្លាប់ហៅថា "អាយ៉ងគួរឱ្យអាណិតរបស់វៀតណាម"[257] និងមានមនោគមន៍វិជ្ជាទៅរកអ្នកប្រាជ្ញ Anglo-French បានបង្កើតឡើងកាន់តែរឹងមាំថែមទៀត។ ប្រវត្តិសាស្ត្រនឹងពុំគាំទ្រលើសាលក្រមទាំងឡាយណាដែលបានធ្វើឡើង ក្នុងកាលៈទេសៈបែបនេះឡើយ។

137. ក៏ប៉ុន្តែ ទោះបីជាទង្វើ និងការសម្រេចរបស់ចៅក្រមនៅក្នុងសំណុំរឿង ០០២/០១ កំពុងបង្កព្យសនកម្មយ៉ាងខ្លាំងក៏ដោយ មេធាវីការពារក្តីនៅតែជឿជាក់ថា ស្ថានភាពនេះអាចជួសជុលបាន ហើយយើងនៅមានឱកាសធានាថា សាលាក្តីនេះនឹងផ្តល់យុត្តិធម៌ពិតប្រាកដ បន្សល់ទុកកេរតំណែលវិជ្ជមានចិតថេរសម្រាប់បទដ្ឋានគតិយុត្តនៅក្នុងប្រទេសកម្ពុជា និងចុងក្រោយបង្ហាញការពិត។ ការប្តឹងជំទាស់ចៅក្រមចេញពីកិច្ចដំណើរការនីតិវិធីខាងមុខប្រឆាំងនឹង នួន ជា គឺជាវិធានការសំខាន់មួយក្នុងផ្លូវត្រូវ។

[256] ឯកសារ E5/3, សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រម និល ណុន កថាខណ្ឌ ១៥។

[257] ឯកសារ E307/5.2.2, កំណត់ហេតុផ្លូវការនៃការកិច្ចប្រជុំរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ "ប្រជុំថ្ងៃទី១១ ខែមករា ឆ្នាំ១៩៧៩", para. 85 (សន្ទរកថារបស់សម្តេចសីហនុ)។

## VI. **សំណើសុំ**

138. យោងតាមហេតុផលដូចបានរៀបរាប់ខាងលើ មេធាវីការពារក្តីសូមស្នើឲ្យ (i) អង្គជំនុំជម្រះទទួលយកពាក្យសុំនេះ (ii) ចៅក្រមទាំងអស់ត្រូវបានដកចេញជាអចិន្ត្រៃយ៍ពីកិច្ចដំណើរការនាពេល ខាងមុខប្រឆាំងនឹង នួន ជា (iii) ចៅក្រមទាំង ចៅក្រមលាចុះពីតំណែង ដោយស្ម័គ្រចិត្ត អនុលោមតាមវិធាន ៣៤(៥) នៃវិធានផ្ទៃក្នុងខណៈពេលសម្រេចលើពាក្យសុំនេះ (iv) ការចាប់ផ្តើមសវនាការលើភស្តុតាងក្នុងសំណុំរឿង០០២/០២ ត្រូវតែពន្យារហូតដល់មានការសម្រេចលើបណ្តឹងនេះ និង (v) អង្គជំនុំជម្រះចាត់ទុកបណ្តឹងដិតចិត្តនេះជាបញ្ហាបន្ទាន់ដោយសារលក្ខណៈ ពិសេសនៃបណ្តឹង។

សហមេធាវីការពារក្តីលោក នួន ជា

**សុន អរុណ**

**Victor KOPPE**